# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣១ លេខ ៨ ខែសីហា

ព. ស. ២៥០២ គ. ស. ១៩៥៩

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ព្រះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|


- ទីបធម្មកថា របស់ព្រះមហា ជា-សន . . . . . ៨៤៥
- ឧដ្ឋានធនលាភទេសនា របស់ព្រះមហា ម៉ៅ-ខាន់ . . . . ៨៥៧
- សុរពជាតក (តមក) លោក ថង-វង ចម្លងពីសាស្ត្រាស្លឹករឹត . . . ៨៦៦


### ផ្នែកអក្សរសាស្ត្រ


- រឿងហង្សយន្ត (តមក) លោក អឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត . . . . ៨៧១
- រឿងមរណមាតា (តមក) លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត . . . ៨៧៨
- រឿងព្រេងជ័យសួស្តី លោក ប៊ូ-ប៉ូ រៀបរៀង . . . . ៨៨៥
- រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន (តមក) លោក ភ៉យ-ប៊ុក រៀបរៀង . . ៨៩០
- សុចរិតនិងទុច្ចរិត រឿងព្រេងរុស្ស៊ី អ្នកស្រី ស-សាភ ប្រែរៀបរៀង . . ៩០៧
- រឿងស្រីគ្រប់លក្ខណ៍ យុក-វជិរ រៀបរៀង លោក ផេង-គ្រីវ ពិនិត្យ . ៩២០
- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ . . . . . . . . . ៩៣៨


### ផ្នែកកំណត់និងប្រវត្តិការណ៍


- សេចក្ដីថ្លែងការណ៍សារពតិមាន របស់ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា . . . . ៩៥០
- ពតិមានផ្សេងៗ របស់ក្រសួងធម្មការ . . . . . . . . . . . ៩៥៧
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . ៩៥៨



មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជាវ ២៣០រ០០

# KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

## sommaire

### Partie religieuse :


— Dipadhammakatha par Preah moha CHEA-SAN . . . . 845
— Uthànadhana la bha desana par Preah moha MAU-KHAN 857
— Sarabajataka (suite) recueilli du manuscrit sur feuilles de latanier par M. THANG-VONG . . . . . . 866


### Partie littéraire :


— Histoire de Hang-Yon (suite) recueillie du manuscrit sur feuilles de latanier par M. IM-PHON . . . . . . . 871
— Histoire de Marana Mâtâ recueillie du manuscrit sur feuilles de latanier par M. By-Sovan . . . . . . . . . . . 878
— Légende de Chey Sûos par M. BOU-PO . . . . . . . 885
— Contes et Légendes du Japon par M. RAY-BUC . . . . . 890
— L'honnêteté et la malhonnêteté, conte populaire Russe traduit par Mme SA-SARA . . . . . . . . . . . . 907
— La femme vertueuse par Yok Vochir revue et corrigée par M. PHENG-CHRIV . . . . . . . . . . . 920
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 938


### Notes et Chroniques :


— Tournée du Vén. Preah Pothivong HUOT-TAT Inspecteur de l'Enseignement du Bouddhisme . . . . . . . 950
— Nouvelles diverses du Ministère des Cultes . . . . . . . 957
— Dictionnaire Sanskrit-Khmer (suite) par Vén. PANG-KHAT . 958



Prix d'abonnement annuel (comprenant 12 numéros): 230$00 .

ផ្នែកសាសនា

# ទីបធម្មកថា

ព្រះមហា ជា-សន រៀបរៀង

## នមោ ៣ ដង

សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ( ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព ) ។

លំដាប់នេះ សូមសម្តែងអំពី ទីបធម្មកថា ។

ទីបធម្មកថា នេះ, សម្តេចព្រះអនាវរណញាណ ទ្រង់ប្រកបដោយប្រាជ្ញាដ៏មោះមុត ឥតមានអ្វីមួយជាគ្រឿងរើសចាក់គតិប្រាជ្ញារបស់ព្រះអង្គ ទ្រង់ត្រាស់ប្រកាសឡើងទុកជាមូលហេតុ សម្រាប់ញ៉ាំងសត្វដែលបានប្រតិបត្តិតាម ឲ្យមានសិទ្ធិចូលទៅត្រងរើយក នូវផល ៣ ប្រការគឺ: បច្ចុប្បន្នផល , សម្បរាយិកផល និង បរមត្ថផល បាន ព្រោះព្រះអង្គមានពុទ្ធបំណងដ៏ល្អវិសេស ប៉ងឲ្យពួកសត្វកល់និកាយបាន កប់ប្រសព្វដោយសុខសម្បត្តិចំរើនរុងរឿង ដោយគុណប្រយោជន៍នានា ទាំងបានយល់ច្បាស់លាស់នូវលោកគតិ " ដំណើររបស់លោក " ធម្មគតិ " ដំណើររបស់ធម៌ " ក្នុងលោកនេះ ទាំងលោកខាងមុខ នៅវេលាដែលមិនទាន់បានជួបប្រទះនូវព្រះនិព្វាន ។

សត្វទាំងឡាយ ដែលមិនទាន់បានទីបធម៌ យកមកកាន់ទុកជាទីគោរពប្រតិបត្តិតាមនៅឡើយ បេះតែលង់លិចទូក (គឺអត្តភាព) ក្នុងសមុទ្ទ (គឺសំសារវដ្ត) ឈ្មក់ទឹក (គឺនីវរណូបក្កិលេស) បាននៅជាចំណីត្រី (គឺមច្ចុរាជ) គ្របាក់លេបញ៉ីកញ៉ាប់ធ្វើជាអាហារ ។ ចំណែកខាងឥន្ទពាលសត្វដែលមិនបានប្រតិបត្តិតាមទីបធម៌ ឥតបានដឹង បានយល់ដូច្នោះឡើយ ម៉្លោះហើយតែងតែជួបប្រទះនឹងទុក្ខវេទនាក្នុងសមុទ្ទសំសារវដ្តនោះឯង; ឯកល្យាណសត្វ ដែលបានប្រតិបត្តិតាម ទើបអាចយល់ហេតុការណ៍នោះបានដោយសភាពពិត ៗ ។

ទីបធម្ម នេះ ប្រែថា "ធម៌ជាទីពឹង, ធម៌ជាប្រទីប ឬថាធម៌ដូចជាកោះ" ។

ទីបធម្ម នេះចែកចេញជា ៤ ប្រភេទ គឺ:

១- ឧដ្ឋាន ការម៉ឹមាក្រេវក្រតែន ប្រកបការងារដែលត្រូវប្រកប ។

២- អប្បមាទ ការមិនធ្វេសប្រហែស មិនភ្លេចស្មារតី ។

៣- សញ្ញម ការសង្រួម-ប្រយ័ត្ន-រាំងឥន្ទ្រិយទាំង ៦ ។

៤- ទម ការទូន្មានចិត្ត ប្រដៅចិត្ត ឲ្យមានបែបបទសណ្ដាប់ធ្នាប់ល្អ ។

សូមលើកយកប្រភេទមួយម្ដងៗ មកអធិប្បាយដូចតទៅ :-

១- ឧដ្ឋាន ការម៉ឹមាប្រកបការងារដែលត្រូវប្រកបនេះ ស្របគ្នា

ហីនវីរិយៈ (សេចក្តីព្យាយាម) ដែលមានកោសជ្ជៈ (សេចក្តីខ្ជិលច្រអូស) ជាទីទាស់ ។ សេចក្តីព្យាយាមប្រកបការងារ មិនមែនសុទ្ធតែត្រូវតាំងអស់នោះទេ មានការងារនៃបុគ្គលខ្លះប្រកបខុសកិច្ចដែរ តួយ៉ាងដូចជាជនពួកខ្លះ មានអត្តភាពជាមនុស្ស បែរជាទៅប្រកបការងារដែលជាកិច្ចរបស់សត្វតិរច្ឆានទៅវិញ យ៉ាងនេះហៅថា ការងារខុសកិច្ច ។ បើដឹងថាខ្លួនជាមនុស្សហើយ ត្រូវតែព្យាយាមប្រកបការងារដែលជារបស់មនុស្ស គឺមនុស្សកម្ម (ការងារល្អដែលមនុស្សត្រូវធ្វើ) មនុស្សធម៌ (ធម៌ល្អមានសុចរិតធម៌ជាដើម ដែលមនុស្សត្រូវកាន់) វិជ្ជាធម៌ (សេចក្តីចំរើនដែលមនុស្សត្រូវចំពេញ) ព្រោះមនុស្សមានសិទ្ធិ-សេរី-អធិបតេយ្យនឹងករណីយកិច្ចតាំងអស់ មិនមែនមានការងារឬធម៌ដូចសត្វតិរច្ឆាននោះទេ ។ ការប្រឹងប្រែងមំម្នា ប្រកបខ្លួនឲ្យបរិបូណ៌ដោយសេចក្តីព្យាយាម បែរមុខទៅរកកុសលធម៌ ទើបហៅថាការងារត្រូវប្រកប ។ សេចក្តីព្យាយាមនេះ ជាគុណធម៌អាចឲ្យសម្រេចប្រយោជន៍គ្រប់យ៉ាង តាមសមគួរដល់ឧបនិស្ស័យវាសនារបស់ខ្លួនពិតប្រាកដ អាចលើកស្ទួយបុរស-ស្ត្រីឲ្យផុតអំពីសភាពជាគតាបក្រខ្សត់អត់ឃ្លានល្ងង់ខ្លៅបាន ហើយដាក់ទៅលើសភាពថ្លៃថ្នូរប្រសើរ ជាគុណធម៌មានអានិសង្សច្រើនជាអនេក ដូចជាក្នុងបធានសូត្រ ដែលព្រះលោកនាថទ្រង់សម្តែងដាស់តឿនថា :

សំវរោ ច បហានញ្ច ភាវនា អនុរក្ខនា

ឯតេ ចត្តារោ បធានា ទេសិតាទិច្ច ពន្ធុនា
យេហិ ភិក្ខុ ឥធាតាបី ខយំ ទុក្ខស្ស បាបុណេ

ប្រែថា: បធាន: គឺធម៌ជាគ្រឿងផ្តួចផ្តើមតាំង ៤ យ៉ាងនេះ គឺ:

ក) សំវរោ រាំងប្រយ័ត្នមិនឲ្យបាបអកុសលកើតឡើងបាន ។

ខ) បហានំ លះបាបអកុសលដែលកើតឡើងហើយ ។

គ) ភាវនា បំពេញកុសលដែលមិនទាន់កើតឲ្យកើតឡើង ។

ឃ) អនុរក្ខនា រក្សាកុសលគឺសេចក្តីល្អ ដែលកើតឡើងហើយ មិនឲ្យវិនាសសាបសូន្យទៅវិញ ។

បធានធម៌តាំង៤យ៉ាងនេះ ព្រះសម្ពុទ្ធមានផៅពង្សដូចជាព្រះអាទិត្យ ទ្រង់សម្តែងហើយ ។ ភិក្ខុក្នុងសាសនានេះ គួរតែប្រឹងព្យាយាមធ្វើកិលេស ឲ្យទ្រុឌទ្រោមរងស្លុតដោយបធានធម៌ ដែលបានពោលមកហើយនេះ ទើបដល់នូវកិរិយាអស់ទៅនៃសេចក្តីទុក្ខព្រួយគ្រប់យ៉ាងបាន ។

២- អប្បមាទ: «ការមិនធ្វេសប្រហែស» នេះ ត្រូវគ្នានឹងសតិ "សេចក្តីនឹកឃើញចាំបាន" ។ អប្បមាទ: ទាន បមាទ: «ការធ្វេសប្រហែស» ជាបដិបក្ស, បមាទ: មានសតិវោស្សគ្គ: ជាលក្ខណ: ។

អប្បមាទ: ជាគូដដ្ឋានរបស់កុសល ហើយជាសភាវធម៌មានថ្លៃយ៉ាងធំបំផុត ជាកំពូលនៃកុសលធម៌ទាំងពួង សមដូចព្រះពុទ្ធដីកាថា

:យេ កេចិ កុសលា ធម្មា សព្វេ តេ អប្បមាទមូលកា

អប្បមាទសមោសរណា អប្បមាទោ តេសំ អគ្គមក្ខា-
យតិ សេចក្តីថា: ពួកធម៌ជាកុសលណាមួយ, ពួកធម៌ជាកុសលទាំងអស់នោះ មានសេចក្តីមិនប្រមាទជាមូល ប្រជុំចុះក្នុងសេចក្តីមិនប្រមាទ. បណ្ឌិតពោលសរសើរសេចក្តីមិនប្រមាទថា ជាកំពូលនៃកុសលធម៌ទាំងនោះ ។

សេចក្តីមិនប្រមាទនេះ ថាជាកំពូលនៃកុសលធម៌នោះ ព្រោះថា បណ្តាកុសលធម៌ទាំងអស់ កុសលធម៌ណាមួយ ដែលនឹងកើតឡើងបាន ក៏ព្រោះតែសេចក្តីមិនប្រមាទកើតឡើងជាមុន ឬក៏មានសេចក្តីមិនប្រមាទនៅពីមុនខ្វះមកហើយទើបកើតឡើងបាន, ដូចមេដំបូលប្រាសាទដែលជាទីប្រជុំចុះនៃគ្រឿងទព្វសម្ភារៈទាំងឡាយ មានផ្តួន ផ្ទាន ជាដើម ព្រោះហេតុនេះ បានជាព្រះមានព្រះភាគទ្រង់សំដែងសេចក្តីមិនប្រមាទដោយបរិយាយផ្សេងៗ មានដើមថា: នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំ សមនុបស្សាមិ ម្នាលភិក្ខុទាំងឡាយ! តថាគតមិនឃើញមានធម៌ដទៃណាមួយ ដែលជាហេតុញ៉ាំងកុសលមិនទាន់កើតឲ្យកើតឡើង ញ៉ាំងកុសលដែលកើតឡើងហើយ ឲ្យរឹងរឹតតែចំរើនឡើង ដូចសេចក្តីមិនប្រមាទនេះឡើយ; សូម្បីតែព្រះអង្គជិតនឹងបរិនិព្វានគង់ព្រះអង្គទ្រង់សំដែងជាស់តឿនថា ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ ម្នាលភិក្ខុទាំងឡាយ តថាគតជាស់តឿនអ្នក

តាំងអស់គ្នា វយធម្មា សង្ខារា សង្ខារទាំងឡាយមានសេចក្ដីសូន្យជាធម្មតា អប្បមាទេន សម្បាទេថ អ្នកទាំងឡាយចូរញុំាងប្រយោជន៍ឲ្យសម្រេចដោយសេចក្ដីមិនប្រមាទចុះ ។

អប្បមាទៈ ការមិនធ្វេសប្រហែសនេះ បើបុគ្គលអាចនឹងបណ្ដុះឲ្យចាក់ឫសនៅក្នុងសន្ដានបាន ចាត់ទុកថាជាគុណប្រសើរណាស់; ព្រោះការអ្វីក៏ដោយ ដែលបែរជាក្លាត់ខូចបង់ទៅ, បាក់បែកវិនាសទៅ ក៏ព្រោះតែសេចក្ដីធ្វេសប្រហែស, បើអប្បមាទៈ "សេចក្ដីមិនធ្វេសប្រហែស" មាននៅហើយ ការនោះៗ មិនអាចខូចបង់ទៅបានឡើយ, មានតែសេចក្ដីចំរើន សេចក្ដីល្អគង់វង់តែប៉ុណ្ណោះ ។ ក៏ឯការវង្វេងគ្មានដឹងខ្លួន គ្មានភ្ញាក់គំនិត គិតតែស្រវឹងជ្រុលជ្រប់ងប់ទៅក្នុងអំពើទុច្ចរិតឥតហិរិឱត្តប្បៈ ក៏ព្រោះតែបមាទៈដឹកនាំ, បើពោលសំដៅទៅរកបុគ្គលវិញថា បុគ្គលដែលជំពាក់ដោយបមាទៈ ទុកជារស់នៅអស់អាយុ១០០ឆ្នាំ ក៏ពុំប្រសើរឡើយ ព្រោះអស្សាសៈ និងបស្សាសៈ ដែលបុគ្គលប្រមាទនោះដកចេញ-ចូលតែងប្រឡាក់ដោយសេចក្ដីផ្ដន្ទាឈ្នានីសនិន្ទាឫស្យា; កាលណាដកចូលស្រូបយកតែអភិជ្ឈាទោមនស្ស ថម្ភៈ និងសារម្ភៈទៅផង, ដល់បញ្ចេញមកវិញហុយផ្សោងដូចផ្សែង គឺអទិន្នាទាន កាមេសុមិច្ឆាចារ ព្យាបាទៈ វិហឹសា មក្ខៈ និងបលាសៈ ។ ឯបុគ្គលមិនប្រមាទមិនដូច្នោះទេ គេតែងបង្វឹកខ្លួនឲ្យមានបញ្ញាគតិ ធ្វើដំណើរទៅតាមលក្ខណៈនៃសតិនិងសម្បជញ្ញៈ

ញុំាងវិចារណញ្ញាណ ឲ្យពិនិត្យពិច័យនូវប្រវត្តន៍របស់បញ្ចក្ខន្ធ បើកបញ្ញាចក្ខុសំឡឹងមុតទៅក្នុងវិមោក្ខមុខ (ទ្វាររបស់ព្រះនិព្វាន) ទំលាក់ត្រៃភារៈ គឺខន្ធភារៈ កិលេសភារៈ អភិសង្ខារភារៈ ចោល លែងប្រកាន់ភារៈដទៃ, ដើរទន្ទ្រានកាត់ព្រៃ គឺអស្មិ- មានៈ- តណ្ហា- ទិដ្ឋិ ឆ្ពោះមុខសំដៅទៅកាន់និព្វានទិស ។

លក្ខណៈ នៃបុគ្គលមិនប្រមាទមាន ៤ យ៉ាងគឺ:

ក) អព្យាបន្ន ដំណើរមិនមានការព្យាបាទ ។

ខ) សទា សតិ មានសតិសព្វ ៗ កាល ។

គ) អជ្ឈត្តំ សុសមាហិត មានចិត្តដំកល់មាំក្នុងខ្លួន ។

ឃ) អភិជ្ឈាវិនយេ សិក្ខា សិក្សាក្នុងការនាំចេញនូវអភិជ្ឈា ។

ឯអប្បមាទៈ នោះក៏គឺកិរិយាបរិបូណ៌ដោយសតិ, សតិនេះជាពហុបការធម៌ " ធម៌មានឧបការច្រើន " ហើយប្រព្រឹត្តទៅដោយបរិយាយច្រើនជាអនេក ។

៣- សញ្ញាមៈ " ការសង្រួម " បានដល់ការរាំងប្រុងប្រយ័ត្នទ្វារទាំង៦គឺ:

ក) ភ្នែក ទ្វារជាទីបញ្ជាក់រូប មានកិរិយាឃើញជាការងារ,

ខ) ត្រចៀក ទ្វារជាទីស្រូបសម្លេង មានកិរិយាឮជាការងារ,

គ) ច្រមុះ ទ្វារជាទីស្រូបក្លិន មានកិរិយាធុំជាការងារ,

ឃ) អណ្តាត ទ្វារជាទីជប់រស មានកិរិយាជ្រួតជ្រាបជាការងារ,

ង) កាយ ទ្វារជាទីបិទបាំង ស្អិតស្អាង មានកិរិយាប៉ះទង្គិចជាការងារ,

ច) ចិត្ត ទ្វារជាទីកើតនៃធម្មារម្មណ៍ មានកិរិយាត្រិះរិះពិចារណាជាការងារ, មិនឲ្យពួកមហាចោរ គឺលោភៈ ទោសៈ មោហៈ នាំពួកចោរដែលជាបរិវារ គឺអភិជ្ឈា និងទោមនស្ស ដើរចូលមកតាមទ្វារទាំង៦ នោះ ពោះទ្វារណាមួយ មកលបលួចយកទ្រព្យសម្បត្តិ គឺសីល-សមាធិ- បញ្ញា អំពីខ្លួ គឺហទយវត្ថុបានឡើយ ។ ឯការប្រុងប្រយ័ត្នរាំងទ្វារទាំង៦នោះ បានដល់ការតាំងសតិជាឆ្មាំទ្វារចាំឆែកឆេរ កាលបើនាយឆ្មាំទ្វារពិនិត្យទៅហើយដឹងថា នេះជាមហាចោរ នេះជាពួកចោរបរិវារ ដូច្នោះហើយនោះ ត្រូវឃាត់ដំណើរពួកនេះទុក ឬកំបណ្តេញបំបរឲ្យចេញផុតទៅ ។ តែបើសង្កេតពិនិត្យយ៉ាងម៉ត់ចត់ទៅហើយដឹងថា នេះជាពួកពាណិជក្រុមសតិប្បដ្ឋាន៤, នេះជាពួកកសិករក្រុមសម្មប្បធាន៤, នេះជាពួកអាកាសចរក្រុមឥទ្ធិបាទ៤, នេះជាពួកប្រធានក្រុមឥន្ទ្រិយ៥, នេះជាពួកពិជ័យសង្គ្រាមក្រុមពលៈ៥, នេះជាពួកបដិវេធប្បណ្ឌិត ក្រុមសម្ពោជ្ឈង្គៈ៧, នេះជាពួកមេដែនទីក្រុមមគ្គប្រកបដោយអង្គ៨ ដូច្នេះហើយ ត្រូវបើកឱកាសឲ្យធ្វើដំណើរចូលតាមទ្វារនោះ ៗ ទៅ ៗ ការប្រុងប្រយ័ត្ន មិនឲ្យបាបធម៌ទាំងឡាយ មានឱកាសចូលមកដឹកនាំ

បានយ៉ាងនេះ ទើបហៅថាសញ្ញមៈ ។

៤- ទមៈ " ការទូន្មានចិត្ត " បានដល់ការបង្កាត់សង្កិនចិត្ត ឲ្យមានរបៀបរៀបរយល្អ ឬការឃាត់ចិត្តទុកមិនឲ្យត្រេកត្រអាលចំពោះអកុសលកម្មផ្សេង ៗ ព្រោះថាចិត្តនេះ បើប្រាសចាកការទូន្មានប្រៀនប្រដៅហើយ នៅជាចិត្តប្រើការមិនកើតទេ តាំងពុំសមស្របដល់ការងារតាំងពួងទៀតផង ។ ហេតុនោះ ការទូន្មានប្រៀនប្រដៅចិត្តបានជាគុណប្រសើរបំផុត ឥតមានអ្វីជាគ្រឿងប្រៀបផ្ទឹមបានឡើយ ។ ពុទ្ធភាសិតសំដែងបញ្ជាក់ ចំពោះការទូន្មានប្រៀនប្រដៅចិត្តថា: ចិត្តស្ស ទមថោ សាធុ "ការទូន្មានចិត្តបាន ជាគុណញុំាងប្រយោជន៍ឲ្យសម្រេច", ចិត្តំ ទន្តំ សុខាវហំ " ចិត្តដែលគេប្រៀនប្រដៅបាន ជាគ្រឿងនាំមកនូវសេចក្ដីសុខ" ។

បុគ្គលមួយរូប ៗ សុទ្ធតែមានចិត្តជាអធិបតី, មានចិត្តជាគ្រឿងសម្រេចការ ឬមានចិត្តជាមេការ សមដូចពុទ្ធភាសិតគង់គម្ពីរធម្មបទខុទ្ទកនិកាយថា:

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា

មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា

តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

សេចក្ដីថា: ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តជាធំ

សម្រេចតែអំពីចិត្ត, បើបុគ្គលមានចិត្តអាក្រក់និយាយ ឬធ្វើការងារអ្វី(អាក្រក់) ចិត្តអាក្រក់នោះឯង តែងតែឲ្យកើតជាសេចក្តីទុក្ខលំបាក ហើយជាប់តាមទៅ, ដូចជាកង់រទេះដែលវិលជាប់តាមស្នាមជើងគោ ។

បុគ្គលគ្រប់រូបសុទ្ធតែមានចិត្តជាធំ- ជាគ្រឿងសម្រេចការឬជាមេការយ៉ាងនេះ បើគ្មានការហ្វឹកហ្វឺនចិត្ត គ្មានការបង្ហាត់ចិត្ត គ្មានបែបបទល្អសោះ គេមិនអាចដឹកនាំអត្តភាពនោះឲ្យទទួលយកសម្បត្តិសួគ៌-និព្វានសុខក្សេមក្សាន្តដូចម្តេចបាន ។

ហេតុនេះ គួរជនទាំងឡាយកំណត់ទុកថា: អាហារត្រូវបរិភោគរាល់ថ្ងៃ, ទឹកត្រូវផឹករាល់ថ្ងៃ បើដូច្នោះ ចិត្តក៏ត្រូវតែប្រដៅឲ្យរាល់ថ្ងៃដែរ ។ អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម តែងសរសើរការប្រៀនប្រដៅចិត្តនោះពេកណាស់ ដូចជាពុទ្ធភាសិតដែលទ្រង់ដាស់តឿនថា:

សុទុទ្ទសំ សុនិបុណំ យត្ថកាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។

សេចក្តីថា: បុគ្គលជាបណ្ឌិតមានប្រាជ្ញាគួរតែខំទូន្មានចិត្ត រក្សាចិត្ត ដែលឃើញបានដោយកម្រ ដែលល្អិតពន់ពេក ដែលលង់ទៅកាន់អារម្មណ៍ណាមួយហើយ មិនងាយនឹងទាញឲ្យងាកចេញមកវិញបាន, ចិត្តដែលអ្នកមានប្រាជ្ញាបានទូន្មានហើយ តែងនាំសុខមកឲ្យ ។

ធមៈ ការទូន្មានចិត្តពិតនោះគឺៈ ការពន្យល់ចិត្តឲ្យស្គាល់ទោស ដែលហៀរហូរចេញចាកលោភៈ ទោសៈ និងមោហៈ ហើយបង្វឹកហាត់ឲ្យ ស្រឡាញ់គុណានិសង្សរបស់ត្រៃសិក្ខាគឺ សីលសិក្ខា សមាធិសិក្ខា និងបញ្ញាសិក្ខា ; ឲ្យត្រាច់ទៅតាមផ្លូវនៃអរិយធម៌ ចូលសំដៅទៅ និព្វានបុរី ដើម្បីយកសុទ្ធិសម្បត្តិ ឬក៏យកបំពង់គឺសមាធិទាំង ៤ ទៅ ស្រូបទឹក (ទុយ) ទាំង ៤ អន្លង់ បង្ហូរចោលឲ្យអស់អំពីមហាសមុទ្រ គឺ តណ្ហា , ហើយយកទឹកគឺសីល ទៅលត់ក្អក់ភ្លើង គឺមានៈ, យក កែវផ្ទះ គឺបញ្ញា ទៅបញ្ចាំងស្លាប់ងងឹត គឺមោហៈ ។ កាលបើយោ-គាវចរ ព្យាយាមទូន្មានចិត្តដូចន័យដែលបានពណ៌នាមកនេះ មុខជានឹង បានមហាមគ្គគឺ សោតាបន្ន សកទាគាមិភាព, បានត្រជាក់កាយ សប្បាយចិត្តសះមុខរបួសជាដំបៅ គឺអនាគាមិភាព, បាត់ធ្ងន់តមមិន មមាំងតាំងតំនិត គឺអរហន្តភាព ។ បុគ្គលដែលប្រតិបត្តិដល់មកថ្នាក់ នេះហើយ បាននាមថា " ព្រះខីណាស្រព, ព្រះអសេក្ខបុគ្គលឬ ព្រះអរហន្ត ", បុគ្គលនោះឈ្មោះថា ញុំាងកិច្ចក្នុងព្រះពុទ្ធសាសនាឲ្យ ចប់ ព្រោះអស់កិច្ចដែលត្រូវបំពេញ ត្រូវប្រតិបត្តិដើម្បីអ្វីទៀតហើយ ; ធម៌ដែលលោកដល់ហើយនោះ ហៅថា អរហត្ត ដែលជាកំពូលនៃ សត្ថុសាសនធម៌របស់ព្រះបរមលោកនាថ, លុះដល់រលត់បញ្ចក្ខន្ធទៅ

អាចបញ្ចូនផលញាណ ដែលកើតអំពីវិបស្សនាយោគៈ (ព្យាយាមជាគ្រឿងប្រកបក្នុងវិបស្សនាញាណទាំង ១០ ណាមួយ) ទៅត្រង់នឹងយកបរមសុខដ៏ទៀងទាត់ឥតប្រែប្រួល ដែលហៅថា ព្រះនិព្វានៈនោះឯង ។

ហេតុនេះ សាធុជនគួរម្នីម្នាដណ្ដើមយកទមៈនោះ មកទុកក្នុងខ្លួនឲ្យបានរួសរាន់ឡើង ទាន់សម័យនៃជីវិតកំពុងមាននៅ ដែលទុកឲ្យជីវិតរលត់ផុតទៅហើយ គ្មាននរណាអាចប្រតិបត្តិជំនួសខ្លួនយើងបានឡើយ ។

សម្ដេចព្រះសក្យមុនីគោតមបរមសម្ពុទ្ធ ទ្រង់ត្រាស់បង្គាប់ឲ្យពុទ្ធបរិសទ្យបំពេញកិច្ចប្រតិបត្តិចំពោះទមធម៌នេះ ដោយគាថាភាសិតយ៉ាងនេះថា:

ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច
ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។

សេចក្ដីថា: អ្នកប្រាជ្ញគប្បីធ្វើទ្វីប: គឺព្រះនិព្វានដែលឱឃៈគ្របសង្កត់មិនបាន ដោយធម៌ ៤ ប្រការគឺ: ឧដ្ឋានៈ១, អប្បមាទៈ១, សញ្ញមៈ ១ ទមៈ ១ (តាមន័យដូចបានពណ៌នាមកហើយនេះឯង) ។

ធម្មទេសនា ដែលបានសំដែងអំពី ទមធម្មកថា កំល្មមសមគួរដល់កាលបរិច្ឆេទត្រឹមប៉ុណ្ណេះ ។

---

ឧដ្ឋានជនលោកទេសនា

ព្រះមហា ទៀ·ខាន់

សមាជិកក្រុមជំនុំ ប្រែព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

---

## នមោ ៣ ជើង

សូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រមទាំងព្រះធម៌និងព្រះសង្ឃ ដោយសេចក្ដីគោរព ។

បន្ទាប់ពីនេះ សូមសម្ដែង ព្រះធម៌ទេសនា ជាទូទៅតាមពុទ្ធសាសនៈ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ដើម្បីជាសវនានុត្តរិយានិសង្ស ដល់អស់លោកសាធុជន អ្នកប្រាថ្នាប្រយោជន៍ក្នុងការស្ដាប់ធម៌ទាំងឡាយ ដោយលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ យល់ឃើញអំណាចប្រយោជន៍នៃគម្ពីរព្រះត្រៃបិដក ដែលពុទ្ធសាសនបណ្ឌិត្យ បានបោះពុម្ពផ្សាយ ក្រោមការឧបត្ថម្ភរបស់ព្រះរាជរដ្ឋាភិបាល ហើយមានសេចក្ដីជ្រះថ្លា ប្រាថ្នាឲ្យអត្ថរសដ៏មានសារៈនៃគម្ពីរនេះ សាយភាយជ្រួតជ្រាបដល់សន្ដានចិត្តនៃសាធុជនទូទៅ ទើបបានអារាធនាព្រះសង្ឃក្រុមជំនុំប្រែព្រះត្រៃបិដក ឲ្យដកស្រង់អត្ថបទពីគម្ពីរនេះខ្លះៗ មកសំដែងផ្សាយតាមវិទ្យុជាតិ ។ ការប្រកាសផ្សាយគម្ពីរព្រះត្រៃបិដក ក៏ឈ្មោះថាប្រកាសផ្សាយនូវព្រះសទ្ធម្ម ឬព្រះពុទ្ធសាសនាទាំងមូល ព្រោះព្រះសទ្ធម្មដែលរាប់ថាជាសាសនធម៌ទាំងប៉ុន្មាន សុទ្ធតែមានមកក្នុងគម្ពីរ

ព្រះត្រៃបិដកទាំងអស់ ។ មែនពិតគម្ពីរព្រះត្រៃបិដកនេះ ជាគោលធារក នៃព្រះពុទ្ធសាសនា ជាឃ្លាំងឬជង្រុកផ្ទុកពេញដោយច្បាប់ដំបូន្មាន សីលធម៌ ទស្សនវិជ្ជានិងបរមត្ថវិជ្ជា ដ៏ជាពុទ្ធោវាទ មានជាន់ មានថ្នាក់ ពីរាក់ទៅជ្រៅ តាមលំដាប់សម្រាប់ដឹកនាំមនុស្សលោកឲ្យរីសេសរុងរឿង និងសុខសន្តិភាព គឺឲ្យបានសម្រេចសម្បត្តិមនុស្ស សម្បត្តិទេវតា សម្បត្តិព្រះនិព្វាន ។ អ្នកណាមានគម្ពីរព្រះត្រៃបិដកនេះ ទុកដូចជាមានឃ្លាំងនៃត្រៃពិធសម្បត្តិ កាលបើខំស្វាហ៍អាន ខំស្វាហ៍សិក្សា និងប្រតិបត្តិតាម ក៏អាចនាំយកគុណប្រយោជន៍អំពីគម្ពីរនេះមិនមានទីបំផុត ។ ពុំនោះសោត អ្នកដែលមានគម្ពីរព្រះត្រៃបិដកនេះ ដំកល់ទុកជាធម្មសម្បត្តិហើយ ទុកដូចជាបានតួអង្គព្រះសម្ពុទ្ធនិងអរិយសាវក មកគង់ក្នុងទីចំពោះមុខ កាលបានអាន បានសិក្សា ដូចជាបានព្រះអង្គមកសំដែងធម៌ប្រោសដូច្នោះដែរ ។ ម្យ៉ាងទៀតគម្ពីរព្រះត្រៃបិដកខ្មែរយើងនេះ លោកបានរៀបរៀងជាបាលីម្ខាង ជាសេចក្ដីប្រែម្ខាងប្រៀបដូចជាដួងប្រទីបពីរដួង លោកដាក់ទន្ទឹមគ្នា សម្រាប់បំភ្លឺផ្លូវមនុស្សលោកឲ្យដើរទៅរកសេចក្ដីសុខសួស្ដីតាមសេចក្ដីប្រាថ្នា ឬតាមនិស្ស័យវាសនារបស់ខ្លួន ។

ដូច្នេះ សូមលើកយកពុទ្ធភាសិតមួយអន្លើ ដែលទ្រង់ព្យាករដោះបញ្ហាអាឡវកយក្ស សំដែងមានមកក្នុងគម្ពីរព្រះត្រៃបិដក ត្រង់សំយុត្តនិកាយ សគាថវគ្គមកសម្ដែងដូចតទៅនេះ :

យក្ខទូលសួរព្រះអង្គថា:

កថំសុ វិន្ទតេ ធនំ បុគ្គលធ្វើដូចម្តេចទើបបានទ្រព្យ ?

ព្រះអង្គត្រាស់តបថា បដិរូបការី ធុរវា ឧដ្ឋាតា វិន្ទតេ ធនំ បុគ្គលព្យាយាមធ្វើការងារតាមសមគួរ មិនលះធុរៈ រមែងបានទ្រព្យ ។

ព្រះពុទ្ធភាសិតនេះទ្រង់សម្តែងបញ្ជាក់ថា ព្យាយាមជាហេតុ មានទ្រព្យជាផល ។ តែមុននឹងសម្តែងពីសេចក្តីព្យាយាម សូមសម្តែងពីប្រភេទនៃទ្រព្យ និងគុណភាពរបស់ទ្រព្យឲ្យឃើញជាមុនសិន ។

ទ្រព្យ គឺរបស់របរឬគ្រឿងប្រកបឲ្យសម្រេចផល គឺធ្វើអ្នកមានទ្រព្យ ឲ្យស្រួលកាយ ទូលាយគំនិត ឲ្យបានសេចក្តីសុខសម្រាន្ត ច្រើនឬតិច ស្រេចហើយតែនឹងចំនួនឬកម្លាំងទ្រព្យដែលមាន ។ ទ្រព្យនោះមានច្រើនប្រភេទ តែលោកចែកដោយខ្លីមាន ២ គឺ: ពាហិរទ្រព្យ ១ អជ្ឈត្តិកទ្រព្យ ១ ។

១- ពាហិរទ្រព្យ ទ្រព្យខាងក្រៅ ចែកចេញជា២គឺ សំហារិមទ្រព្យ បានដល់របស់ដែលអាចធ្វើឲ្យឃ្លាតចាកទីដើមទៅបាន ដូចយន្តយាន ពាហនៈ ប្រាក់ មាស គ្រឿងឧបភោគ-បរិភោគជាដើម១, អសំហារិមទ្រព្យ បានដល់របស់ដែលមិនអាចឲ្យឃ្លាតចាកទីបាន ដូចដីធ្លី ទីភូមិ ស្រែចំការ ផ្ទះសំបែងជាដើម ១ ។ បណ្តាទ្រព្យទាំងពីរនេះ ចែកចេញជាពីរទៀតគឺ ទ្រព្យដែលចាំបាច់១ ទ្រព្យដែលមិនសូវចាំបាច់ ១ ។

របស់ណាបើទុកជាមិនមាន ក៏មិនដល់ទៅជាកើតសេចក្ដីទុក្ខលំបាកក្ដៅ
ក្រហាយ ដូចគ្រឿងប្រដាប់សម្រាប់តែងកាយឲ្យហ៊ឺហា ឬគ្រឿងតាំង
គ្រឿងតែងគេហដ្ឋានខ្លះ ដែលលើសពីសេចក្ដីត្រូវការ នេះហៅថា
ទ្រព្យមិនសូវចាំបាច់ ។ របស់ណាដែលខ្វះមិនបាន ដូចភោជនាហារ
សំលៀកបំពាក់ទីនៅអាស្រ័យនិងថ្នាំកែរោគ ព្រមទាំងគ្រឿងឧបករណ៍
ដែលជាជំនួយដល់ការរស់នៅ និងគ្រឿងការពារភ័យអន្តរាយ ដើម្បីឲ្យ
បានសុខសម្រាន្ត ទាំងនេះជាទ្រព្យចាំបាច់ ជារបស់គួរស្វែងរក ។

២- អជ្ឈត្តិកទ្រព្យ ទ្រព្យខាងក្នុងមានពីរគឺ អត្ថសមនិធិ
ទ្រព្យដែលឲ្យផលដល់ខ្លួនដរាបដល់អស់ជីវិត ឬទ្រព្យដែលអាស្រ័យបាន
ក្នុងវេលាមានអាយុៈពេញបរិបូណ៌ ១, អនុគាមិកនិធិ ទ្រព្យដែល
ផ្ដល់ផលពិសេសដល់ខ្លួន ទាំងក្នុងបច្ចុប្បន្នទាំងក្នុងលោកខាងមុខ ១ ។

បណ្ដាទ្រព្យខាងក្នុងទាំងពីរយ៉ាងនេះ, ចំណេះវិជ្ជាផ្សេងៗ ដែលជា
សម្បត្តិជិតជាប់នឹងខ្លួន ធ្វើឲ្យអ្នកដែលបានហាត់រៀនមក មានសេចក្ដីចេះ
ដឹង មានគំនិតនឹងមានសេចក្ដីអង់អាចជាងកាលដែលមិនទាន់បានហាត់
រៀនជាដើម ចេះសរសេរ ចេះអាន ចេះចាត់ចែង ចេះធ្វើកិច្ចការទាំង
ពួង យ៉ាងតាមបែបតាំងពីកិច្ចការក្នុងគ្រួសារឡើងទៅ ត្រូវចាត់ចែង ត្រូវ
ធ្វើយ៉ាងណាៗ ដើម្បីឲ្យបុះរបៀប មិនទំនាស់នឹងអនាម័យ ឬតាមសម័យ
និយម ចេះសិល្បៈប្រការខ្លះ ដូចការជាង ការឈ្មួញ និងហត្ថកម្ម ឬវិជ្ជាជីវៈ

ដទៃ ៗ មានចេះរបៀបធ្វើស្រែចំការជាដើម ចេះទំនៀមទម្លាប់ប្រពៃណី ចេះប្រាស្រ័យសន្ទនា ក្នុងវេលាដែលខ្លួនត្រូវទាក់ទងនឹងប្រជុំជន ក្នុងសម័យនោះ ៗ រហូតដល់ចេះច្បាប់ទម្លាប់ ឬវិជ្ជាជាន់ខ្ពស់ផ្សេងៗទៀត នេះហៅថា អត្ថសមិទ្ធិ ទ្រព្យដែលជិតជាប់នឹងខ្លួន ៗ

ចំណែកការប្រតិបត្តិល្អ ដែលហៅថា បុណ្យកុសលគ្រប់ប្រការ ដូចទាន-ការបរិច្ចាគទ្រព្យរបស់ខ្លួនឲ្យដល់អ្នកដទៃ ដោយចេតនាអនុគ្រោះ ឬបូជាគុណ ឬប្រាថ្នាសាធារណប្រយោជន៍ ដូចសាងសាលារៀន មន្ទីរពេទ្យព្យាបាលរោគ សាងថ្នល់ សាងស្ពាន សម្រាប់ការចរាចរ ជីកអណ្តូង ជីកស្រះ សម្រាប់ប្រជាជនអាស្រ័យ និងឧបត្ថម្ភព្រះពុទ្ធសាសនា មានសាងកុដិវិហារសាលាជាដើម សម្រាប់បណ្តុះផ្សាយសេចក្តីល្អ ដល់ពួកកុលបុត្តទូទៅ, សីល ការតាំងចិត្តបង្រួម ការពារមិនឲ្យទោសទុច្ចរិតកើតឡើងបាន មានកាយកម្ម វចីកម្ម មនោកម្ម ប្រកបដោយមេត្តាករុណាចំពោះសត្វទាំងពួង និងភាវនា គឺការអប់រំបន្ទំចិត្ត ដោយការនឹកគិតពិចារណានូវអំពើល្អដែលខ្លួនបានសាងសន្សំមកហើយ ដើម្បីធ្វើចិត្តឲ្យជ្រះថ្លា ឲ្យគួរដល់ការទានកម្ម ឲ្យជាចិត្តរីករាយក្លាហានក្នុងគុណធម៌នោះៗ ឲ្យជាចិត្តថ្លាស្អាតប្រាសចាកមន្ទិលគ្រឿងសៅហ្មងផ្សេងៗ ជាឧបាយឲ្យកើតបញ្ញាថ្លាសម្រាប់មើលឃើញសភាវៈពិត ពោលដោយឈ្មោះថា

ទាន សីល ភាវនា នេះហៅថា អនុគាមិកនិធិ ទ្រព្យដែលជាប់តាមខ្លួន ដូចស្រមោលអន្ទោលតាមប្រាណ ។

កាលបានជ្រាបប្រភេទនៃទ្រព្យផ្សេងៗ ដូចសម្ដែងមកដោយសង្ខេបនេះ ក៏ឃើញបានថា ទ្រព្យទាំងអស់នោះ សុទ្ធតែគួរប្រាថ្នាគួរស្វែងរក ព្រោះពួកលោកពោលសរសើរទ្រព្យទុកថា :

ន រូបំ ន ច បញ្ញាណំ ន ច កុលញ្ច សម្ភវោ
កាលវិបត្តិសម្បត្តេ ធនមេវ វិសេសកំ

កាលគ្រាវិបត្តិ គឺគ្រោះថ្នាក់មកដល់ហើយ រាងកាយក៏ជួយមិនបាន កេរ្តិ៍ឈ្មោះពីរោះល្បីល្បាញក៏ជួយមិនបាន ទាំងត្រកូលវង្សផៅសន្តាន ក៏ជួយមិនបាន មានតែទ្រព្យប៉ុណ្ណោះទេ ទើបជារបស់វិសេសអាចជួយរំដោះគ្រោះវិបត្តិនោះបាន

ធនហីនំ ចជេ មិត្តា បុត្តទារា សហោទរា
ធនវន្តា សោភន្តិ ធនំ លោកេ មហាសខា ។

មនុស្សសូន្យទ្រព្យ មិត្តទាំងឡាយ ក៏គង់លះបង់ចោល បុត្តភរិយា ទឹងបងប្អូនបង្កើត ក៏គង់លះបង់ចោលបាន មានតែអ្នកមានទ្រព្យទើបល្អរុងរឿង ព្រោះទ្រព្យរាប់ថាជាសំឡាញ់ធំក្នុងលោក ។

ប៉ុន្តែ បុគ្គលដែលនឹងស្វែងរកទ្រព្យបាននោះ លោកពោលថាត្រូវអាស្រ័យសេចក្ដីព្យាយាមជាបច្ច័យ ឬ ជាមូលហេតុ បានដល់ការខំយកចិត្ត

ទុកដាក់ ខំប្រឹងប្រែងស្វែងរក គឺខំធ្វើ ខំប្រកបឲ្យពេញកម្លាំង ឲ្យសមគួរ តាមនាទី តាមទំនង តាមសម័យកាល មិនធ្វើដោយខ្ជិល មិនដំអក់ទម្រន់ ឬលះធុរៈដោយការហេតុការណ៍ផ្សេង ៗ ពេះរកឧបាយ ជំនះនូវឧបសគ្គ ទាំងពួង មិនការលេសថា ត្រជាក់ណាស់ ក្តៅណាស់ជាដើម ដែលជាហេតុឲ្យខ្ជិលច្រអូសមិនប្រកបការងារ ។ តែបើមានសេចក្តីខ្ជិលច្រអូសក្តី មិនស្គាល់ប្រភេទព្រមទាំងគុណប្រយោជន៍នៃទ្រព្យក្តី ជាអ្នកធ្ងន់ទៅក្នុងរឿងអបាយមុខ ជាប់ជំពាក់ចិត្តទៅក្នុងអបាយមុខនោះ ៗ ក្តី ពលកាយមានរោគាពាធបៀតបៀនកុំកែក្តី ទាំងនេះក៏ជាឧបសគ្គពំនឹក មិនឲ្យព្យាយាមស្វែងរកទ្រព្យកើត ។ ព្រោះហេតុនោះ ត្រូវជាអ្នកសម្បូណ៌ដោយឧបាយកំចាត់បង់ ឬការពារខ្លួន ឲ្យផុតចាកភ័យអន្តរាយនោះ ៗ គ្រប់ប្រការ ទាំងត្រូវស្គាល់តម្លៃ ស្គាល់គុណប្រយោជន៍របស់ទ្រព្យ តាមចំណែកតាមប្រភេទ ដែលជាហេតុជាស់តឿនក្រើនរំលឹកទឹកចិត្តឲ្យប្រញាប់ខំប្រឹងស្វែងរក ។ ក្នុងការព្យាយាមស្វែងរកទ្រព្យនោះ គប្បីចាំហើយរលឹករឿយ ៗ ដល់សុភាសិតថា

ភោគេ សំហរមានស្ស ភមរស្សេវ ឥរីយតោ
ភោគា សន្និចយំ យន្តិ វម្មិកោវុបចីយតិ

កាលស្វែងរកភោគទ្រព្យ គប្បីជាអ្នកយកគំរូយ៉ាងសត្វឃ្មុំ ភោគទ្រព្យទើបដល់នូវការពេញពូន ដូចដំបូកដែលកណ្តៀរពូនឡើងដូច្នោះ ៗ

អប្បកោនបិ មេធាវី ចាភតេន វិចក្ខណោ
សមុដ្ឋាបេតិ អត្តានំ អណុំ អគ្គឹវ សន្ធមំ

អ្នកមានប្រាជ្ញាចេះគិតវៃលក រមែងតាំងខ្លួនបានដោយទ្រព្យជាដើមទុន ទោះបន្តិចបន្តួច ដូចគេបង្កាត់ភ្លើងដ៏តូច ឲ្យជាគំនរភ្លើងដ៏ធំឡើងបានដូច្នោះ ។

សុភាសិតទាំងពីរបទនេះ ជាគ្រឿងសម្ដែងវិធីស្វែងរក វិធីថែទាំរក្សា ព្រមទាំងវិធីបរិភោគប្រើប្រាស់ទ្រព្យសម្បត្តិឲ្យល្មមប្រមាណ ។

ទ្រព្យជាមូលហេតុ ឬជាបច្ច័យនៃសេចក្ដីរុងរឿងគ្រប់យ៉ាង គប្បីពិនិត្យ ផលរបស់ដែលបានឃើញចំពោះមុខទាំងឡាយ ដូចគ្រឿងសំណង់និងរបស់ប្រើប្រាស់ សម្រាប់សេចក្ដីស្រួលសប្បាយនៃខ្លួន និងមនុស្សដទៃៗ រហូតដល់អ្នកដែលចំរើនស្ដុកស្ដម្ភក្នុងសម័យបច្ចុប្បន្ននេះ ក៏ឃើញបានថា ទាំងអស់នោះ សុទ្ធតែត្រូវអាស្រ័យទ្រព្យជាកម្លាំងយ៉ាងខ្ពង់ខ្ពស់ បើខ្វះទ្រព្យហើយ សូម្បីមានគំនិតត្រូវល្អយ៉ាងណាក៏ដោយ ក៏កម្រនឹងធ្វើឲ្យកិច្ចការនោះៗ សម្រេចទូលំទូលាយទៅបាន ។ មនុស្សគ្មានទ្រព្យ ទើបជាមនុស្សទាល់គំនិត ចូលក្នុងបទថា ខ្វះទ្រព្យអាប់បញ្ញា ។ ព្រោះហេតុនោះ សាធុជនគួរជាអ្នកខំប្រឹងប្រែងស្វែងរកទ្រព្យ

ទាំងខាងក្រៅ ទាំងខាងក្នុង ដែលជាគ្រឿងបំបាត់សេចក្តីទ័លក្រ ទាំងជាហេតុ ឲ្យបានសេចក្តីសុខចំរើន ក្នុងបច្ចុប្បន្នទាំងអនាគត ដល់ខ្លួនទាំងអ្នកដទៃ តាមន័យព្រះពុទ្ធភាសិត ដែលបានលើកតាំងខាងដើមនោះ កុំបីភាន់ខានឡើយ ។

មុននឹងបញ្ចប់នូវព្រះធម៌ទេសនានេះ សូមថ្វាយព្រះរាជកុសលចំពោះព្រះករុណាជាអម្ចាស់ជីវិតទាំងពីរព្រះអង្គ និងសម្តេចព្រះឧបយុវរាជ សូមទ្រង់គង់នៅក្នុងសិរីរាជសម្បត្តិ ប្រកបដោយព្រះបរមសុខជានិរន្តរ៍ ដើម្បីជាទីពឹងនៃជាតិ ទាំងជាគ្រឹះនៃព្រះពុទ្ធសាសនាអស់កាលជាអង្វែងតទៅ ។

សោត្ថឹ បប្បោន្តុ សោត្ថាភោ សាធវោ ពុទ្ធមាមកា

សូមសាធុជនពុទ្ធមាមកៈអ្នកតាំងចិត្តស្តាប់ទាំងឡាយ បានដល់នូវសិរីសួស្តី គឺសេចក្តីសុខ សេចក្តីចំរើន កុំបីឃ្លៀងឃ្លាតឡើយ ។

អយំ ធម្មទេសនា សង្ខេបេន សមត្តា ព្រះធម៌ទេសនាដែលបានសម្តែងមកនេះ សន្មតថាចប់ដោយសង្ខេប ត្រឹមប៉ុណ្ណោះឯង ។

# សុរពជាតក

(តមក)

លោក ចង-វង បម្រួងពីសាស្ត្រស្លឹករឹត

---

ទើបផ្ដាំអ្នកយាមទ្វារថា បើឃើញបុរសស្លៀកខ្មៅ ដណ្ដប់ខ្មៅចូលមក អ្នកកុំឃាត់ឡើយ ឲ្យចូលមកចុះ, លុះផ្ដាំស្រេចហើយ ក៏ចូលទៅក្នុងព្រះរាជវាំង ៗ កាលនោះ ព្រះរាជាដាក់ដងសន្ទូចរត់ទៅពុំទាន់ ដល់ទៅព្រះរាជវាំងជាខាងក្រោយ ស្ដេចដេញតាមទៅក្នុងព្រះរាជវាំង ៗ ឯពួកអមាត្យមានសេនាបតីជាដើមគិតថា អយំ ចោរោ អានេះជាចោរវាយកដិមកម្ដារព្រះមហាក្សត្រ ប្រដាប់ខ្លួនវា ទើបព្រះមហាក្សត្រទ្រង់ព្រះពស្ត្រខ្មៅ យាងចូលមកតាមក្រោយប្រុងចាប់អាចោរនេះ ៗ គ្រានោះព្រះរាជកុមារស្ទុះចូលទៅក្រាបទៀបព្រះបាទានៃព្រះមហាក្សត្រ ហើយក្រាបទូលថា អហាន្ត បុត្តោ តច្ចាមិ បពិត្រក្សត្រថ្លៃប្រសើរអើយ! ទូលព្រះបង្គំជាព្រះរាជបុត្ររបស់ព្រះអង្គ ៗ សម្ដេចព្រះមហាក្សត្រាធិរាជព្រះអង្គពុំជឿ ទើបត្រាស់ថា ហៃចោរ! អ្នកថាខ្លួនអ្នកជាកូនអញ ៗ ពុំជឿឡើយ ៗ ព្រះរាជកុមារក្រាបបង្គំទូលថា ទូលព្រះបង្គំនេះ ជាកូននាងនគរសោភិនី នៅនគរឈ្មោះឯណោះ ព្រះអង្គជាព្រះបិតានៃទូលព្រះបង្គំពិតប្រាកដ បើព្រះអង្គពុំជឿ សូមព្រះអង្គទតចិញ្ចៀនព្រះទំរង់នេះចុះ មម មាតុយា ព្រះអង្គបានព្រះរាជទានដល់មាតារបស់ទូល

ព្រះបង្គំ ហើយមាតារបស់ទូលព្រះបង្គំប្រាប់ទៀតថា ព្រះវរបិតារបស់បាឯង គឺព្រះបាទសញ្ជ័យជាជីតាជ, ដូច្នោះ ទើបទូលព្រះបង្គំមានចិត្តគិតថា ធ្វើដូចម្ដេចទើបឃើញព្រះអង្គជាព្រះវរបិតា, ទើបលាមាតាមក, មាតាបានឲ្យព្រះទំរង់នេះជាបន្ទាល់ ។ ព្រះរាជាទ្រង់ទតទៅព្រះទំរង់ហើយស្គាល់ ទើបត្រាស់នឹងសេនាបតីថា ម្នាលសេនាបតី! អ្នកចូរពិនិត្យមើលព្រះទំរង់នេះប្រាកដជារបស់អញ ឬមិនមែនទេ? ។ សេនាបតីក៏យកព្រះទំរង់នោះមកពិនិត្យមើលដោយសព្វគ្រប់, ស្គាល់ជាក់ជាព្រះទំរង់នៃព្រះមហាក្សត្រខ្លួន ទើបក្រាបបង្គំទូលថា បពិត្រក្សត្រថ្លៃប្រសើរអើយ! ព្រះទំរង់នេះ ប្រាកដជាព្រះទំរង់របស់ព្រះអង្គ. ឯព្រះរាជបុត្រនេះ ក៏ប្រាកដជាព្រះរាជបុត្ររបស់ព្រះអង្គដែរ ។ ទើបស្ដេចត្រាស់ថា ម្នាលបា! ហេតុអ្វីក៏អ្នកមិនមកដោយត្រង់ អ្នកធ្វើជាចោរដូច្នោះ? ។ បពិត្រព្រះវរបិតា អម្បាំ ឧដុំគាំ អាគតោ ថាបើទូលព្រះបង្គំមកដោយត្រង់ ធ្វើម្ដេចនឹងបានចូលមកដល់ព្រះអង្គ, ត្បិតទូលព្រះបង្គំជាអ្នកកំសត់ទុគ៌ត ឧបារុតោ សំពត់ដណ្ដប់ក៏ដាច់រយីករយាក ឧនិវត្ថោ សំពត់ស្លៀកក៏ដាច់ដាចច្រើនបំណះណាស់ ព្រោះដើរដោយផ្លូវឆ្ងាយក្រនឹងមកដល់; ប្រការមួយទៀត អស់មនុស្សទាំងឡាយក៏គេមិនស្គាល់ថា ទូលព្រះបង្គំជាព្រះរាជបុត្រនៃព្រះអង្គដែរ ទូលព្រះបង្គំស្វះស្វែងមករកព្រះអង្គដោយការលំបាកពន់ពេកណាស់ ថាបើវិបំពារ

ចូលមក អ្នកនាំចោរនឹងសេនាមាត្យទាំងពួង គេនឹងផាក់កាត់ក្បាលទូល ព្រះបង្គំ ហើយណាគេនឹងមកក្រាបទូលព្រះអង្គ, ទូលព្រះបង្គំគិតដូច្នេះ ហើយទូលព្រះបង្គំធ្វើជាចោរ, ការឧបាយគសង្គ្រោះទាំងម៉្លេះនេះ ប្រាថ្នានឹងសំដែងអានុភាពតាមខត្តិយជាតិតែម្យ៉ាង, ឯទ្រព្យសម្បត្តិដែលទូលព្រះបង្គំយកទៅទុកកន្លែងណា ៗ សូមព្រះអង្គបាវគេឹប្រាប់អស់អ្នកនគរថា របស់ទ្រព្យណា ៗ ដែលចោរលួចយកទៅ ចូរអ្នកជាម្ចាស់ទ្រព្យទៅយកនៅទីឯណេះ ៗ វិញហោង ។ ព្រះរាជាបានជ្រាបហើយមានព្រះរាជហឫទ័យត្រេកអរឥតឧបមា ត្រាស់ប្រើអមាត្យឲ្យទៅវាយគងប្រាប់អស់អ្នកនគរដូចព្រះរាជកុមារក្រាបទូល ។ អមាត្យក៏បាវគេឹប្រាប់អស់អ្នកនគរឲ្យទៅយកទ្រព្យរបស់ខ្លួន ៗ ។ កាលនោះព្រះបាទវេទ្ធមានដ៏តកដស្ដេចតាំងព្រះរាជកុមារជាឧបរាជ ។

ឥតិ សា បណ្ឌិតា ទេវី រីនាងបណ្ឌិតៈទេវី ជាស្ដ្រីឈ្លាសវៃនាងនិទានរឿងទាំងឡាយ តាំងពីបឋមយាមរហូតដល់យាម ៤ ក៏ ឈប់ចប់ ។ រីព្រះបាទចន្ទរាជដែលមានព្រះរាជហឫទ័យកាចសាហាវ មុទុ. ភោ ចិត្តោ ព្រះអង្គមានព្រះរាជហឫទ័យទន់ ហើយអភិសេកនាងបណ្ឌិតៈទេវីនុះ ជាមហេសី ។ តតោ បដ្ឋាយ ចាប់ដើមតាំងពីថ្ងៃនោះមក ព្រះចៅចន្ទរាជក៏ឋិតនៅកងឧក្ខទៃនអគ្គមហេសី ទ្រង់រក្សាទសពិធរាជធម៌ ពុំឲ្យអ្នកនគរមានចលាចលឡើយ មិនត្រឹមតែប៉ុណ្ណោះ

ព្រះអង្គទ្រង់សង្គ្រោះគណកប្រជានុរាស្ត្រដោយសង្គហធម៌៤យ៉ាង, ទ្រង់មានព្រះរាជហឫទ័យជ្រះថ្លាឲ្យទានរក្សាសីល លុះសោយទិវង្គតទៅបានទៅកើតឯស្ថានសួគ៌ទេវលោកនាយហោង ។

ឥតិ សុវេទោ ពោធិសត្តោ ទានំ ទត្វា អាហារេត្វា ឯព្រះសុវេទពោធិសត្វ ទ្រង់បានទាំទាហណ៍នឹងទិចានផ្សេងៗ ដូច្នេះ ដើម្បីដោះសាក្តីព្រះគាថាថា អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា, បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមន្តិ ប្រែជាសេចក្តីថា អសេវនា ច ពាលានំ គុំបានសេពគប់នឹងមនុស្សពាល១, បណ្ឌិតានញ្ច សេវនា ឲសេពគប់នឹងអ្នកប្រាជ្ញ១, បូជា ច បូជនីយានំ គួរបូជាចំពោះបងប្អូនជីដូនជីតា សមណព្រាហ្មណ៍នឹងព្រះរតនៈទាំង៣ ដែលគួរបូជា ១, ឯតំ វីធម៌ទាំង៣នេះ ឧត្តមំ ជាមង្គលប្រសើរ ពុំដឹងបើនឹងគណនាបាន ។

រីឯបុរសទាំងពីរ (បុរសពុទ្ធកុកនឹងបុរសល្មោភចង់បានកុក) លុះបានស្តាប់ព្រះធម៌វិសេសទេសនានៃព្រះបរមពោធិសត្វហើយ មានចិត្តពោរទន់លះបង់ផុសេវ៉ា ថ្វាយបង្គំលាព្រះបរមពោធិសត្វទៅកាន់ផ្ទះអាត្មាទីទៃៗហោង ។

កាលនោះ ព្រះបរមពោធិសត្វ ទ្រង់លីលាចេញពីសាលានោះ ត្រោះទៅដល់នគរមួយនៅទិសទក្សិណ ចេញពីនោះទៅដល់ស្រុកមួយទៀត

ឈ្មោះ តក្កលិគ្រាម, មានអាវាមមួយឈ្មោះ អម្ពលដ្ឋិកង ។ នៅក្នុងស្រុកនោះ មានកុដុម្ពិកម្នាក់ឈ្មោះ សុចិ ជាអ្នកចាំថែទាំទំនងជា មគ្គនាយកក្នុងអាវាមនេះ ។ ឯអាវាមនោះមានសមណៈ ១ អង្គ ព្រះនាម សុទត្តសមណៈ ។

ឯកស្មឹំ កាលេ ពេលមួយ ព្រះសុទត្តសមណៈ ចង់ទៅសួរញាតិកានៅភូមិឆ្ងាយ ទើបហៅសុចិកុដុម្ពិកនោះមកផ្តាំថា អម្ភោ ឧបាសក ហៃឧបាសកដ៏ចំរើន ! ឥឡូវអាត្មាចង់ទៅភូមិឆ្ងាយ ដើម្បីនឹងទៅសួរញាតិកៈនៃអាត្មា ចូរអ្នកយកហិបនេះទៅទុកក្នុងផ្ទះនៃអ្នកផងចុះ ទំរាំអាត្មាវិលមកវិញ ។ កុដុម្ពិកនោះសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់បានដាក់អ្វីខ្លះក្នុងហិបនេះ ។ អាត្មាដាក់ថ្នាំឫសឈើសម្បកនិងខ្ទឹមឈើ ។ ទើបកុដុម្ពិកទទួលថាសាធុៗ ហើយពុំបានបើកមើលហិបនោះឡើយ លីយកទៅទុកក្នុងផ្ទះ ។ ប៉ុន្តែហិបនោះចៅអាវាសដាក់ថង់មាស ១ សែនដំឡឹងខាងក្រោម យកសម្បក-ឫស-ខ្ទឹមឈើដាក់ខាងលើ ។ ឯសុចិកុដុម្ពិក លុះលីហិបទៅ នឹកសង្ស័យថា ទ្រព្យអ្វីហ្ន៎! នៅក្នុងហិបនេះធ្ងន់ម្ល៉េះ ! ទើបបើកហិបរើសម្បក - ឫស - ខ្ទឹមឈើចេញ ឃើញមាស ១ សែនដំឡឹងគិតថា ព្រះភិក្ខុពុំបានប្រាប់អញៗ នឹងយកមាសនេះទុក ព្រះភិក្ខុនេះពារយកវិញប្តូរទេ » គិតដូច្នោះហើយក៏យកមាសទុកខាងក្រៅ ដាក់ទង់ដែងជំនួស រួចយកសម្បក-ឫស-ខ្ទឹមឈើមកដាក់ដូចដើមវិញ ។

(មានត)

## ផ្នែកអក្សរសាស្ត្រ

# រឿងហង្សយន្ត

( តមក )

លោក អ៊ុំ-ភន ចម្លងពីសាស្ត្រាស្លឹករឹត

ភាចន៍ចូលចិត្ត ព្រមទាំងមហាក្សត្រ ឥតឧមិតោកក្រៃ ទើបតុទ្ធន័រ បន្ទូលថាថៃ អស់គ្នាទាំ វិលទៅម្នា ៗ ទៅប្រាប់មហាក្សត្រ ឥតធមិះក្រៅក្រិត្យ ជាអម្ចាស់រ៉ា ថាអញទាំងឮាន ទៅថ្កានគាត ស្រុកអញនាយណា ថ្ងៃនេះជាមួន ៗ ពេជ្ឈឃាដស្ដែងស្ដាប់ ស្ដេចបន្ទូលប្រាប់ ហើយធ្វើយរឹងស្នួន ថាអាកុំអួត ប្រកួតប្រឡង ចូរអាវិងផ្គនចុះមកវិញណា ៗ ប៉េយើងទាំងទាំ យកគ្នារំលំ ទូរដើមព្រឹក្សា ជួលចុះដល់ដី សូម្បីអាត្មា មិនក្សៀយឯងណា ពុំលន់ឡើងហោង ៗ ទើបស្ដេចត្រាស់ថា ទៃម្នាលអស់អា ពេជ្ឈឃាដទ្រស្ដយួន ចូរមិនក្រឡាប់វិលធាប់ទៅផ្គន កុំព្រួយមិនហោង ចាំអញឡើយណា ៗ ក្សិណនោះព្រះបាទ សម្ដេចនរោត្ត ធិកជេស្ដា ស្ដែងស្ដេចឡើងគន់ ឈើហង្សយន្តណា ហោះដោយវេហាស៍ ក្រោងព្រោយរស្មី ៗ ឯអស់ពេជ្ឈឃាដ យន់យល់ព្រះបាទ ហោះដោយនភ៍ ភិតភ័យខ្ញុំបន្ទាប

អំណាចបារមី ក្រញូក្រាបអភិ- វាទវរវន្ទា ៗ ស្រែកថ្វាយសព្ទសា-ធុការ
ព្រះបាទ សពេជ្ញសាស្តា ថាព្រះអង្គ ទ្រង់បារមីតា សូមទានករុណា
ប្រោសយើងខ្ញុំផង ៗ អស់ទាំងពេជ្ឈឃាដ សឹងថ្វាយសព្ទសា-ធុការ
អឹងកង ស្រេចហើយក្រឡាប់ វិលធាប់មកផ្គង ដល់ក្បាលហើយហាង
ក្រញូក្រាបទូលថា ៗ បពិត្រព្រះបាទ ត្រៃត្រកូវនាថ ឥស្សរស-
រសា សូមទានព្រះអង្គ ស្ដេចទ្រង់ក្រោធា ប្រោះខ្ញុំករុណា ខ្ញុំអស់
គ្នាផង ៗ នាំអ្នកទោសទៅ បណ្ដើរសំដៅ ដល់ព្រៃហើយហាង
ទើបអស់យើងខ្ញុំ ហោមជុំជាមួន ដោយចិត្តប៉ុនប៉ង មិនមានប្រណី ៗ
យើងខ្ញុំស្រេចស្រាប់ លើកដាវនឹងកាប់ ឲ្យក្ស័យជីវ៍ តាប់មានបក្សា
មហិមារឹទ្ធិ ធៀនឆាបឆក់ពី យើងខ្ញុំទៅហោង ៗ ក្សណនោះព្រះបាទ
លុះឮពេជ្ឈឃាដ ទូលដូច្នោះហោង ព្រួយព្រះហឫទ័យ ភិតភ័យ
កន្ទុំ ទុអញ្ញនេះមួន ឥតការទោសណា ៗ ឲ្យទៅសម្លាប់ ឥឡូវមិនស្លាប់
មកមានទោសា បក្សាឆាបពាំ នាំយាត្រា ហោះដោយវេហាស៍
ប្រាកដគួរស្មែន ៗ ម៉្លេះហើយសមនឹង ក្រឡាប់វិលវិញ មកវិញមិនលែង
ដៀតបានបក្សា មហិមាអះអែង ម៉្លេះហើយគេកែង នឹងធ្វើទោសា ៗ
អញអើយថាបើ គេមកគេធ្វើ ដោយចិត្តក្រោធា ឯខ្លួនអញនេះ ពាស
ម៉្លេះហើយណា សមក្ស័យជន្មា ពិតពុំលង់ឡើយ ៗ ព្រះទៅបញ្ចាល់
ទ្រង់ព្រះចិន្ដា អម្បាលនោះហើយ ភិតឯងពេកស្រាល់ ខ្លួនញ័រលំឥត

សៀយ ទើបក្សត្រត្រាណត្រើយ ទំបន្ទូលថា ៗ ប្រាប់ប្រើបុត្រី ប្រសើរស្រស់ស្រី ស្រីគេធ៌ចីតា ឲ្យវិលទៅថ្កាន បិតឋានប្រាង្គប្រា- សាទ សួគិមហិមា ពិតពុំលង់ឡើយ ៗ ឯនាងបទុម- គេសរទត្តម ក្សត្រី ត្រាណត្រើយ នាងក្ខស្វាមី រួចពីក្តីហើយ នាងនាថបុានសៀយ ទុក្ខ ពោមនស្ស ៗ ទើបនាងកល្យាណ វិលវិងទៅថ្កាន ប្រាសាទនាងណា ហើយនាងគង់នៅ នាព្រះគៅតា មើលផ្លូវព្រះមហា ពន្ទុកថ្ងៃ ៗ

បទព្រហ្មគីត

ទេះទីដីថ្ងៃដ៏ស្រដី ដំណើរពីព្រះចមក្រៃ ស្តេចគង់យន្តមាសថៃ ហោះត្រាប់តអណ្តែតដល់ៗ ប្រាសាទប្រសើរបាន កដពិមានគេទម្នល នាងនាថស្រីសួគិសល់ ទតយង់យល់ព្រះកថា ៗ នាងមានព្រះហឫទ័យ ស្រីគេទថ្ងៃសោមនស្ស អគេតឯតណនា ទីដីថ្ងៃដ៏ថ្ងៃពុំបានឡើយ ៗ ក្បៀណនោះឯព្រះបាទ ដល់ប្រាសាទប្រសើរហើយ ព្រះអង្គពុំបង់ឡើយ ស្តេចចុះចាកយន្តមាសថៃ ៗ ស្តេចថ្នមព្រះប្អូនស្រី អគ្គមហេសីដាក់ដល់ញ ទការគេទប្រពៃ ពីរពន្ធក្សត្រពិលាបលន់ ៗ ព្រះអង្គថ្នមបបក់ ព្រលឹងម្នក មាសប្អូនគន់ បីដាក់លើយន្តយន្ត ស្រេចហើយហៀរហោះចាកបាន ៗ ប្រទក្សិណប្រាសាទ ប្រសើរស្អាតបីដុំបាន បរិបូណ៌ហើយក្សត្រក្សាន្ត ហោះទៅត្រង់នាមណ្ឌល ៗ នៃព្រះបាចញ្ចាល់ ដាបិតានាងទមិល ទើបព្រះ

បាទទសពល បន្ទូលពីអាកាសថា ៗ ហៃស្តេចកំឡោលខ៌ ជាទុជ៌នដ៏

មោហោ ខ្ញុំឥតពិចារណា ពុំចេះគិតឲ្យអស់ក្តី ៗ ឥឡូវចូរស្តេចស្តាប់

អញនឹងប្រាប់ដំណើរពី អង្គអញឯងជាតិ មិនគឺកូនព្រាហ្មណ៍ហោក ៗ

អញឯងបុត្រព្រះអង្គ អាទិត្យវង្សចិកជា គ្រប់គ្រងក្រុងភាព អស់ក្សត្រា

ទាំងរយឯក ៗ អញឯងចរយាត្រា បង់ស័មាមកឆ្ងាយពេក តែអង្គអញ

សង្វេគ សំណាក់នៅព្រាហ្មណ៍ហោក ៗ ព្រះចៅបញ្ចាល់ស្តាប់ ព្រះ

អង្គប្រាប់ដូច្នោះណា៎ ក៏តញ័រអស់អង្គា ខំមើលទៅឯអាកាស ៗ

យល់ជាក់ជាព្រះអង្គ ស្តេចស្តែនគង់លើហង្សមាស ស្តេចក៏ចុះផ្លាស់

គ្រប់ៈវៃចង់ដោយរហ័ស ៗ ស្តេចយល់ហើយរៃគិត ក៏យឯងឥតពិ-

ចារណា ខំទូលអង្វរថា អម្ចាស់អាពុកអ្នកអើយ ៗ សូមទានអ្នក

សន្តោស កុំយកទោសអាពុកឡើយ ស្តីអាពុកក្បើយហើយ សូមអាណិត

អាពុកវិញ ៗ ទោសអាពុកនេះជ្រៅ ធ្ងន់ក្រាស់ក្រៅប្រមាណមិញ

សូមអ្នកប្រោសចោលចេញ អត់ទោសទៅយកតែបុណ្យ ៗ អា-

ពុកមានបុត្រី ឆោមពិសិពិសេសលន់ ថ្វាយស្នងជាប្រពន្ធ ជាម្ចាស់

អ្នកហើយណា៎ ៗ រីព្រាហ្មណ៍ប្រាជ្ញបុរោហិត កុំអ្នកគិតទុក្ខឲ្យអា· ពុក

នេះនឹងរកា កុំឲ្យព្រួយព្រះទ័យឡើយ ៗ បើអ្នកមានមេត្តា ទ្រង់

ករុណាអត់ទោសហើយ ព្រះគុណអ្នកជាត្រើយ អាពុកពុំភ្លេចឡើយ

ណា៎ ៗ ក្សិណនោះឯព្រះបាទ បរមនាថធិរាជា យល់ព្រះចៅបញ្ចាល់

ចាញ់ខ្ញុំបង្ខាចព្រះបារមី ។ ពុំអាចហានប្រឡង ប្រកួតជនព្រះបារមី សម្តេចព្រះជិនស្រី ស្តេចពុំយកទោសឡើយណា ។ ឯនាងនាថទេវី អគ្គមហាសិរីសួគ៌ាសោភា នាងផ្តាំព្រះមាតា ថាបពិត្រអ្នកម៉ែអើយ ។ ខ្ញុំសូមគាល់ក្រាបលា ព្រះមាតាឥឡូវហើយ អ្នកម្ចាស់កូនអើយ កូននឹងទៅពុំបានណា ។ ក្សណនោះព្រះជននី ឮបុត្រីនាងទូលលា នាងបេញស្រមីស្រមា ទៅតែយល់កូនបុត្រី ។ នាងទ្រង់ព្រះកន្សែង សោកស្ញប់ស្ញែងស្តុតស្មារតី ពិលាបលោមយាត់ខ្វី ថាកូនស្ងួនមាតា ។ មាសអើយកុំនាងទៅ ចូរនាងនៅនឹងម្តាយក៏ ម្តាយមានមាសមេជា ចើមដង្ហើមម្តាយសព្វថ្ងៃ ។ អ្នកនៅនេះចាំងពារ ម្តាយបង្ហើររស់ចាំងថ្ងៃ ក្រោមក្រមឲ្យឆាសថ្ងៃ ចាំងពារសោយរាជសម្បត្តិ ។ កូនចាំងពារអើយ កុំទៅឡើយម្តាយសូមឃាត់ អស្តាញចុះមកថ្វាត់ នៅនឹងម្តាយក៏មាសថ្ងៃ ។ ខ្ទួនម្តាយសោកពាសហើយ មាសម្តាយអើយបើម្តាយក្សយ ម្តាយដើរខ្លាចនេះនៃ ឲ្យកូនប្អូនលើកខ្មោចម្តាយ ។ មាសអើយកុំនាងទៅ ចូរនាងនៅណានាងនាយ អាសូរត្រឹមតែម្តាយ កុំយកទោសព្រះបិតា ។ ថាបើនាងកូនទៅ មាសមិននៅនឹងយាត្រា ទៅផងនឹងប្តីនាងណា សមម្តាយក្សយឯងកូនអើយ ។ ដ្បិតម្តាយកំព្រាសល់ ឥតឯយល់អ្នកណាឡើយ ព្រលឹងមាសម្តាយអើយ សូមនាងនៅនឹងម្តាយក៏ ។ ក្សណនោះរាជបុត្រ ស្តាប់ជននីនាងសោកា បន្ទូល

ដូច្នោះណា នាងសែនសោយសោកាណស់ ៗ អាណិតព្រះមាតា
នាងសោកាពន់ពេកសល់ ព្រះនេត្រាដោរដល សស្រាក់ស្រោចព្រះ
កន្ត្រា ៗ នាងសោកពុំអាចថ្លែង ចរចាចែងចេញឡើយណា តាម
គន់ផ្លូវទុក ចង្អៀតអស់ព្រះហឫទ័យ ៗ ក្សណនោះព្រះភូបាល
យល់ជាយាសោកពេកក្រៃ ស្តេចកើយទូមាំសមៃ ហោះអណ្តែត
ដោយវេហាស៍ ៗ ព្រះឥន្ទ្រស្តេចគង់យន្ត ហោះដោយបុណ្យព្រះ
ចេស្តា ខ្ពស់ផុតព្រះនេត្រា នៃអ្នកផងពុំយល់ឡើយ ៗ ឯព្រះវរបិតា
សែនសោកាឥតឯស្បើយ ដៀតកូនស្ងួនគ្រាណាត្រើយ ប្រែប្រាស
ព្រាត់ចម្បែងបង់ ៗ សម្តេចវរមាតា សោយសោកាសន្ធប់ស៊ុង នាងឈឺ
ដៀតបុត្របង់ ប្រែប្រាសពីព្រះទ្រូង ៗ ឯព្រះភូមិ យល់ទេវីសន្ធប់ណា
ស្តេចយកព្រះគង្គា ក្សិតព្រះកន្ត្រានាងនាថហើយ ៗ ក្សណនោះវរក្សត្រី
ភ្ញាក់ស្មារតីពុំលង់ឡើយ នាងសោយសោកឥតស្បើយ ពិលាបលន់
ពន់ពេកណា ៗ នាងនាថយកព្រះករ តាំងពីគេគក់ទុក ព្រះទស្សៃថ្ងូញថា
ឱកូនស្ងួនមាសម្តាយអើយ ៗ ពីដូចមាសឧត្តម កើតមកធំ ៗ ម៉្លេះហើយ
ពុំដែលបង់ម្តាយឡើយ ដល់រាត្រីថ្ងៃមួយណា ៗ នេះម្តេចម្តេចកូនទៅ
ប្រែប្រាសទៅពីមាតា តាំងនេះហេតុវេរា ឯងមកផ្តល់កូនឱម្តាយ ៗ
ឱកូនស្ងួនប្រាសទៅ ទីលំនៅនៅឆ្ងាយ ឱកូនមាសមិត្តម្តាយ ម្តាយ

ថប់ច្រើនប្រការក្តាត់ ៗ ឱម្តាយប្រណីនាថ ជាប់នៅប្រាថ្នាប្រាសាទទេវ ឥឡូវនេះនាងក្រាត់ នៅឯកាណាកូនអើយ ៗ ម្តាយថប់មួយពេកក្រៃ គគិតពេញផ្ទៃបរិបូណ៌ហើយ ក្រែងពុំដល់ស្រុកឡើយ ជួនប្រសូតដោយ មាគ៌ា ៗ ថប់មួយក្រែងដល់ហាន ភពពិមានព្រះអង្គជា មេក្អូកបាក្អូក ណា៎ ក្រែងលោកពុំការសួរមេ ៗ មិនអស់ចិត្តដូចខ្លួន ឱកូនសួន ៗ មាស-ស្នេហ៍ ម្តាយគិតគិតនៅខែ ថៃហើយថប់ថប់ពេកពន់ ៗ សម្តេចព្រះជននី សោកបុត្រពិលាបលន់ ទល់ទុក្ខជាទុរន់ គាន់ទុកវៀងនៅហោង ៗ

នេះនឹងចរចាថែង និទានថ្លែងដោយគន្ថ ដំណាលនូវទំនង ដំណើរព្រះពោធិសត្វ ៗ ស្តេចហោះនឹងប្អូនក្តា ដោយវេហាស៍ប្រសើរ ភ្ញាត ពីរពន្ធ្យព្រះអគ្គក្សត្រ បន្ទោបង់លែងសោកា ៗ ស្តេចស្តែងជង្រ ដោយបុណ្យ កណ្តាលមណ្ឌលវេហាស៍ ឥតក្សត្រដទៃណា នៅស្មើនឹង ព្រះអង្គបាន ៗ ក្សត្រានូវក្សត្រី ប្រសើរវិសេសៈក្កងថ្កាន ស្តេចហោះ ពាពឃហាន គំរប់ជួនទិនទិវា ៗ នាងឈឺព្រះឧទរ គ្រប់បរិបូណ៌ខែហើយ ណា៎ នឹងប្រសូតពជបុត្រា នាងក្រាបទូលព្រះភូមី ៗ ស្តេចស្តាបព្រះប្អូន គន់ ស្តេចកើចយន្តមាសមណី ធៀងឆាប់ចុះទាបទ្វី ចុះដល់ដីដើមព្រឹក្សា ៗ ស្តេចចូលបតអាស្រ័យ ក្រោមព្រះដៃព្រៃក្រឹស្នា ខាងឆ្វេរព្រះគង្គា គឺស្រះ បោក្ខរណីៈជ្រៅ ៗ ខែត្រខែមបាមពាន្ត ស្តេចសម្រាន្តអាស្រ័យនៅ វិងព្រះប្អូនពៅ សែនសោកាស្មោគស្មុគ ៗ នាងទ្រាថនាវថ្ងៃ នាងឈឺផ្ទៃ ញ៉ាររន្ធត់ អស់ឥន្ទ្រិយស្រយុត ពុំស្រយាលដល់តិចឡើយ ៗ (អានត)

# រឿងមរណមាតា

(តមក)

លោក ប៉ី សុវណ្ណ ចម្លងពីសារៈស្តាស្វីការ

---

កំពែងវែងត្រដាច ចុះស្ងាចខ្ពស់ត្រៃឈើ ត្រឈឹងស្តឹងស្កឹមស្គៃ
តាំងប្រាំពីរជាន់ដុំដិត ៗ នៅក្តារទើសតាំងជួន សមជំជួនជះពេកពេក
ស្រោងស្រស់ខ្ពស់ពិចិត្រ ហើយបូកឈ្មើតៈកសា ៗ គាកកែងជាមណ្ឌប
កំពូលគ្រប់ប្រាំសោភា ល្អល្អះឥតគណនា មានក្បូរក្បាច់ផាសជាំដិត ៗ
ដាំត្បូងដាក់ពាក្យ ក្បាច់ក្បូងក៏មានមាសបិទ ភ្លឺផ្លេក ៗ ពិចិត្រ មាន
ទល្ហូនោងប្រាលប្រុះ ៗ គូរគោគៈជ្រៅស្រឡូង សឹងចំរូងដែកដាំផុះ ដាំពិត
ប្រភិតប្រុះ ជាសម្រាប់ការសង្គ្រោម ៗ គូទក ៗ ជ្រាលជ្រៅ មៀង-
មើលទៅលិចអន្ទាម អន្ទង់មានម្កាឆ្ងាម គ្រកពើច្រើនយោរយៅ ៗ
ទឹកកកពឹកសំងុះ ច្រើនប្រច់ប្រុះផ្កាប្រាលឆ្មៅ មច្ឆាហែបហែលទៅ
ទាស្រ័យពឹងពាកពួន ៗ សេនាពួកពាហន កងរូបប្រាណធំក្រអួន
ក្រអឺតស្កូតមាំមួន ចិត្តក្លៀវក្លាមិនខ្លាចស្លឹក ៗ បេះគូខគង់អាគម
រូបធាតុធំចិត្តឥតកុក តយល្បាតតាំងយប់ព្រឹក យាមប្រយ័ត្នសព្វទិស ៗ
អស់រាស្ត្រសោភិន ដោយហ្វូរម៉ុញក្សត្រា ឥតទុក្ខឥតទោសា ឥត
សត្រូវបៀតបៀនប្រាណ ៗ

## បឋភាភកតិ

នេះនឹងថ្លែងនិត ដំណាលដំណ ដំណើរនិទាន បទដើមចំពោះ

កាលនោះមែនមាន បុរសមួយប្រាណ និត្យនៅភរិយា ៗ រនាមនៃ

ឈ្មោះ កុលីយបុរស ប្រពន្ធនាមា នាងកែវកេសី ជាស្រីសោភា

សុភាពភរិយា ភាយោល្អល្អះ ៗ ល្អល្អិតប្រិមប្រិយ ឡើងបុណ្យស័ក្តិថ្កី

បំរើម្ចាស់ ស្តេចទ្រង់ប្រណី កុលីយនោះណាស់ ព្រះអង្គទ្រង់ត្រាស់

បើកបន្ទូលថា ៗ កុលីយបុរស អញឱ្យស័ក្តិយស ស្តីការពេជការ

ឲ្យចៅមស្រុក ដោះទុក្ខនានា របស់ប្រជា- ទុកស្ត្រស្រុកក្រៅ ៗ កុលីយ

បុរស ទទួលស័ក្តិយស វិលមកលំនៅ ស្តីការពេជការ ប្រជាកស្ត្រក្រៅ

ចំណោះតទៅ រីឯភរិយា ៗ នាងមានតភិគ្រប់ ដប់ខែសម្គត បុត្រ

សោភា មេស្រុកឲ្យនាម នោះតាមពង្សា យកនាមមាតា បិតាមកផ្សំ ៗ

ឈ្មោះកុលកេសី កុមារប្រិមប្រិយ រូបកាយឧត្តម ល្អល្អះទ្រង់ទ្រាយ

ផ្គុំមានស័ក្តិសម ចម្រើនវៀគុំ ដូចទេពធីតា ៗ ជនកជននី

ស្រឡាញ់បុត្រី បណ្តុលស្នេហា ដ្បិតបុត្រតែមួយ ត្រយសង្វាព

កើតមកកាលណា ចំរើនយសស័ក្តិ ៗ ទាសាទាសី គោសេះដំរី

របស់មាសប្រាក់ មេស្រុកកើតមាន ធនធានអនេក អនេកឥតភាគ

សាត្តសុខសត្វថ្ងៃ ៗ ដូចចូលគំរប់ ប្រាំមួយដណ្តប់ រូបកាន់

ល្អព្រំ មានលក្ខណា សោភាប្រពៃ ញ៉ាំគ្រៀងដទៃ ទ្រែសោត.

សឹងស្រឡាញ់ ៗ មកមើលកុមារ សឹងកាន់ទ្រព្យ មកជូនពាសពេញ

ពោរពេញទាំងផ្ទះ លុះវិលវិញ ទៅទុកស្រឡាញ់ មកក្រោយ

មហិមា ៗ ឈប់ស្ទើរខានខាន ទៀងទើបទិទាន ទៀតគតណិនា

មិនមានបុរស មួយនោះជាតិជា អ្នកស្រែនៅនា ទៀបទីមេស្រុក ៗ

បុរសនោះមាន ភរិយារូបប្រាណ ក្រក្រពុំសុខ ពុំក្សាន្តសប្បាយ គង់

កាយវិតក្ក ដៀតគ្មានសម្បក សម្បត្តិល្អជា ៗ សង់ផ្ទះតូចមួយ ទៀង

ដេករញ្ជួយ ស្ទើរធ្លាក់សោះសា រក្សាស្រូវស្រែ គ្រាន់តែភោគ្គា គង់

ទើបភរិយា មានគភ៌ទ្រគប់ ៗ បុរសជាប្តី រវល់ឃ្មាតខ្ទី មិនមានឈរ

ឈប់ រកេសកាស្រ័យ ពីថ្ងៃរះយប់ មិនមានឈរឈប់ ទៅលក់

យកថ្លៃ ៗ ទិញត្រីភោជន ចិញ្ចឹមប្រពន្ធ ពុំខានមួយថ្ងៃ រស្រូវក្នុងស្រែ

ពុំបែរវៃតា ប្រពន្ធសព្វថ្ងៃ ទៅមើលទៅថៃ ៗ មានកាលមួយថ្ងៃ

ប្រពន្ធវិលវៃ ទៅមើលស្រូវស្រែ ដេញចាបរំពៃ សព្វថ្ងៃសព្វខែ

តាមកាលនោះឯ- នាងឈឺពោះពេក ៗ សម្តែងបុត្រប្រុស រូបកាន់

ស្អានស្អោះ តែម្នាក់ឯងឯក ហេតុតែកំសត់ ទុគ៌តអនេក ការណ៍គនានីពេក

នាងពុំសប្បាយ ៗ រួចអស់ពីពោះ ទើបដឹងដល់អស់ គ្រៀងលានតាំង

ឡាយ ដែលចាំចាបស្រូវ ស្រែនៅជិតឆ្ងាយ រួតប្រញាយ មកមើល

ជូនថ្លៃ ៗ ជុំញាតិកា មាតាបិតា ឲ្យឈ្មោះគ្រោះតែ ហេតុកូននោះកាល

សម្រាលក្នុងស្រែ ឲ្យ ឈ្មោះហៅតែ ក្មេងក្តីកុមារ ៗ លុះជន្មដល់ចប់

ចូលជួបគំរប់ សោឡសវស្សា មុខមាត់ប្រិមប្រិយ ប្រុសស្រីទូទា
ល្អលើសកុមារ ក្នុងស្រុកទាំងឡាយ ៗ ចេះជួយធ្វើការ មាតាបិតា
គ្រាន់ធូរសប្បាយ មើលតាបមើលថៃ ទឹកស្រែសប្បាយ ជួយកំលាំង
ម្ដាយ ឪពុកគ្រាន់ល្ហែ ៗ មានមួយថ្ងៃ កេសីធីតា ចិត្តចង់លេង
ស្រែ ក៏លៀងមេទំ ហោមជុំដង្ហែ ទៅតាល់ទៀបស្រែ កុដុម្ពីកកុមារ ៗ
កុដុម្ពីកមើលយល់ ធីតាទិមិល ក្ដួចកើតស្នេហា ចាប់ចិត្តស្រឡាញ់ ពោរ
ពេញចិន្តា ក្រុះលាន់មាត់ថា ឱកូនមេស្រុក ៗ អញមិនដែលយល់
រូបល្អទិមិល ឲ្យអញកើតទុក្ខ ធ្វើម្ដេចនឹងបាន រួមឋានរួមសុខ កុដុម្ពីក
ជាទុក្ខ ខ្វល់ខ្វាយចិន្តា ៗ នាងកុលកេសី បានឃើញកុដុម្ពីក ក្ដួចកើត
ស្នេហា ក្នុងចិត្តផ្អើលផ្អូក ទៅមកកាន់គ្នា • ហើយរំពគ្រីហា ជាសុខ
សប្បាយ ៗ រីឯកុដុម្ពីក កើតទុក្ខអំពី បានយល់រូបកាយ នាងកុលកេ-
សី ប្រិមប្រិយឆោមឆាយ អត់ទឹកអត់បាយ ពុំបានកោត្តា ៗ ធ្លាក់
ចិត្តរំភើង វិលវល់ដើរលេង សះលេលលា លលះឥតក្រេង ផាស្បែង
អស្សារ មិនមានការការ កាន់ក្ដួចតែស្រី ៗ មាតាបិតា គន់គិតថៃ
ថា ឱកូនពីសី មិនដែលដូច្នេះ កូនទេះឈឺអ្វី គិតហើយស្រដី
ជណ្ដឹងទៅថា ៗ ហៃកូនមាសម្ដាយ ថ្មីមិនហូបបាយ ឈឺអ្វីប្រាប់ក៏
កុដុម្ពីកប្រាប់គ្រប់ ប្រាប់សព្វគ្រប់ការ ពីឃើញរូប នាងកុលកេសី ៗ
ម្ដាយប្រាប់ហើយថា ឱកូនពុំអា កូនយើងក្រក្រៃ កូនលោកមេស្រុក

ជាមុខមន្ត្រី បើចង់សើច កេកស្រែជួបគ្នា ៗ ឯកុដុម្ពិកនោះ ពុម្ពាយស្រោម ថ្មោះ ពាំចេញចរចា សញ្ចឹងសញ្ចប់ សុខស្ងួតក្រា ទៅចរកោក្កា បានពីរបីម៉ាត់ ៗ ហើយដើរទៅស្រែ គន់គិតទៅតែ កេសីមិនបាត់ ថ្ងៃនោះកេសី ប្រមប្រិយរូបរ័ត្ន ទៅឆ្នួតទឹកថ្លាត់ តែពីរអង្គ ៗ ខឹងកំលៀនម្នាក់ កុដុម្ពិកដើរស្រោក ទៅពាល់ជួបគ្នា ជួបកុលកេសី នៅទីគង្គា កុដុម្ពិកម្ចា ចូលចាប់ដៃខ្លាប់ ៗ ហើយសួរទៅថា ដោយពាក្យស្នេហា សួរលោម រៀបរាប់ នាងសោកខេរខ័ន រួសរ័ន្ធពុំស្តាប់ កំលៀនប្រញាប់ ចូលជួយ បេះដៃ ៗ កុដុម្ពិកប្រឹងក្តាប់ កដៃនាងជាប់ កំលៀនសោកវៃ ជួយទារក្រៅ ប្រែកទៅខាងក្រៅ ហៅម្នាក់ដទៃ ឲ្យជួយផង ៗ ឯកុលកេសី ភាំង ភិតភ័យតក់ស្លុត តក់បើបមា ខាងក្តិបនាងខាំ នាងខាំនាងខ្វារ កុដុម្ពិក មិនលា មិនលែងនាងសោះ ៗ រហែកអាវស្បៃ លុះបានដល់ដៃ កុដុម្ពិកកាលនោះ កំលៀងមើលយល់ កិច្ចកលចំពោះ កំលៀនចេញ ចុះ ចេញបោលផង ៗ កុដុម្ពិកសោកបាន រួមសុខរួមប្រាណ ទីន កេសីណា ស្រេចហើយកំលៀន នាំនាងផង វិលទៅគ្រឹហា ដូចដើមប្រក្រតី ៗ កំលៀនផង ពុំហ៊ានចរចា ពាក្យពេចន៍អ្វី ៗ កុដុម្ពិកគេងទៅ ស្ងួតនៅកេសី ពល់ៗពេត្រ ពុំមានទំនង ៗ យូរទៅកុដុម្ពិក ប្រាប់កុលកេសី ថាប្អូនស្នេហា យើងនៅពុំបាន ក្រែងមានទោសា ចេះយើងនាំគ្នា រត់ទៅជនបទ ៗ កេសីឆ្លើយថា អ្នកគិតនោះជា

ពេញត្រូវប្រាកដ ស្រេចហើយកុដម្ពក់ គិតទីកំណត់ វេលាទីនេះតែ ប្រាប់កុលគេសី ៗ ឲ្យរៀបស្បៀងផ្លូវ ទៅតាមសត្វ ភស្តុភោជ្យ ចំណី នានាលបលាក់ផ្ញើ សរពើអ្វីៗ ស្រេចហើយគេសី ប្រកេវិច ទុកល្អ ៗ ស្រេចយកសំពត់ ចាស់ស្លៀកព័ទ្ធព័ទ្ធ គៀស ថ្ងៃជាក្រ ហើយយកសំពត់ ថ្មីបត់វេចខ្ចប់ យល់ស្មាតនានីចរ នានាពាក់គ្រឹហា ៗ ទំដើរទាំងយប់ មិនយប់មិនក លុះភ្លឺសុរិយា ទើបគេត្រៀមខ្លួន ៗ នាំគ្នាគោក្តា ហើយរៀបទ្រព្យា លងលក់មាំមួន ដោយខ្សៀយហាត់ពេក ដេកពុំដឹងខ្លួន ពោះដាស់អន្ទីន ស្មើរពុំភ្ញាក់ប្រាណ ៗ លុះវាទ់សុរិយា ទើបភ្ញាក់ទ្រព្យា បរិភោគខ្ពួតបាន ចាំលុះព្រលប់ ពុំយប់សម្រាន្ត ងងឹតទើបបាន នាំគ្នាដើរទៅ ៗ សត្វថ្ងៃប្រក្រតី ពល់រាត្រី មិនឈប់ឈរនៅ ពោះបីខ្សៀយហាត់ ទំអត់ទុកទៅ ដើរកាត់សំដៅ ជនបទគ្រាមា ៗ

នេះនិពាន់ទៅ ឯមេស្រុកនៅ លុះបានទ្រព្យា គិតល្បៀងមិន ជួបជុំគ្រប់គ្នា យល់បាត់ធីតា ពុំមានដំណឹង ៗ ទៀងទៅដកប មេស្រុក ដកប សេចក្តីដែលដឹង មេស្រុកឲ្យរក គោឡាច្រហឹង ទ្រហោ យំអឹង យំអាបពល់គ្នា ៗ អាពុកកុដម្ពក់ នៅឆ្ងាយភ្ញាក់ពី ដេកបាត់បុត្រ ក្វា ដឹងហេតុនោះជាក់ គិតលាក់ពាំងក ខ្សឹបខ្សៀវប្រាប់គ្នា មិន ឲ្យស្រដី ៗ កូនយើងជាប្រុស យើងខ្សត់របស់ កូនលោកជាប្រើ

វានាំបរើន. ឲ្យយើងកើតក្ដី យើងរកវាថ្វី ឲ្យខឿយអាត្មា ទីដ៏រម្យស្រុក ជាថ្មីខាងកៃរកេសី គិតពិចារណា ហៅអស់មេទំ មកជុំពល់គ្នា ហើយសួរទៅថា ហនស្ដីឲ្យត្រង់ ៗ ដៀកហង់រក្សា កូនអញពល់គ្នា មិនឲ្យលះបង់. បើនោះមិនគាប់ ហន៍ប្រាប់ឲ្យត្រង់ អញរសាគអញ ចង់ ដឹងហេតុឲ្យជាក់ ៗ ក៏លៀនជំពប ថាសូមលោកជ្រាប យើង ខ្ញុំទីងលាក់ កាលលោកទៅហ្វាយ ឲ្យទៅរកអ្នក យើងខ្ញុំសឹងស្ទាក់ សឹងស្លាបសត្វទ៏ ៗ ទៅរកដល់ស្រែ ប៉ានសួរផ្ទះមេ ជាម្ដាយកុដម្ពក មិនម្ចាំនព្ធមាត សូទ្យស្ទាត់ពិទ គ្រង់នោះពុំះបរ តែលោកមេត្តា ៗ មេស្រុកបានស្ដាប់ ក៏លៀនថ្លៃប្រាប់ គិតក្នុងចិត្ដា ទើបស្ដីថាអើ ថាបើខ្លួនវា ជាកូនពុំងា មិនបង់ជំមុខ ៗ វាកាច់កើ្តខ្លាស ឲ្យអាស្រាវ ភាស ខូចកេ្មាះអាពុក អញរសាគកាត់សាច ឲ្យជាប់គុំទុក ពីរខះ ទៅមុខ លៃនទឹកលៃង់រក់ ៗ ឯម្ដាយកុដម្ពក អាពុកនោះក្ដី ហេតុតែ អ្នកទ្រ ព្ធថាមេស្រុក មិនរកមិនរក់ មានចិត្តក្រេកអរ ឥតប៉ះបមា ៗ

បទព្រហ្មគីតិ

ទ័យនេះស្មេះឈប់ខាន ទីង់ខិពាខតបរចា ឯកុដម្ពក់យាត្រា ទីង នាន់កុលកេស់នោះ ៗ ដើរដោយដងមាគ៌ា ចូលព្រៃក្សាព្រៃបោះ ដើរ យប់មិនឈប់សោះ មិនសម្រាន្តខាននិទ្រា ៗ

(មានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## រឿងព្រះជ័យសួស្តី

លោក ប៊ូ.ប៊ូ រៀបរៀង

វេលានេះ សូមបរិយាយអំពីពាក្យថា "ជ័យហោង! សួស្តីហោង! មែនហោង! តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ មានសេចក្តីដូចតទៅនេះ:

ជនានុជននៅប្រទេសខ្មែរ កាលបើមានធ្វើពិធីមង្គលការ វេលាដែលកូនប្រុសស្រីកំពុងក្រាបទន្ទឹមគ្នា នាកណ្តាលទីប្រជុំពួកញាតិមិត្រ មានមាតាបិតាជាដើម ដើម្បីសំពះទទួលស្វាពរអំពីមេបានោះ លោកអាចារ្យតែងស្រែកសួរពួកញាតិមិត្រនៅទីនោះថា "ជ័យហោង ?"

ពួកញាតិមិត្រឆ្លើយព្រមគ្នាថា "ជ័យ !"

លោកអាចារ្យសួរទៀតថា "សួស្តីហោង ?"

ពួកញាតិមិត្រ ថា "សួស្តី !"

លោកអាចារ្យ ថា "មែនហោង ? "

ពួកញាតិមិត្រ ថា "មែន !"

លោកអាចារ្យ ថា "យកអ្វីជាបន្ទាល់ ?"

ពួកញាតិមិត្រ ថា "យកហោជាបន្ទាល់ !

រួចកំតាំងនាំគ្នាស្រែកហោកង់រំពងពេញផ្ទះ ៣ ដង ឯលោកអាចារ្យក៏លើកឃ្មោះឡើងវាយយ៉ាងខ្លាំងឮសូរម្ដងៗ ទុកជាសញ្ញាថា កូនប្រុសស្រីគូស្វាមីភរិយាថ្មី មានសិរីសួស្ដីជ័យមង្គលហើយ ។

របៀបនេះ អ្នកផងនៅប្រទេសខ្មែរយើង គេតែងធ្វើគ្រប់គ្នាពេលតែពេលរៀបមង្គលការកូនប្រុសស្រី ។

សំនួរ- គួរឲ្យឆ្ងល់ណាស់ ចុះហេតុអ្វី បានជាជាតិខ្មែរប្រកាន់យកពាក្យ "ជ័យហោង! សួស្ដីហោង! មែនហោង! បីបទនេះ មកធ្វើជាគ្រឿងមុខក្នុងពិធីមង្គលការ ? ។

ចម្លើយ- ព្រោះមានអត្ថនិទានជារឿងព្រេង ដែលចាស់ៗដំណាលតៗគ្នាមកថា:

កាលពីព្រេងនាយ មានស្ត្រីក្រមុំម្នាក់ កំព្រាឪពុក មានតែម្ដាយ មិនដឹងជានៅស្រុកទេសណាទេ ។ ជួនជាគ្រានោះ ស្រុកទេសកើតអំណត់អត់ឃ្លានដោយកង្វះភ្លៀងយូរពេក ។ នាងក្រមុំកំព្រាតែងចូលទៅព្រៃ ព្រៃជីកដំឡូងនឹងមើមឈើឯទៀតជាមួយអ្នកស្រុក យកមកស្ងោរបរិភោគជួសបាយតែសព្វថ្ងៃរៀងមក ។

វេលាពេលមួយ នាងក្រមុំដេកលក់ទៅយល់សប្តិឃើញថា ព្រះឥន្ទ្រយកគជ ១ មានសម្បុរល្អណាស់មកហុចឲ្យនាង ហើយប្រាប់ថា "របស់នេះ ជាគជដ៏វិសេស ចូរនាងថែរក្សាទុកឲ្យល្អ ឲ្យគង់នៅយូរ

លង់ទៅ នាងទឹងបានជាចំពុំលែងឡើយ " ។ ព្រះឥន្ទ្រប្រាប់រួចក៏កៀសខ្លួនបាត់មួយរំពេចទៅ ។

លុះព្រឹកឡើង នាងក្រមុំដណ្តាំបាយផ្អិនដួសខ្ចប់ជាសំណុំនឹងទឹកមួយបំពង់ រួចលីចបជីក ចូលទៅព្រៃជាមួយអ្នកស្រុកដូចថ្ងៃមុន ៗ ។ លុះនាងចូលទៅក្នុងព្រៃជ្រៅឆ្ងាយ ស្រាប់តែមេឃមានស្រទំងងឹតឈប់ផ្គរលាន់គ្រឹម ១ ហាក់ដូចជាធ្លាក់ភ្លៀងភ្លាម ១ ។ ឯពួកចាស់ ៗ ឃើញមេឃងងឹតដូច្នោះ ក៏និយាយលេងថា " ហ៊ាចាំអីទៀត យើងចាក់ទឹកបំពង់ចោលទៅ ចាំត្រងយកទឹកភ្លៀងផឹកវិញ " ។ នាងក្រមុំ ហេតុតែខ្លួននៅក្មេងខ្វះសេចក្តី ពុំសិជចាស់ៗ ដូច្នោះ ក៏ចាក់ទឹកបំពង់របស់ខ្លួនចោលអស់រលីងទៅ ។ តមក មិនយូរប៉ុន្មាន ស្រាប់តែមេឃប្រែខ្វៅជាភ្លឺស្វាងស្រឡះឡេងទៅវិញ ឥតស្រក់ភ្លៀងមួយដំណក់សោះ ។ បន្ទាប់ពីនោះមក នាងក្រមុំស្រេកទឹកយ៉ាងខ្លាំង ទ្រាំពុំបាន ក៏ដើររុះរស្វែងរកទឹកផឹក ទៅឆ្ងាយពីគេ ដល់កន្លែងមួយ នាងឃើញទឹកដក់នៅក្នុងដានជើងដំរី ដែលវាទើបដើរផុតទៅថ្មី ១ នាងស្មានថាជាទឹកភ្លៀង ដោយស្រេកខ្លាំងពេកក៏ឱនក្រេបផឹកទាល់តែឆ្អែត ទើបបានដឹងជាក្រោយថាទឹកនោមដំរី ។ នាងវិលមកផ្ទះវិញ ក៏មានទម្ងន់ដោយសារតែផឹកទឹកនោមដំរីនោះ លុះគ្រប់ខែហើយសម្រាលមកជាកូនប្រុស នាងឲ្យឈ្មោះ "ជ័យ" ។

ចំណេរក្រោយមកទៀត នាងក្រមុំនោះមានផ្ទៃ បានកូនប្រុសម្នាក់ទៀតឲ្យឈ្មោះ « សួស្តី » ។ មិនយូរប៉ុន្មាន ប្តីនាងអនិច្ចកម្មទៅ នាងនៅចិញ្ចឹមរក្សាកូនប្រុសទាំងពីរតែម្នាក់ឯង ។

ថ្ងៃពីព្រះមហាក្សត្រក្នុងនគរនោះ ស្តេចទ្រង់ព្រះទិវង្គតទៅគ្មានព្រះរាជបុត្រា-បុត្រីមួយព្រះអង្គ នឹងឡើងគ្រប់គ្រងនគរ តព្រះរាជវង្សនោះ ។ ទើបពួកអាមាត្យមុខមន្ត្រីធ្វើពិធីបួងសួងផ្សងដំរីមង្គល ដើម្បីស្វែងរកអ្នកមានបុណ្យវាសនា យកមកអភិសេកសោយរាជ្យក្នុងនគរនោះ ។

ឯដំរីមង្គលនោះ មានរេហ៍ពលជាច្រើនដើរដង្ហែពីក្រោយ ដើរទៅដល់ផ្ទះចៅជ័យនិងចៅសួស្តី ក៏លុតជើងមុខទ្រោមក្រាបនៅមុខផ្ទះនោះ ។ អាមាត្យមុខមន្ត្រីអ្នកតាមហែដំរី ឃើញអាការដូច្នោះហើយ ក៏សំគាល់ថា ចៅជ័យនិងចៅសួស្តីជាអ្នកមានបុណ្យបារមីច្រើន អាចសោយរាជ្យបាន ទើបយកគ្រឿងរាជ្យចូលទៅបំពាក់ចៅជ័យ ហើយអញ្ជើញឲ្យឡើងជិះដំរីមង្គលហែចូលក្នុងព្រះបរមរាជវាំង តាំងអភិសេកចៅជ័យជាស្តេចសោយរាជ្យ, អភិសេកចៅសួស្តីជាព្រះឧបរាជ ក្នុងពេលជាមួយគ្នា ។ នៅវេលាអភិសេកនោះ សេវកាមាត្យមុខមន្ត្រីទាំងពួងនាំគ្នាបន្លឺសម្រែកថា "ជ័យោហោង! សួស្តីហោង! មែនហោង! បីដងស្រេចហើយ ក៏ស្រោចទឹកក្រូសទឹកសង្ខអភិសេកសម្រេចកិច្ចសុភមង្គលក្នុងគ្រានោះឯង ។

ពាក្យ "ជ័យហោង, សួស្ដីហោង" មានរឿងព្រេងប្រារព្ធមកដូច្នេះ ។

ចំណែកពាក្យ "មែនហោង" ពុំមានរឿងព្រេងប្រារព្ធចំពោះរូបអ្នកណាទេ ហើយពុំមានអត្ថាធិប្បាយឲ្យពិស្ដារផង គ្រាន់តែជាពាក្យដែលលោកអាចារ្យសួរបញ្ជាក់យកសេចក្ដីពិតប្រាកដ ជាលើកទី៣ បន្ថែមទៅលើពាក្យ "ជ័យហោង" ទី១ "សួស្ដីហោង" ទី២ ឲ្យឃើញថា កូនប្រុសស្រីដែលក្រាបសំពះទទឹមគ្នានោះ ជាអ្នកមានជ័យជំនះឈ្នះមារសត្រូវមែន ជាអ្នកមានសិរីសួស្ដីមែនៗ ឬពុំមែនប៉ុណ្ណោះ ។

ពួកញាតិមិត្រឆ្លើយបញ្ជាក់ថា "មែនពិតណាស់ហោង ឥតក្លែងក្លាយទេ" ។

ហេតុតែមានទំនាងរឿងព្រេងដូចថ្លែងមកហើយនេះ បានជាមានពាក្យ "ជ័យហោង ! សួស្ដីហោង ! មែនហោង ! ក្នុងពិធីមង្គលការជាប់ជាទំនៀមទម្លាប់រហូតមកដល់សព្វថ្ងៃនេះ ។

# រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

(តទៅ)

លោក ហ៊ុយ-ម៉ុត រៀបរៀង

---

## គតិបណ្ឌិតកុង - ហ្វុងស៊ឺ

–អ្នកណាជាបណ្ឌិតកុង ហ្វុងស៊ឺ?

ប្រហែលជាង២០០០ឆ្នាំមកហើយ មានបណ្ឌិតមួយរូបនាមកុង–ហ្វុងស៊ឺ ជាមគ្គុទ្ទេសក៍យ៉ាងឆ្នើមនៃមនុស្សជាតិ ជាអ្នកទស្សនវិទូយ៉ាងឯក ។ ឧប្បត្តិឡើងនៅប្រទេសចិន ក្នុងគ.ស.៥៥២ គឺ ២០ ឆ្នាំ ក្រោយដែលព្រះអធិរាជចិនលិង វ៉ាង នៃសន្តតិវង្ស ចៅ សោយរាជសម្បត្តិ, ខ្លះថាលោកបដិសន្ធិក្នុងឆ្នាំ៥៥១ មុនគ្រិស្តសករាជ ដោយហេតុថា លោកមិនអាចបដិសន្ធិនៅឆ្នាំ៥៥២ ដែលមានសូរ្យគ្រាសដល់ទៅបីលើក ។ លោកស៊ូលីយេដឺម៉ូរ៉ង់ ជាអ្នកប្រែភាសាចិនទៅជាបារាំង បានកំណត់នាមលោកថា ក្រុងហ្វូត្សេ ប្រែថា បណ្ឌិតក្រុង, មានខ្លះថាលោកនាម ក្រុងត្សេ ។

គេបានដំណាលថា ជីតារបស់លោកកុង ហ្វុងស៊ឺ រាជការបានតែងតាំងជាចៅហ្វាយក្រុងតូចមួយឈ្មោះ ហ្វុង នៅក្នុងរដ្ឋលូ ។ ចៅលោកចៅហ្វាយក្រុងនាម ជូ-លៀង-ហ៊ី ដោយបានរៀបវិវាហ-

មង្គលជាមួយនឹងស្រីម្នាក់ រស់នៅដល់អាយុ ៧០ ឆ្នាំ មានសុទ្ធតែកូនស្រី ក៏ធ្វើពិពាហមង្គលនឹងស្រីម្នាក់ទៀតឈ្មោះនាង គ្វេង-ឆៃ ក៏បានបុត្រមួយនាម កុង–ហ្វុងសឺ ។

ក្រោយដែលបានរៀបការជាមួយបុរសនោះ អស់រយៈពេល ២-៣ ខែ, នាង គ្វេង-ឆៃ ក៏បានឡើងទៅលើភ្នំនីកៀវ ដើម្បីនឹងសុំព្រះជាម្ចាស់នូវបុត្រម្នាក់; ផលនៃពិធីបត្រឡប់មកវិញ, ពេលយប់ នាងយល់សប្តិឃើញព្រះអធិកសម្បុរខ្មៅមួយព្រះអង្គ ទ្រង់មានព្រះរាជឱង្ការមកកាន់នាងថា នាងឯងនឹងមានកូនប្រុសមួយជាបណ្ឌិត រួចនាងឯងត្រូវប្រសូតបុត្រនោះ នៅក្នុងរូងដែលគេហៅក្នុងដើមមន ។ ថ្ងៃមួយក្នុងកំឡុងដែលនាងមានគភ៌ នាងបាននិមិត្តឃើញ ទេវតាទាំង ៥ រូប គឺ អាកាស ភ្លើង ខ្យល់ ទឹក ដី មាននាគពិសដ្ឋមួយហែហមផង មកលុតជង្គង់ចំពោះមុខនាង ហើយព្រួសនូវត្បូងមួយចេញពីមាត់ដាក់ជើងនាង ។ គ្រាឡុកមើលទៅ ឃើញបណ្ណធ្វើពីថ្មយក់(១) ហើយមានចារឹកអក្សរថា «បុត្រានៃគុណសម្បត្តិ នឹងសោយរាជ្យដំណពីមន្តតិវង្ស ត្បៀវ ដែលនឹងធ្លាក់ចុះអាប់ឱនក្នុងអនាគត, បុត្រានោះនឹងទៅជាព្រះមហាក្សត្រឥតមកុដរាជ្យ ។ នាង គ្វេង-ឆៃ ក៏ស្ទុះ

(១) ថ្មមានសាច់រឹងមិនថ្លៃ មានពណ៌ខៀវឬស ជាតិចិនច្រើនយកថ្មនេះទៅកែច្នៃ ធ្វើជាគ្រឿងលំអផ្សេងៗ ។

យកកំណាត់សំពត់ចងស្នែងនាគពិសិដ្ឋនោះៗក៏រត់បាត់ទៅ ។ នាងក៏ភ្ញាក់ឡើង ។

នាងគួង-តៃ ហៅកុង-ហ្វូងសឺថា "ភៀវ ឬ គួងឌី" ដោយទើបដល់ភ្នំដែលនាងឡើងទៅបន់ ។ កុង-ហ្វូងសឺ កើតនៅកន្លែងមួយហៅថា "កុងទ័រ" ប្រែថា គុហាភ្នំ ឬកុងសាង ប្រែថា ដើមមនមានប្រហោង នៅក្នុងរជ្ជកាលព្រះមហាក្សត្រទី ២៣ នៃសន្តតិវង្សគ្រៀវ ។

កុង-ហ្វូងសឺ, នៅលើក្បាលមានសាច់ផតមួយកន្លែង ប្រៀបដូចភ្នំតូចដែលរក្សាទុកនៅទឹកពេលរដូវភ្លៀង, នៅចង្កេះក៏មានសាច់ផតដូចលលាដ៍ក្បាលដែរ ។ កុង ហ្វូងសឺ មានសម្បុរស្បែកខ្មៅ ហើយមានប្រាជ្ញា ។

កុង-ហ្វូងសឺ កាលពីកុមារពេញចិត្តខាងការគោរពដឹងសំដែងសេចក្ដីគួរសម ។ កុមារចេះបញ្ចេញអាកប្បកិរិយាធ្វើដំណើរទៅតាមវិធីបុណ្យមួយៗឲ្យបានសមរម្យ, ដូនកាលមុនប្រសប់ខាងការទទួលភ្ញៀវចេះរៀបចំទៅតាមឋានៈ តាមកិត្តិយស ក្មេង ជំទង់ ចាស់ ព្រឹទ្ធាចារ្យ ឬមន្ត្រីធំ-តូច ។

លុះកុង-ហ្វូងសឺអាយុបាន១៩ឆ្នាំ, គេបានធ្វើសមរសនឹងស្រីម្នាក់នៅក្នុងរដ្ឋសុង ។ អាពាហមង្គលនេះ នាំឲ្យបានបុត្រាម្នាក់ គមក

បានបុត្រម្នាក់ទៀត ។ បុត្រីរបស់លោកបានធ្វើអាពាហ៍ពិពាហ៍នឹងសិស្សរបស់លោកម្នាក់ឈ្មោះ កុង-ត្ស៊ី-ឆាង ។ លោកមានប្រសាសន៍ថា “ពិតមែនតែ កុង-ត្ស៊ី-ឆាង ជាប់ពន្ធនាគារ តែឈ្មោះនេះគ្មានបានប្រព្រឹត្តបទឧក្រិដ្ឋអ្វីសោះឡើយ , បានជាខ្ញុំអនុញ្ញាតឲ្យការនឹងកូនស្រីខ្ញុំ” ។

បណ្ឌិតកុង-ហ្វូស៊ឺ ជាអ្នកកាចរឹងរូសចំពោះខ្លួនលោក ខំព្យាយាមកែចរិយារបស់លោក ហើយលោកច្រើនពោលថា “ចូរអ្នកស្រឡាញ់នូវមនុស្សធម៌ តែកុំភ្លេចថា បើអ្នកចង់កុំឲ្យគេប្រព្រឹត្តទាំងធ្ងន់មកលើអ្នក ។ ត្រូវកុំប្រព្រឹត្តទាំងធ្ងន់ទៅលើអ្នកដទៃជាមុន” ។

ដល់លោកអាយុ ២០ឆ្នាំ , រាជការបានតាំងលោកឲ្យធ្វើជានាយកទ្វារបាលនៃជង្រុកសាធារណៈ ។ ក្នុងពេលនោះ លោកបានចុះបញ្ជីគណនីត្រឹមត្រូវ ហើយលោកកាន់សុចរិតពិតត្រង់ , ដល់ ២–៣ ខែក្រោយមក លោកធ្វើជាអ្នករក្សាវាលស្មៅ , ក្នុងឋានៈនេះ លោកបានថែរក្សាចៀមឲ្យមានសាច់ធាត់ធំ ។

លុះដល់អាយុ ២២ ឆ្នាំ , លោកទៅជាអ្នកតស៊ូខាងសង្គមកិច្ច ជាគ្រូបង្រៀននៃលទ្ធិបុរាណនិយម, ដោយលោកពោលថា:

“ពួកបុរាណមិនដែលបញ្ចេញសំឡេងឥតប្រយោជន៍ទេ ខ្លាចក្រែងសកម្មភាពដែលខ្លួនធ្វើមិនបានការ, ចិត្តស្មោះត្រង់ជាការប្រសើរ ត្រូវស្រឡាញ់អ្នកដទៃ ឲ្យដូចជាខ្លួនស្រឡាញ់ខ្លួនឯង” ។

ក្នុងការបង្រៀនកូនសិស្ស លោកយកថ្លៃឈ្នួល ទៅតាមឋានៈ កូនសិស្សមាន ឬក្រ ។

លំដាប់តមក លោកបានសរសេរសៀវភៅឈ្មោះថា "ឯកសារនៃនិទាឃរដូវនិងសរទរដូវ" ដែលលោកបានឲ្យយោបល់អំពីបញ្ហាសង្គមកិច្ចនិងទស្សនវិជ្ជា ហើយបង្ហាញថា សង្គមនៃប្រទេសចិនក្នុងពេលនោះ មានសភាពថោកថយជាខ្លាំង ព្រោះគ្មានន័យខាងកិត្តិ-យស សីលធម៌ និងនយោបាយសោះឡើយ ។ ការដែលចេញសៀវភៅនេះ នាំឲ្យលោកកុង-ហ្វូសឺ មានបច្ចាមិត្រជាច្រើន ព្រោះមន្ត្រីធំ-តូចដែលប្រព្រឹត្តបទទុច្ចរិតក្នុងពេលនោះ មានចិត្តភ័យតក់ស្លុតក្រែងគេដឹងចរិយារបស់ខ្លួន ។ តែមន្ត្រីទាំងនោះ ពុំទាន់មានពលកាពនៅឡើយ ហើយព្រះមហាក្សត្រនៃរដ្ឋលូ (រដ្ឋដែលលោកកុង-ហ្វូសឺស្ថិតនៅ) តែងត្រូវការ លោកខានមិនបាន ។ ព្រះមហាក្សត្រនៃរដ្ឋលូ មានព្រះរាជហឫទ័យខ្លាចព្រះមហាក្សត្ររដ្ឋជូ (រដ្ឋនេះ រាជធានីនាមថាឡូ) ។ នៅក្នុងរដ្ឋជូនេះ មានចាស់ព្រឹទ្ធាចារ្យម្នាក់ឈ្មោះ ឡៅ-ត្សឺ ជាអ្នកត្រួតត្រាឯកសារនៃព្រះអធិរាជចិន ជាអ្នកមានប្រាជ្ញា ហើយចេះដឹងវិជ្ជាច្រើនផង ។ ព្រះមហាក្សត្រនៃរដ្ឋលូ បានចាត់លោកកុង-ហ្វូសឺ ជាឯកអគ្គរាជទូតប្រចាំទីក្រុងឡូ ។

ពេលនោះ លោកកុង-ហ្វូសឺ មានអាយុ៦៧ឆ្នាំ លោកបានបង្រៀន

និស្សិតរបស់លោកថា "ធ្វើសកម្មភាពទើបបានផល" ។ ចំណែកលោកឡៅ-ត្សឺ បង្រៀននិស្សិតរបស់លោកថា: "ត្រូវប្រព្រឹត្តអកម្មភាពទើបបានផល" ។

គតិនៃលោកទាំងពីរ មានសភាពផ្ទុយគ្នាស្រឡះគឺថា បណ្ឌិតកុង-ហ្វូងស៊ឺយល់ថា "កិច្ចការទាំងឡាយត្រូវព្យាយាមធ្វើ ទើបបានសម្រេចប្រយោជន៍." បណ្ឌិតឡៅ-ត្សឺយល់ថា "ត្រូវអង្គុយឲ្យស្ងៀម ធ្វើសមាធិចិត្ត ហើយយកប្រាជ្ញាពិចារណាទើបបានសម្រេចប្រយោជន៍" ។

បណ្ឌិតឡៅ-ត្សឺបានពោលថា: ដើម្បីធ្វើប្រទេសឲ្យបានសន្តិសុខ ត្រូវបំបាត់នូវការរំដើបរំជួល,អ្នកណាមិនបានធ្វើចិត្តឲ្យស្ងប់ស្ងៀមអ្នកនោះមិនអាចគ្រប់គ្រងប្រទេសបាន, តើអ្នកណាអាចធ្វើចិត្តឲ្យបរិសុទ្ធបានដូចជាទឹកល្អក់ដែលគេដាក់ទុកឲ្យរងថ្លា, គុណធម៌ដ៏ឧត្តមប្រៀបដូចជាទឹកដូច្នោះ" ។

បណ្ឌិតឡៅ-ត្សឺ បានសួរបណ្ឌិតកុង-ហ្វូងស៊ឺថា: "ឯងបានឃើញផ្លូវហើយឬនៅ? ឯតាបានលះបង់រូបកាយ ក្នុងពេលដែលតាធ្វើដំណើរទៅក្នុងភូមិចិត្ត ចំពោះការរកបុព្វហេតុនៃធម៌ទាំងឡាយ" ។

លោកកុង-ហ្វូងស៊ឺតបថា: "ខ្ញុំបាទបានរកអស់រយៈវេលា២៧ឆ្នាំហើយ មិនឃើញសោះផ្លូវនេះ" ។

បណ្ឌិតឡៅ-ត្សឺពោលថា "បណ្ឌិតពេញចិត្តខាងការងងឹត, ការស្ងប់ស្ងៀម មិនផ្ដន់ខ្ទន់ដោយឥតពិចារណាទៅលើបុគ្គលណាមួយ តែងពិចារ-

ណាមួយកាលវេលាជាមិច្ច ។ បើពេលនិយាយទើបនិយាយ បើពេលមិនត្រូវនិយាយលោកនៅស្ងៀមស្ងាត់, កាលបើមានគេនរត្រូវមិនផ្សាយដំណឹងឲ្យអ្នកផងទាំងពួងដឹងឮទេ , បណ្ឌិតពិត ចេះពន្យល់បំភ្លឺវិជ្ជាមិនមួយៗ ចំពោះតែបុគ្គលណា។ ដែលអាចសិក្សារៀនសូត្របាន" ។

ក្រោយពេលដែលបណ្ឌិតគុង ហ្វូងស៊ី ត្រឡប់ពីរដ្ឋជូមកវិញ លោកបានចូលទៅក្រាបបង្គំទូលព្រះមហាក្សត្ររបស់លោកថា " សូមទ្រង់កុំព្រួយបារម្ភអ្វីឡើយ" ហើយលោកបានពណ៌នាអំពីអានុភាពប្រជារាស្ត្រ នាហ្មឺនតូចធំ បរិយាព្រះមហាក្សត្រ ។ល។ ក្នុងរដ្ឋនោះ ។

លំដាប់តមក លោកគុង ហ្វូងស៊ី បានឋានន្តរជានាយក្សាប្រាលជង្រុកស្រូវសាធារណៈ ។ ក្នុងពេលនោះ លោកខំព្យាយាមបង្កាត់ពូជមនុស្សសត្វ ដោយការសរសេរផ្សាយពត៌មាន ធ្វើសន្និសីទ ព្រមទាំងពន្យល់អំពីការអនុវត្តន៍នៃការបំបាត់ឡើបានជាធ្ងន់ ដល់អ្នកដែលប្រឹងប្រែងបំពេញករណីយកិច្ចរបស់ខ្លួនយ៉ាងពេញលេញ ។ លោកកំណត់នូវអត្រា-ពន្ធដារសត្វសាហារពើ មិនតែប៉ុណ្ណោះ លោកបានរៀបចំបទបញ្ញត្តិច្បាប់ស្តីអំពីវិវាហមង្គលនៃបុរសអាយុ៣០ឆ្នាំ នារីអាយុ ២០ ឆ្នាំ ស្រីមេម៉ាយនិងប្រុសពោះម៉ាយឲ្យមានរបៀបរៀបរយ ។

រាជការបានតែងតាំងលោកជានាយចាត់ការខាងពិធីបុណ្យសាសនា លោកបានរៀបចំនូវវិធានការណ៍ខាងការគួរសម ការយុត្តិធម៌ ទំនៀម

ខ្ជាប់ ប្រពៃណី ការប្រាស្រ័យរវាងស្តេច និង ប្រជារាស្ត្រ ស្វាមីនិង ភរិយា បិតាមាតា និង បុត្រាបុត្រី មិត្ត ចាស់ ក្មេង ណែនាំខាងក្បួន ពួកភាពសាស្ត្រជាដើម ។

លំដាប់តមក រាជការបានតែងតាំងលោកជានាយកខាងគង់វិភា សេះ មានការៈខាងត្រួតត្រាឃុំឃាំងគ្រឿងសស្ត្រាវុធនិងប្រមាញ់ ហើយ មានអំណាចដាក់ទណ្ឌកម្ម ចំពោះមន្ត្រីធំ-នាយទាហានឬនាយទាហាន រងដែលប្រព្រឹត្តបទល្មើសផ្សេងៗ ។

ក្រៅពីនេះ រាជការបានចាត់លោកឲ្យកាន់ដំណែងជានាយកចាត់ ការខាងកិច្ចការសាន្តផ្សេងៗ ។ ក្នុងពេលនោះ លោកបានប្រគល់ ការឲ្យគេធ្វើក្នុងពេលដែលកិច្ចការកសិកម្មបានធ្វើរួចហើយ គឺក្នុងពេល ដែលប្រជារាស្ត្រទំនេរ ព្រមទាំងឲ្យរង្វាន់ដល់ជនណាដែលចេះធ្វើ កិច្ចការល្អ និងពន្យល់ បំភ្លឺនូវមធ្យោបាយផ្សេងៗ ដើម្បីវឌ្ឍនភាពនៃ ឧស្សាហកម្ម និង សិប្បកម្ម ។

តមកទៀត លោកបានកាន់មុខងារខាងនាយកនៃក្រុមកំចាត់ពួក ពាលទុច្ចរិត គឺកាន់កាប់ខាងតុលាការ ធ្វើទណ្ឌកម្មដល់ពួកអ្នកប្រព្រឹត្ត បទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ផ្តន្ទាទោសពួកទាំងនោះ ពួក ផ្សាយដំណឹងអកុសល ។

លោកកុង ហ្វូងសឺ បានពន្យល់ពួកសិស្សថា " បទបញ្ញត្តិនៃការសក្ការដ៏ឧត្តមឬទស្សនវិជ្ជា ជាកិច្ចប្រតិបត្តិដែលត្រូវយកគោលការណ៍ប្រកបដោយវិចារណញាណរបស់ខ្លួនមករចនាឲ្យបានចំរើន, វិចារណញ្ញាណនេះ ជាការកែប្រែមនុស្សឲ្យមានចរិយាល្អ ហើយនឹងដឹកល់ដោតវាសនារបស់មនុស្សជាអវសានឲ្យបែតទៅជាសុក្រិតភាព ឬក្នុងមហាកុសល តាំងពីមនុស្សខ្ពង់ខ្ពស់ ដែលមានចរិយាថ្លៃថ្នូរហូតដល់ជនសាមញ្ញអ្នកថោកទាប ត្រូវមានករណីយកិច្ចស្មើគ្នាតែមួយគឺៈ កែប្រែបុគ្គលិកលក្ខណៈរបស់ខ្លួនឲ្យបានចំរើនជាតិរយៈភាពតទៅ ។ ការធ្វើខ្លួនឲ្យបានប្រកបដោយសុក្រិតភាពគឺជាមូលដ្ឋានដ៏សំខាន់នៃការចំរើនពិតប្រាកដ " ។

ពេលក្រោយមក មាតារបស់លោកទទួលអនិច្ចកម្ម លោកមានបំណងចង់យកសពមាតាលោក ទៅកប់ជិតកន្លែង ដែលកប់សពបិតាលោក នៅភូមិហ្វាងកង់ផ្លូ ។ លោកគិតថាជីវភាពរបស់លោក មិនស្ថិតថេរ គង់មួយកន្លែងតែងធ្វើដំណើរពីស្រុកមួយទៅស្រុកមួយ ។ ហេតុនេះ បានជាលោកមិនសាងផ្នូរសម្រាប់ដំកល់សពបិតាមាតាលោក គ្រាន់តែពូនដីឲ្យខ្ពស់បន្តិចស្រួលចំណាំតទៅអនាគត ។ លុះលោកពូនដីហើយ ស្រាប់តែរន្ទះបាញ់ទម្លាយផ្នូរទៅជាដីរាបស្មើទៅវិញ ។ លោកក៏ពិចារណាថា ការកែប្រែទម្រង់អ្វីមួយ ឲ្យខុសពីទំនៀមទម្លាប់ប្រពៃណីដើមដូចជា មិន

មែនធ្វើបានដោយងាយទេ មិនមែនមកពីហេតុខាងក្រៅឡើយ គឺមកពីព្រះជាម្ចាស់ជាហេតុខាងក្នុង ។

លោកបានពណ៌នាក្នុងសៀវភៅរបស់លោកមួយឈ្មោះ «ការសិក្សាដ៏ធំទូលាយ» មានសេចក្តីថា «សិក្សាដោយគ្មានគិតពិចារណា រមែងខាតពេលវេលាឥតប្រយោជន៍, គិតពិចារណាដោយគ្មានការសិក្សា រមែងកាន់ច្រឡំជាខ្លាំង» ។ ក្នុងពេលនោះ លោកបានស្ថាបនាសាលារៀនមួយឈ្មោះថា «សាលាសិក្សាខាងរបៀប យុត្តិធម៌, សុចរិតនិងការស្និទ្ធស្នាល» ។ ពេលនោះ មានសាវ័កខ្លះ ព្រមទាំងនិស្សិត ៣០០ នាក់ ចូលមកសិក្សាក្នុងសាលានោះ ។ កូនសិស្សដែលមកពីប្រទេសឆ្ងាយ ឬក្នុងខេត្តនៃប្រទេសចិន តែងមកសុំគេហដ្ឋានរបស់លោកសំណាក់អាស្រ័យ ។

លោកកុង ហ្វូងស៊ីបានពន្យល់កូនសិស្សនិងសាវ័ករបស់លោក នូវទាំងជាច្រើនបែបច្រើនយ៉ាង ។ ទាំងនោះ គឺលោកធ្វើអត្ថាធិប្បាយពាក្យសុភាសិតបណ្ឌិតបុរាណដែលលោករៀបចំតាមសកាលគុណៈ បទបែបគាថាជាដើម ។ ទាំងនេះ លោកបានប្រមូលយកទៅធ្វើជាសៀវភៅបាន ៤ក្បាលគឺ :

១–យី-គីង សៀវភៅពណ៌នាអំពីបវបញ្ញត្តិច្បាប់ផ្លាស់ផ្តូរកម្មសិទ្ធិអសំហារិមៈ ។

២- ជូ-គីជ សៀវភៅប្រវត្តិសាស្ត្រ ។

៣- ចេ-គីជ សៀវភៅតែងកាព្យឃ្លោង ។

៤- យូ-គីជ សៀវភៅពណ៌នាអំពីទំនៀមទម្លាប់ប្រពៃណីទីន ក្រុង ។

ពេលនោះ ប្រទេសចិន មានការចលាចលជាច្រើនកន្លែង រដ្ឋមន្ត្រីធ្វើឃាតកម្មព្រះអង្គម្ចាស់, កូនសំឡាប់ឪពុក ។ លោកកុង-ហ្វូស៊ី មានចិត្តរំជួលជាខ្លាំង ហើយដើម្បីទប់ស្កាត់ នូវការចលាចលទាំងនេះ លោកបាននិពន្ធសៀវភៅមួយឈ្មោះថា "ជូនែនស៊ីវ" ឯកសារនិទាឃ-រដូវនិងសរទរដូវ ។ ក្រោយមក មានពួកគ្រួសារខាងស្តេចត្រាញ់ប៉ុប បង្កឲ្យកើតការបះបោរឡើង (គ.ស. ៥១៣) ។ ព្រះមហាក្សត្ររដ្ឋលូ ត្រូវរត់ចេញពីរដ្ឋទៅពួននៅទីដទៃ ។ មានពួកមួយក្រុមមិនគំនិតគាំគិតធ្វើឃាតកម្មលោកកុង-ហ្វូស៊ី ។ គាត់រត់ចេញពីរដ្ឋលូ ទៅនៅឯរដ្ឋត្សី, ទីក្រុងឈ្មោះតិងស៊ី ។ នៅទីនោះ លោកបានចងមេត្រីនិងចាង-ហ្វាងកុង ហើយបានចូលទៅគាល់ព្រះមហាក្សត្ររដ្ឋត្សី ។ ព្រះមហាក្សត្រអង្គនេះ ទ្រង់សព្វព្រះរាជហឫទ័យតាំងលោកធ្វើជាទីប្រឹក្សា ។

ពេលនោះ លោកបានផ្សាយនូវបុរាណសុភាសិត ហើយបានកំណត់កម្មវិធីកែទម្រង់ទំនៀមទម្លាប់បុរាណ ។ តែលោករដ្ឋមន្ត្រីមួយពុំព្រមតាម ហើយចោទប្រកាន់លោកថា "លោកយកបុរាណជាធំ ដើម្បីបន្ទុះបង្អាប់បច្ចុប្បន្នសម័យ, ពោលពាក្យសព្ទអតីតកាល ដើម្បី

បះញ្ញាសេចក្តីអាក្រក់ក្នុងបច្ចុប្បន្នកាល » ។

ព្រះមហាក្សត្រនៃរដ្ឋឆី ទ្រង់យល់ស្របតាមលោករដ្ឋមន្ត្រីទាំង ទ្រង់ព្រះពិរោធនឹងលោក កុង-ហ្វូងសឺ ជាខ្លាំង ។ លោកកុង-ហ្វូងសឺ បានចាកចេញពីរដ្ឋឆី វិលត្រឡប់មកកាន់រដ្ឋលូវិញ ។ នៅរដ្ឋលូមានសង្គ្រាមពលរដ្ឋនៅឡើយ ។ ពួកមន្ត្រីធ្វើបាបពស្ត្រូវតូចតាច ។

លុះលោកអញ្ជើញមកដល់រដ្ឋលូ, សាលាចាស់រៀបអប់រំយុត្តិធម៌ និងសុចរិតធម៌ ត្រូវរាជការលុបចោលជាអសារបង់ ។ លោកកុង-ហ្វូងសឺ ក៏បិតនៅឆ្ងាតពីជីវភាពសាធារណៈ, តែប្រាជ្ញារបស់លោក ក៏ផ្សាយទូទៅលាន់ឮឡើង, មានពួកបះបោរ ក្រុមមន្ត្រីភាគីអាក្រក់ក្រសួងបានប្រើឧបាយដឹកនាំលោកឱ្យចូលបក្សពួករបស់ខ្លួន តែលោកមិនព្រមចូល បើទុកជាអ្នកណាពោលពាក្យពីរោះពីសាយ៉ាងណាក៏ដោយ ក៏លោកមិនព្រមចូលជាដាច់ខាតអស់រយៈវេលា ១៥ ឆ្នាំ ។

មានថ្ងៃមួយ ជាឱកាសល្អ គឺរដ្ឋលូបិតនៅក្នុងសន្តិភាព គ.ស. ៥០០ ។ រាជការបានអញ្ជើញលោកឱ្យកាន់ដំណែងជាចៅហ្វាយក្រុង តួង-ទូ ។ លោកក៏ព្រមទទួលធ្វើ, កាលនោះលោកមានអាយុ ៥២ ឆ្នាំ, ដោយសារប្រាជ្ញារបស់លោក, ព្រះឥទ្ធិទ័ង ព្រះចៅរដ្ឋលូ ក៏តែងតាំងលោកក្នុងឋានន្តរសក្តិកាន់តែខ្ពស់ឡើង ១ តាំងពីចាងហ្វាងកសាន្ត ចាងហ្វាងពួកពលទុច្ចរិត ទីបំផុតជាឧបកាជនៃរដ្ឋលូ គ.ស. ៤៩៧ ។

បណ្ដាក្សត្រ មានសេចក្ដីសរសើរបណ្ឌិតកុង-ហ្វូសឺពន់ពេក ។ រដ្ឋលូទៅជារដ្ឋមួយ ប្រកបដោយសម្បូណ៌ភាព នឹងគេជាទុភាពយ៉ាងអស្ចារ្យ ។

មានរដ្ឋដទៃ ប្រាថ្នាចូលមកលុកលុយរដ្ឋលូ, តែបណ្ឌិតកុង-ហ្វូសឺបានចាត់ឲ្យកងទ័ពទៅបង្រ្កាបពាល់តែស្ងប់ស្ងាត់ ។

តាមក្បួនរណសាស្រ្តចិន បានពណ៌នាប្រវត្តិសាស្រ្តប្រទេសចិនរបស់លោកស៊ូលីយេដឺម៉ូរ៉ង់ត៍ មានក្បួនរណសាស្រ្តលោកមេទ័ពស៊ុន-ត្ស ជាដើមបានពោលថា ៖

“ រក្សាថែទាំប្រទេសជាទី ១, បំផ្លាញប្រទេសដែលជាសត្រូវជាទីពីរ, ច្បាំង ១០០ ដង ជោគជ័យ ១០០ ដង ពុំប្រសើរទេ ការដែលប្រសើរនោះគឺ ធ្វើកងទ័ពរបស់សត្រូវឲ្យបែកនៅបាននឹងមួយកន្លែងគ្មានច្បាំង, បើកងទ័ពបច្ចាមិត្រមានកម្លាំង ១០ ភាគលើសកងទ័ពខ្លួន ត្រូវចាត់កងទ័ពឲ្យទៅឡោមព័ទ្ធកងទ័ពបច្ចាមិត្រ, បើកងទ័ពបច្ចា-មិត្រមានកម្លាំង ៥ ភាគលើសកងទ័ពខ្លួន ត្រូវនាំកងទ័ពទៅវាយតែមួយភាគ, បើកងទ័ពសត្រូវមានកម្លាំងតែពីរភាគ ត្រូវបំបែកកងទ័ពរបស់ខ្លួនជាពីរផ្នែកគឺ: មួយផ្នែកសម្រាប់ទប់កងទ័ពសត្រូវឲ្យនៅនឹងមួយកន្លែង មួយផ្នែកទៀត សម្រាប់វាយលុកចូល ។ អ្នកណាស្គាល់ពេលវេលាដែលត្រូវនាំកងទ័ពទៅច្បាំងអ្នកនោះនឹងមានជ័យជំនះ, អ្នកណាប្រើយុះ

វេលាជាច្រើនឆ្នាំ ដើម្បីនឹងធ្វើសង្គ្រាម អ្នកនោះមិនស្រឡាញ់ប្រជារាស្ត្រ ឈ្មោះថាជាសត្រូវនៃប្រទេសរបស់ខ្លួន, ធ្វើសង្គ្រាមដោយវិធីឡោមព័ទ្ធ នឹងការគេស៊ើបលុកចូលដើម្បីឲ្យបានជោគជ័យ ឈ្មោះថា មិនចេះធ្វើសង្គ្រាមទេ. អ្នកណាដែលគិតតែបំផ្លាញទីក្រុងនិងកងទ័ពសត្រូវ អ្នកនោះហៅថាល្ងង់, ការប្រសើរគឺ ចេះវៃលកឲ្យបានទីក្រុងនោះមកបិតនៅក្នុងកណ្ដាប់ដៃយើងឬកងទ័ពសត្រូវឲ្យបាក់បបខ្ចុបខ្ចាប ៗ ព្រោះហេតុដូច្នោះ យើងត្រូវប្រើមធ្យោបាយគ្រប់យ៉ាងប្រសើរជាងធ្វើសង្គ្រាម ៗ ច្បាំងហើយបានជោគជ័យ គឺបន្ថយកម្លាំងរបស់ខ្លួន ដោយពុំឃាតពួកទាហានរបស់ខ្លួន, ត្រូវវៃលកឲ្យបានកម្លាំងនិងសីលធម៌ ចំនួនទាហានឲ្យច្រើន ស្គាល់ទ័ពនឹងគ្រឿងសស្ត្រាវុធឲ្យបានប្រែកប្រទៅតាមកាលៈទេសៈ ជាការប្រសើរពន់ពេក អ្នកណាហ៊ានមកធ្វើសង្គ្រាមចំពោះកងទ័ពបែបនេះ ហៅថា ឆ្កួត" ៗ

ក្នុងពេលនោះ ព្រះមហាក្សត្រនៃរដ្ឋវ៉ូវទ្រង់ព្រះនាម គីង ដោយមានរដ្ឋមន្ត្រីរបស់ព្រះអង្គចាក់រុក ក៏លើកកងទ័ពមកវាយរដ្ឋលូមានជ័យជំនះ តែពួកប្រជារាស្ត្រនៅរដ្ឋលូ បានយកលទ្ធិកុង-ហ្វូស៊ឺមកគត់ ៗ ព្រះចៅគីង ក៏ព្រមថ្វាយរដ្ឋលូមកព្រះមហាក្សត្ររដ្ឋនេះវិញ ៗ

តាំងពីនោះមក អានុភាពរបស់បណ្ឌិត កុង-ហ្វូស៊ឺ ក៏ផ្សាយពេញប្រទេសចិនទាំងមូល ៗ តែបច្ចាមិត្រនៃបណ្ឌិត កុង-ហ្វូស៊ឺ ក៏មិនលះបង់

ការគំនុំគុំទួនគេកេះ, ពួកវា មិនចង់ត្រឹមតែហូតឆ្ការបណ្ឌិត កុង-ហ្វូសឺពីដំណែងជាទេបកជនៃរដ្ឋលូប៉ុណ្ណោះទេ ថែមទាំងចង់បំផ្លាញនូវសាវករបស់លោកពីរនាក់ទៀតគឺ លោកត្សឺ-លូ និងលោកត្សឺ-យូ ដែលបិតនៅក្នុងដំណែងជាន់ខ្ពស់ទៀតផង ។ ហេតុនេះហើយបានជា ពួកបច្ចាមិត្តរបស់លោក បានចូលទៅចងស្ពានមេត្រីនឹងព្រះចៅរដ្ឋត្សី ។ មានទីប្រឹក្សារបស់ព្រះចៅរដ្ឋត្សី ទូលព្រះមហាក្សត្រឲ្យនាំស្រីប៉ុនឹងក្រុមក្មេងចំនួន៨០នាក់ ដែលមានរូបឆោមល្អទៅថ្វាយព្រះចៅរដ្ឋលូ ។ ព្រះចៅរដ្ឋលូដោយត្រេកអរនឹងនាងនារីទាំងឡាយ ក៏ភ្លេចកិច្ចការផែនដី ។ ក្នុងពេលនោះ ពួកបច្ចាមិត្តបណ្ឌិត កុង-ហ្វូសឺ ក៏ឆ្លៀតឱកាសក្រាបបង្គំទូលព្រះមហាក្សត្រ ចង់ ។ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យផង បានហូតឆ្ការលោកកុង-ហ្វូសឺ ចេញពីដំណែងជាមហាទេបកជ ។

បណ្ឌិត កុង-ហ្វូសឺ លុះខាតចេញពីដំណែងទេបកជនៃរដ្ឋលូហើយក៏ធ្វើដំណើរពីរដ្ឋមួយ ទៅរដ្ឋមួយ ត្រាច់រង្គាត់តាមនិគមជនបទពន្យល់បក្ខអ្នកស្រុកថា: មនុស្សមាន ៦ ថ្នាក់គឺ:

ថ្នាក់ទី ១ - មុននឹងតាំងខ្លួនជាបណ្ឌិត, ត្រូវសិក្សានូវវិជ្ជាទាំងឡាយព្រមទាំងពិចារណានូវវិជ្ជាទាំងនេះ ឲ្យបានយល់សព្វគ្រប់ ហើយធ្វើនូវបេសកកម្មបង្ហាញនូវសមត្ថភាពរបស់ខ្លួន ។

ថ្នាក់ទី ២- ត្រូវបង្ហាត់បង្ហាញនូវវិជ្ជាទាំងឡាយដល់អ្នកដទៃឲ្យបាន

ចេះរាំស្អាត់ តែហាមកុំឲ្យត្រូតត្រាបផ្ទាប់ឲ្យសោះ ។

ថ្នាក់ទី ៣ - ត្រូវត្រាច់តាម "ភាវ" គឺពស់នាគរាជដែលចូលមកបំភ័ន នៅក្នុងខ្លួនយើង ហើយបញ្ចេញអានុភាពជាខាងក្រោយ (ថ្នាក់នេះ ប្រហែលជាចង់ថា បើមានវិជ្ជាគ្រប់គ្រាន់ហើយ ត្រូវប្រព្រឹត្តប្រតិបត្តិតាមវិជ្ជានោះឲ្យ ទាល់តែសម្រេចនូវលទ្ធផលដ៏ប្រសើរ ) ។ ភាវនេះ បើតាមយល់របស់ខ្ញុំ គឺ "ផ្លូវ" ។

ថ្នាក់ទី ៤ - មនុស្ស- នាគ ត្រូវបង្ហាត់ខ្លួនឲ្យចំរើនសតិប្រាជ្ញាឲ្យបាន ខុសពីមនុស្សធម្មតា ដើម្បីធ្វើការជាប្រយោជន៍មនុស្សជាតិទីផែនដី ។

ថ្នាក់ទី ៥- មនុស្ស-នាគ ចេះពេញលក្ខណៈប្រព្រឹត្តប្រតិបត្តិត្រឹមត្រូវតាមលទ្ធិកុង-ហ្វូស៊ីហើយ ញ៉ាំងអ្នកដទៃឲ្យប្រតិបត្តិតាមៈហៅថា ឧត្តមមនុស្ស ។

ថ្នាក់ទី ៦- មនុស្ស- នាគ ពោះពារ បង្ហាត់ខ្លួនឲ្យមានលំអ សច្ចធម៌ សុចរិតគ្រប់យ៉ាង លែងភ័យ លែងខ្លាច, គឺខ្លួនបានធម៌ ហើយ ញ៉ាំងអ្នកដទៃឲ្យបានធម៌ផង ។

ចាប់តាំងពីនោះមក លោកកុង-ហ្វូស៊ី បានត្រាច់ទៅក្នុងរដ្ឋវៃ, រដ្ឋត្រេន, រដ្ឋត្សៃ, រដ្ឋឆ្វេង; លោកនៅក្នុងរដ្ឋឆ្វេងអស់រយៈវេលា ៣ ឆ្នាំ ។ នៅក្នុងរដ្ឋណាក៏ដោយ លោកជួបប្រទះតែនឹងអំពើពាលទុច្ចរិតគ្រប់យ៉ាងគឺ: មនុស្សប្រព្រឹត្តអបាយមុខ, ពួកអសប្បុរស' មនុស្ស

វែនប្រព្រឹត្តតាមច្បាប់រដ្ឋ, និងមនុស្សមានតែចិត្តបាបអកុសល ។

លុះពេលគេអញ្ជើញទៅដល់រដ្ឋឆ្វុមាន, លោកត្រូវពួកការនៃរដ្ឋនោះ ចាប់ខ្លួនលោកទៅដាក់គុក, តែមិនយូរប៉ុន្មាន លោកបានរួចពីការឃុំឃាំងធ្វើដំណើរទៅដល់រដ្ឋត្រូន ក្នុងខែត្រកៃ-ហូន-ហ្វិ, ក្រោយមកលោកបានអញ្ជើញទៅដល់រដ្ឋស៊ុន ដែលជារដ្ឋរបស់ជីដូនជីតាលោក ។ នៅទីនេះ លោកត្រូវនាយពាហានជាន់ខ្ពស់ម្នាក់ ដែលជាបច្ចាមិត្ររបស់លោក ចង់ពិឃាតលោក តែមិនសម្រេចដូចបំណង ។ រួចលោកបានបន្តដំណើរមកដល់រដ្ឋត្រៃ ។

ក្នុងពេលនោះ មានសង្គ្រាមកើតឡើងរវាងរដ្ឋវុ និងរដ្ឋត្រូន ។ ព្រះមហាក្សត្រនៃរដ្ឋឆ្វុ ដែលបានចងស្ពានមេត្រីនឹងមហាក្សត្ររដ្ឋត្រូន ទ្រង់បានជ្រាបថា បណ្ឌិតកុង-ហ្វូងស៊ី ឋិតនៅរវាងភូមិភាគរដ្ឋត្រូននិងត្រៃ ទ្រង់ចាត់កងទូតឲ្យនាំបណ្ណាការទៅជូនបណ្ឌិតកុង-ហ្វូងស៊ី ដើម្បីអញ្ជើញឲ្យមកធ្វើជាទីប្រឹក្សារបស់ព្រះអង្គ ។ បណ្ឌិតកុង-ហ្វូងស៊ី កំពុងរៀបចំថានឹងចេញដំណើរទៅ ប៉ុន្តែ ពួកសាវករបស់លោកឃាត់ថា មានគេនិងពលត្រូវចាំឆ្មក់កណ្តាលផ្លូវប៉ុនប៉ងនឹងពិឃាតលោក ។ ក៏កាត់ខានអញ្ជើញទៅ ។ លោកមានអាយុ ៦៣ ឆ្នាំហើយ លោកបានវិលត្រឡប់មកកាន់រដ្ឋវិញ ។

(មានត)

# សុចរិតនិងទុច្ចរិត-រឿងព្រេងរុស្ស៊ី

អ្នកស្រី ស-សាក ប្រែរៀបរៀង

លោក ប៊ូ-ប៉ូ ពិនិត្យកែសម្រួល

---

ថ្ងៃមួយ មានបុរសអ្នកស្រែពីរនាក់និយាយដដែកគ្នាអំពីសុចរិតនិងទុច្ចរិត ដូចមានសេចក្ដីតទៅនេះ ៖

បុរសម្នាក់ ជាមនុស្សពាលប្រព្រឹត្តតែអំពើទុច្ចរិត រកបានមួយថ្ងៃ ស៊ីតែមួយថ្ងៃ ដោយអំពើវៀចគ្រប់យ៉ាង នៅខ្វះតែអំពើលួចប្លន់គេមួយយ៉ាងប៉ុណ្ណោះ ។

បុរសម្នាក់ទៀត ជាបណ្ឌិតប្រព្រឹត្តតែអំពើសុចរិតជានិច្ច ។ អ្នកទាំងពីរដើរមកជួបប្រទះគ្នានៅនាកណ្ដាលផ្លូវ ក៏និយាយសាកសួរសុខទុក្ខគ្នាអំពីរបៀបចិញ្ចឹមជីវិតរៀងខ្លួន ។

បុរសពាល និយាយថា ខ្ញុំចូលចិត្តតែចិញ្ចឹមជីវិតដោយអំពើទុច្ចរិត ភូតកុហកបោកប្រាស់គេជានិច្ចកាល ។

បុរសបណ្ឌិតឆ្លើយថា មិនដែលមានអ្នកណាចេះតែភូតកុហកបោកប្រាស់គេបានរាល់ថ្ងៃទេ, ចំណែកខ្ញុំវិញ ខ្ញុំស៊ូទ្រាំចិញ្ចឹមជីវិតដោយអំពើសុចរិត ទោះបីលំបាកវេទនាយ៉ាងណាក៏ដោយចុះ ឲ្យតែធ្វើតាមសេចក្ដីពិតត្រង់ ។

បុរសទាំងពីរនាក់ ជជែកគ្នាដណ្ដើមយកត្រូវតែរៀងខ្លួន មិនព្រមចាញ់គ្នាទៅវិញទៅមក មិនចុះសម្រុងគ្នាសោះ ទើបស្រុះចិត្តព្រមគ្នាថា "យើងត្រូវតែដើរសួរស្វែងរកមនុស្សដទៃទៀត ប្រាប់គេឲ្យជួយដោះស្រាយរកខុសត្រូវរឿងយើងទាំងពីរនាក់" និយាយរួចក៏នាំគ្នាធ្វើដំណើរទៅ ។

បុរសពីរនាក់បណ្ដើរគ្នាទៅមិនយូរប៉ុន្មាន បានជួបប្រទះនឹងអ្នកស្រែម្នាក់កំពុងភ្ជួរស្រែ ទើបដើរដម្រង់ទៅដល់ហើយសួរថា ៖

បពិត្រអ្នកដ៏ចំរើន ! សូមអ្នកមេត្តាកាត់សេចក្ដីខុសត្រូវឲ្យយើងខ្ញុំបន្តិចមើល នៅក្នុងសកលលោកនេះ ការចិញ្ចឹមជីវិតដោយអំពើសុចរិតនឹងដោយអំពើទុច្ចរិត តើអំពើណាប្រសើរជាង ? យើងខ្ញុំជជែកគ្នាមិនដាច់ស្រេចសោះ ។

អ្នកស្រែឆ្លើយថា ៖

–នែអ្នកទាំងពីរ ! អំពើសុចរិតយុត្តិធម៌មិនងាយនឹងជួយចិញ្ចឹមជីវិតយើងបានទេ យើងត្រូវតែប្រព្រឹត្តចិញ្ចឹមជីវិតដោយអំពើទុច្ចរិតអយុត្តិធម៌វិញ ទើបបានស្រួលរស់នៅក្នុងលោកនេះបានដោយងាយ ព្រោះអំពើសុចរិតយុត្តិធម៌ប្រៀបដូចអ្នកពាក់ស្បែកជើងសំពត់ស្តើងទន់ ដើរមិនបានវែងឆ្ងាយទេ; ឯអំពើទុច្ចរិតអយុត្តិធម៌ប្រៀបដូចអ្នកពាក់ស្បែកជើងយ៉ាងក្រាស់ជាប់មាំ អាចដើរបានវែងឆ្ងាយណាស់ បើទុកជាដើរទៅជាន់លើ

ចំរូងចន្ទា កំមិនមុតបាតជើងដែរ បេះតែទៅរួចហូត ៗ អ្នកធ្លាប់ដឹងឬទេ ? កូនប្រទេសយើងសព្វថ្ងៃនេះ ពួកចោរបាតដែលជាម្ចាស់យើង គេគិតតែតឹងទារយកផលប្រយោជន៍អំពីយើងឲ្យពេញ ១ ៗ កូនមួយថ្ងៃៗ ឥតឲ្យខ្វះកន្ទះទេ? យើងកៅតែពេលចំនេរទឹងបំពេញផលប្រយោជន៍របស់ខ្លួនពុំបានសោះ, ដូច្នេះ យើងត្រូវតែពុតធ្វើជាឈើ ដើម្បីនឹងលួចបន្តិចចូលទៅរកកាប់ឈើកូនព្រៃនៅពេលថ្ងៃ បើគេដឹងពុតយើងហើយ គេហាមប្រាមមិនឲ្យយើងធ្វើដូច្នោះទៀត យើងលួចទៅធ្វើនៅវេលាយប់វិញ ៗ

- ហាំ! មើចទៅ ឯងឮឬទេ ? ឯងដឹងថាអញយល់ត្រូវមែនឬទេ ?

(បុរសពាលសួរបុរសបណ្ឌិត) ៗ

បុរសទាំងពីរនាក់ នៅមិនទាន់អស់ចិត្ត កំបបួលគ្នាដើរទៅមុខទៀត លុះដើរទៅបានបន្តិច ជួបនឹងឈ្មួញរទេះម្នាក់ ស្រែកហៅថា ៖

សូមអ្នកឈប់បន្តិចសិន ព្រោះយើងខ្ញុំចង់សួរប្រស្នានឹងអ្នកបន្តិច បើអ្នកអនុញ្ញាតឲ្យសួរបាន ? យើងខ្ញុំទឹកសង្ស័យថា កូនលោកនេះ មនុស្សយើងត្រូវចិញ្ចឹមជីវិតដោយអំពើសុចរិត ឬ ទុច្ចរិត ?

អ្នកជំនួញថា នែអ្នកអើយ ! អំពើសុចរិតធ្វើឲ្យយើងចិញ្ចឹមជីវិតដោយលំបាកណាស់ ត្រូវតែយើងគេស៊ូចិញ្ចឹមជីវិតដោយអំពើទុច្ចរិតវិញ ដ្បិតថា បើគេកុហកបញ្ឆោតបោកប្រាស់យើងហើយ យើងក៏ត្រូវបញ្ឆោតបោកប្រាស់គេវិញដែរ ៗ

បុរសពាល– ម៉េចឯងថាទេ? អញគិតត្រូវមែនឬទេ? អ្នកទាំងពីរមិនទាន់យល់ស្របគ្នាសោះ ទើបប្រឹក្សាគ្នាថាយើងត្រូវទៅរកសួរអ្នកណាម្នាក់ទៀត ឲ្យបានតំរប់បីនាក់ ដើម្បីឲ្យអស់ចិត្តអំពីប្រស្នារបស់យើង ទើបនាំគ្នាដើរទៅមុខទៀត លុះតែដើរយូរ ៗ ទៅ បានជួបនឹងសេដ្ឋីម្នាក់ ហើយនិយាយថា ៖

–សូមលោកអាណិតមេត្តាឈប់បន្តិចសិន យើងខ្ញុំសុំសួរលោកអំពីប្រស្នាមួយថា “ មនុស្សយើងសព្វថ្ងៃនេះ ត្រូវរកស៊ីចិញ្ចឹមជីវិតតាមអំពើសុចរិតស្រួលជាង ឬតាមអំពើទុច្ចរិតស្រួលជាង?

សេដ្ឋី– ប្រស្នាអ្នកពីរោះណាស់ អ្នកកុំឆ្ងល់គឺ ការរកស៊ីចិញ្ចឹមជីវិតដោយអំពើទុច្ចរិតប្រសើរជាងអំពើសុចរិត ក្នុងលោកនេះ អ្នកទៅរកសុចរិតឯណាឃើញ បើអ្នកឯងនិយាយពិតត្រង់ មុខជាគេបញ្ជូនខ្លួនទៅស្រុកស៊ីបេរី (Sibérie) ហើយ ហើយគេចោទថាយើងកុហកគេថែមទៀតផង ។

បុរសពាល– ទឺ ឯងថា! អ្នកណាក៏គេថាដូច ៗ គ្នាដែរ យើងសួរមនុស្សបីនាក់ហើយ គេឆ្លើយតែរបៀបមួយទៅលើទុច្ចរិតពលមាត់ថា ការរស់នៅដោយអំពើទុច្ចរិតគ្រាន់បើស្រួលជាងរស់នៅដោយអំពើសុចរិត ។

បុរសបណ្ឌិត– ទេ! ទេ! អញមិនយកទេ! អញយកតែខាងសុចរិត ទុកជាអញលំបាកលំបិនយ៉ាងណាក៏ដោយ ក៏អញមិនព្រមរកស៊ីតាមអំពើទុច្ចរិតដែរ ។

បុរសទាំងពីរនាក់ និយាយគ្នាដូច្នោះហើយ ក៏នាំគ្នាដើរទៅស្វែងរកធ្វើការងារដោយចិញ្ចឹមជីវិតទាំងពីរនាក់ ។ បុរសពាលចេះតែបំបែរចិត្តឲ្យទៅតាមកាលៈទេសៈនិងតាមកិច្ចការ ហើយទៅដល់ទីណា ក៏ចេះតែមានមនុស្សឲ្យបាយទឹកបរិភោគឥតខ្វះដែរ ហើយឥតគិតថ្ងៃទៀតផង ។ ចំណែកបុរសបណ្ឌិត គឺខំធ្វើការងារយកបាយទឹកចិញ្ចឹមជីវិតខ្លួនពល់ថ្ងៃ ដោយសេចក្ដីពេញចិត្ត នឹងអំពើសុចរិតរបស់ខ្លួនជានិច្ចកាល ។

ថ្ងៃមួយ នៅគ្រាដែលបុរសបណ្ឌិតធ្វើដំណើរទៅតាមផ្លូវក៏ទីកឃ្លានបាយជាខ្លាំង ទើបនិយាយនឹងបុរសពាលជាសំឡេងថា ៖

– ចូរឯងការណ៍គអញ ឲ្យនំបុ័ងមួយដុំមកអញស៊ីផង ។

បុរសពាល – ចុះឯងឲ្យអ្វីជាសំណងមកអញវិញ ?

បុរសបណ្ឌិត – បើឯងចង់បានអ្វី ស្រេចនៅចិត្តឯងយកចុះ ។

បុរសពាល- អើ ! បើឯងថាអ៊ីចឹង អញត្រូវធ្មៀលយកគ្រាប់ភ្នែកឯងម្ខាង ។

បុរសបណ្ឌិត- អើ ! មិនជាអ្វីទេ អញព្រមឲ្យធ្មៀលតាមចិត្តឯង ។

បុរសពាលក៏ធ្មៀលយកគ្រាប់ភ្នែកម្ខាងរបស់បុរសបណ្ឌិត រួចឲ្យនំបុ័ងមួយដុំទៅបុរសបណ្ឌិត ហើយនាំគ្នាដើរទៅមុខទៀត ។

ថ្ងៃក្រោយមកទៀត បុរសបណ្ឌិតឃ្លានខ្លាំង ពាល់តែអត់ទ្រាំពុំបាន ក៏សុំនំបុ័ងពីបុរសពាលមួយដុំទៀត ។

បុរសពាល- បើដូច្នោះ អញត្រូវតែឆ្កៀលយកគ្រាប់ភ្នែកឯងម្ខាងទៀត ។

បុរសបណ្ឌិត ឱ! សំឡាញ់អើយ សូមអាណិតអាសូរអញផង បើឯងឆ្កៀលភ្នែកអញម្ខាងទៀត មុខជាអញខ្វាក់លែងឃើញអ្វីសោះហើយ ។

បុរសពាល- ឯងខ្វាក់ទៅជាអ្វីក៏ដោយ បើឯងចូលចិត្តតែរស់នៅដោយសារអំពើសុចរិតដូច្នេះហើយ ឯងខ្លាចខ្វាក់អីទៀត ។

បុរសបណ្ឌិត- ដញ្ចឹងគិតថា ធ្វើម្ដេចឥឡូវ បើឯងឃ្លានបាយស្ទើរដាច់ខ្យល់ ពាល់តែទ្រាំអត់មិនបានហើយ, គិតរួចប្រាប់ថា ណ្ហើយចុះសំឡាញ់! បើឯងមិនខ្លាចកម្មពៀរវេរាទេ ចូរឯងឆ្កៀលយកគ្រាប់ភ្នែកអញម្ខាងទៅទៀតចុះ ។

បុរសពាលក៏ឆ្កៀលភ្នែកបុរសបណ្ឌិតម្ខាងទៀត រួចឲ្យនំបុ័ងមួយដុំ ហើយប្រាប់ថា អញមិនដឹកដៃឯងទៅទេ, ត្រូវឯងនៅទីនេះចុះ ចង់ទៅឯណាតាមចិត្តឯង អញលែងនៅជាមួយឯងទៀតហើយ ការមនុស្សខ្វាក់យ៉ាងនេះ នឹងបានជាការអ្វី ថាប៉ុណ្ណោះក៏ដើរចោលបុរសបណ្ឌិតបាត់ទៅ ។

ចំណែកបុរសបណ្ឌិតខ្វាក់ភ្នែកទាំងគូលែងឃើញអ្វីសោះ បាននំបុ័ងមួយដុំបរិភោគអស់ហើយ ក៏រាវស្ទាបផ្លូវដើរតើមៗទៅមុខទៀត ដោយនឹកសង្ឃឹមថា ក្រែងបានដល់ស្រុកភូមិណាមួយគ្រាន់ទីពឹងនៅសំណាក់អាស្រ័យ, លុះចេះតែដើរតើមៗទៅក៏វង្វេងផ្លូវ មិនដឹងជាតម្រង់

ទៅទិសទីដប់ទណាទេ ទើបបន្ទឹកបាតែស្រែកអំពាវនាវបន់ស្រន់ទេវតាសុំឲ្យជួយស្រោចស្រង់ជីវិតខ្លួនឲ្យផុតពីក្តីទុក្ខវេទនា ។

ក្រោយមកមិនយូរប៉ុន្មាន ស្រាប់តែបុរសបណ្ឌិតដង់ដឹតន៍ទុលឮសូរសំឡេងប្រកថា, "ចូរឯងដើរឆាកទៅខាងស្តាំដៃឯងទៅ ឯងនឹងទៅដល់ព្រៃមួយ ដែលមានប្រឡាយទឹកហូរគុក ៗ ចូរឯងក្សង់យកទឹកនោះលុបលាងមុខទៅ មុខជាភ្នែកឯងទាំងគូក៏ដូចដើមវិញមិនខាន ហើយឯងនឹងឃើញ ដើមជ្រៃធំមួយដើមនៅទីនោះ ដល់ពេលពត្រីត្រូវឯងឡើងទៅពួនសម្ងំដេកលើដើមជ្រៃនោះទៅ កុំខាត់កឲ្យនរណាឃើញដឹងឮឡើយ" ។

បុរសបណ្ឌិតឮពាក្យនេះហើយ ក៏ត្រេកអរខំស្ទាបពាវដើរទៅទៀត ហើយប្រកាន់តែស្តាំដៃរហូតទៅ ដក ដល់ចូលក្នុងព្រៃទៅត្រូវត្រង់ប្រឡាយទឹក ក៏ឮសូរទឹកហូរគុក ៗ ទើបក្សង់ទឹកនោះលុបលាងមុខ ស្រាប់តែភ្នែកក៏ដូចដើមវិញ ហើយឆាកមើលទៅឃើញជ្រៃមួយដើមធំ, ឃើញស្មោះទៅគល់ជ្រៃនោះ រេចរលេខក់ទីដូចជាមានអ្នកដំណើរដើរមកឈប់ជ្រកអង្គុយលេងនៅគល់ជ្រៃ លុះដល់យប់ក៏ឡើងទៅដេកពួនសម្ងំនៅប្រគាប់ជ្រៃខាងលើខ្ពស់ដី ដើម្បីកុំឲ្យអ្នកណាឃើញខ្លួន ។

នៅពេលអធ្រាត្រស្ងាត់ ពួកបិសាចដែលមានឫទ្ធិខ្លាំងពូកែមកប្រជុំគ្នាក្រោមដើមជ្រៃនោះ អួតអាងអំពីឫទ្ធិរបស់ខ្លួនដែលបានធ្វើឲ្យគេឈឺចាប់ ៗ ពេលនោះ បិសាចម្នាក់និយាយថា ៖

សព្វថ្ងៃ អញអាស្រ័យនៅក្នុងប្រាសាទកូនស្រីស្តេច រវាង១០ឆ្នាំមក ហើយ អញចេះតែធ្វើឲ្យនាងឈឺចាប់ឥតស្រាកស្រាន្ត បើទុកជាមានគ្រូយ៉ាងពូកែ ឬមានថ្នាំធ្មុតឆាប់ចំណានមកមើលជម្ងឺនាងយ៉ាងណា ក៏ឥតបានការអ្វីសោះ នៅតែឈឺដដែល ព្រោះបណ្តាញអញមិនបាន អញគ្មានខ្លាចគ្រូឬថ្នាំទាំងនោះសោះ អញខ្លាចតែរូបព្រះអរហន្តីណោត្រឺដាមមួយប៉ុណ្ណោះ បើអ្នកណាទៅយករូបព្រះអរហន្តីនេះពីពាណិជម្នាក់បានមកធ្វើទឹកឲ្យនាងសោយហើយ នោះទើបបណ្តាញអញចេញពីប្រាសាទបាន អញលែងហ៊ាននៅតទៅទៀត ។

លុះព្រឹកឡើង ពួកបិសាចបែកគ្នាទៅរកកន្លែងរៀងខ្លួនហើយ បុរសបណ្ឌិតចាំពាក្យបិសាចម្នាក់នោះច្បាស់ក្នុងចិត្ត ទើបចុះពីដើមជ្រៃហើយស្វែងរកពាណិជអ្នកមានធនធាននោះ ។ (ខ្ញុំមិនដឹងជាបុរសបណ្ឌិតដើររកពាណិជនោះប៉ុន្មានថ្ងៃ-ខែ-ឆ្នាំទេ) ប៉ុន្តែ ខ្ញុំដឹងថាក្រោយមកបុរសបណ្ឌិតរកពាណិជឃើញដូចប្រាថ្នា ហើយក៏ចូលទៅនិយាយសុំស៊ីឈ្នួលធ្វើការនៅផ្ទះពាណិជនោះដោយសំដីថា ៖

"ខ្ញុំសុំនៅធ្វើការជូនលោកពេញមួយឆ្នាំ ហើយខ្ញុំមិនយកថ្លៃឈ្នួលជាប្រាក់កាសទេ ខ្ញុំសុំតែរូបព្រះអរហន្តីណោត្រឺដាម (notre dame) ដែលមានក្នុងផ្ទះលោក" ។ ពាណិជក៏ព្រមតាមពាក្យសុំនោះ ។

បុរសបណ្ឌិត ខំយកចិត្តទុកដាក់ធ្វើការឲ្យពាណិជទាំងថ្ងៃទាំងយប់

គ្មានគិតទៀយហត់ ដើម្បីឲ្យគេពេញចិត្តស្រឡាញ់ខ្លួន ។ លុះធ្វើការគ្រប់មួយឆ្នាំហើយ ក៏ចូលទៅនិយាយសុំរូបនោះពីនាយពាណិជ ។

នាយពាណិជឆ្លើយថា អញពេញចិត្តនឹងការងារដែលឯងធ្វើ ណាស់ ប៉ុន្តែអញចូលចិត្តឲ្យប្រាក់ឯងវិញ ព្រោះអញស្តាយរូបនោះពេក កាត់ចិត្តឲ្យឯងមិនដាច់សោះ ។

បុរសបណ្ឌិត ទេលោក ! ខ្ញុំមិនដឹងជាយកប្រាក់ពីលោកទៅធ្វើអ្វីកើតទេ ខ្ញុំចង់បានតែរូបព្រះអរហន្តដែលលោកសុខចិត្តព្រមឲ្យខ្ញុំនោះប៉ុណ្ណោះ ។

ពាណិជ - អើ ! បើដូច្នោះ ត្រូវឯងនៅបំរើអញឲ្យពេញមួយឆ្នាំទៀតទៅ ទើបអញឲ្យរូបនោះ ។

បុរសបណ្ឌិតសុខចិត្តនៅបំរើពាណិជពេញមួយឆ្នាំទៀត ដោយយកចិត្តទុកដាក់ធ្វើការដូចឆ្នាំមុន ដល់គ្រប់មួយឆ្នាំចូលទៅសុំយករូបពីនាយពាណិជ ។ បេះតែធ្វើទើរគេចកែមិនចង់ឲ្យរូប ប្រាប់ថា "អញឲ្យថ្លៃឈ្នួលឯងជាប្រាក់វិញ បើឯងនៅតែខ្ជូបសុំយករូបនោះមិនឈប់ ត្រូវឯងនៅបំរើអញឲ្យពេញមួយឆ្នាំទៅមុខទៀតចុះ អញនឹងឲ្យរូបនោះតាមឯងសុំមិនខាន" ។

បុរសបណ្ឌិតប្រកាន់សច្ចធម៌ផង ខ្លាចចិត្តនាយពាណិជផង ក៏ព្រមនៅបំរើនាយពាណិជមួយឆ្នាំទៀត ដោយខំបំរើដូចឆ្នាំមុន ៗ ឥតធ្វេស

ប្រហែល រហូតដល់ពេញមួយឆ្នាំ ជាគំរប់បីឆ្នាំ ទើបចូលទៅសុំយករូបនោះពីនាយពាណិជ ។

នាយពាណិជ ដោះរូបដែលខ្លួនព្យួរនៅជញ្ជាំងយកមកកាន់ហើយ និយាយនឹងបុរសស៊ីឈ្នួលថា ៖

"នែអ្នកចិត្តស៊ូ ! យើងឲ្យរូបព្រះអរហន្តដល់អ្នកជាថ្នូរឈ្នួល ចូរអ្នកទទួលយករូបនេះទៅចុះ ហើយឲ្យបានសម្រេចដូចក្តីប្រាថ្នានៃខ្លួនកុំបីខានឡើយ" ។

បុរសបណ្ឌិតឮដូច្នោះ ត្រេកអរណាស់ លើកដៃសំពះទទួលយករូបពីនាយពាណិជ រួចលាពាណិជចេញពីផ្ទះនោះទៅ ដើរសំដៅទៅកាន់នគរដែលបិសាចធ្វើព្រះរាជបុត្រីស្តេចឲ្យប្រឈួននោះ លុះទៅដល់ហើយ និយាយអង្វរសុំគេចូលទៅក្នុងព្រះរាជវាំងដោយប្រាប់អ្នកចាំទ្វារថា "ខ្ញុំសុំចូលទៅក្នុងវាំងហ្នឹងនេះ ព្រោះមានបំណងនឹងមើលរោគព្រះរាជធីតាឲ្យសះជាស្រះស្រឡះ" ។

ឆ្មាំទ្វារឮដូច្នោះ ក៏យល់ព្រមនាំបុរសចូលទៅក្រាបទូលព្រះមហាក្សត្រតាមដំណើរ ។ ព្រះរាជទ្រង់អនុញ្ញាតឲ្យអាមាត្យនាំបុរសចូលទៅក្នុងបន្ទប់ព្រះរាជធីតា ដល់ហើយ បុរសសុំទឹកពីអាមាត្យមួយពែង យកមកជ្រលក់រូបព្រះអរហន្តនោះទៅក្នុងពែងបីដង រួចថ្វាយទៅព្រះនាងស្រប់ព្រះភក្ត្រា ។

ព្រះនាងទើបតែទទួលយកនៃទឹកពីដៃបុរសបណ្ឌិតភ្លាមមិនទាន់តាំងស្រប់ព្រះកន្រ្តាផង ស្រាប់តែបិសាចកំណាចដែលវាអួតអាងឫទ្ធិជាពូកែណាស់នោះ ស្ទុះចេញពីអង្គព្រះនាងទៅមួយរំពេច ហាក់បីដូចជាផ្សែងមួយដុំខ្មៅហុយចេញទៅ ។ ពេលនោះ ព្រះរាជធីតាស្រស់ថ្លាសម្បុរ ព្រះកន្រ្តាបំព្រងញញឹមពព្រាយ រីកកាយសប្បាយព្រះទ័យកេសរជាស្រឡះ មានកំឡាំងពលំដូចដើមវិញ ។

ឯព្រះមហាក្សត្រទ្រង់ព្រះអគ្គមហេសីទតឃើញដូច្នោះ ក៏មានព្រះរាជហឫទ័យសោមនស្សក្រៃលែង ឥតអ្វីប្រៀបស្មើបាន ទ្រង់ព្រះពន្លាថា " អញបានរបស់អ្វីឲ្យថ្លៃថ្លា តបគុណលោកគ្រូពេទ្យនេះ ណ្ហើយចុះ អញព្រះរាជទានយសសក្តិទីងទ្រព្យសម្បត្តិឲ្យច្រើនទៅចុះ " ទើបទ្រង់ហៅបុរសមកទទួលព្រះរាជទាន ។

បុរសបណ្ឌិតក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ! ទូលព្រះបង្គំជាខ្ញុំមិនចង់បានរបស់អ្វីបន្តិចសោះ ។

ព្រះរាជធីតាទ្រង់ព្រះសណ្តាប់ពាក្យបុរសដូច្នោះ ក៏ក្រាបទូលព្រះវររាជបិតាថា ខ្ញុំម្ចាស់សូមព្រះរាជានុញ្ញាតរៀបអាពាហ៍ពិពាហ៍ជាមួយបុរសនេះ ។

ព្រះមហាក្សត្រទ្រង់ពេញព្រះរាជហឫទ័យនឹងពាក្យរបស់ព្រះរាជបុត្រីណាស់ ដោយត្រូវតាមព្រះរាជបំណង ក៏ទ្រង់ចាត់ឲ្យរៀបពិធីមង្គលការ

ឲ្យរាជធីតានឹងបុរសបណ្ឌិតយ៉ាងខ្លាំងក្រៃលែង ។

តាំងពីថ្ងៃនោះមក បុរសបណ្ឌិតបាននៅគង់ព្រះបរមរាជវាំងជាមួយព្រះរាជធីតាជាព្រះជាយា ស្លៀកពាក់សុទ្ធតែសំពត់អាវយ៉ាងល្អៗថ្លៃៗ ហើយបរិភោគអាហារឆ្ងាញ់ពិសាជាមួយព្រះមហាក្សត្រផងទៀត ។

លុះចំណេរចីរកាលមក បុរសបណ្ឌិតក្រាបទូលសុំលាព្រះរាជាទាំងចេញទៅសួរសុខទុក្ខម្តាយរបស់ខ្លួន ដែលចាស់ជរានៅឯស្រុកកំណើត ។ ចំណែកព្រះនាងជាយាសុំតាមព្រះស្វាមីទៅផងដែរ ។ បុរសនឹងព្រះនាងឡើងជិះព្រះរាជរថព្រះទីនាំងនៃព្រះមហាក្សត្រ អង្គុយទន្ទឹមគ្នាចេញដំណើរទៅ ដល់កន្លែងមួយ បុរសបណ្ឌិតបោលភ្នែកក្រឡេកទៅឃើញបុរសពាលជាសំឡាញ់ចាស់របស់ខ្លួន ក៏ចាំបាន ទើបស្រែកសួរថា៖

ជំរាបសួរ សំឡាញ់ ! ម៉េចឯងមិនស្គាល់យើងទេឬ? ឯងចាំទេ ពីកាលនោះ ឯងប្រកាន់ថា ការចិញ្ចឹមជីវិតដោយអំពើទុច្ចរិតប្រសើរជាងអំពើសុចរិត មិនតែប៉ុណ្ណោះ ថែមទាំងឯងឆ្កៀលភ្នែកអញទាំងគូ ធ្វើឲ្យអញខ្វាក់សូន្យឈឹងទៀតផង ។

បុរសពាលឮដូច្នោះ ក្រឡេកមើលឃើញបុរសបណ្ឌិតជាសំឡាញ់ចាស់ ជិះព្រះរាជរថស្តេចទន្ទឹមព្រះរាជបុត្រី ក៏ចាំមុខបានឥតភ្លេចភ្លាំង ទើបភិតភ័យផង អៀនខ្មាសផង ដាក់មុខជ្រប់ លែងហ៊ានងើបមើលបុរសបណ្ឌិតទៀត ។

បុរសបណ្ឌិតប្រាប់ថា ឯងកុំខ្លាចអញឡើយ អញឥតបង់គំនុំគុំគួនព្យាបាទសងសឹកទៅឯងវិញទេ ព្រោះអញប្រកាន់យកតែខាងសុចរិតយុត្តិធម៌ម្យ៉ាងប៉ុណ្ណោះ ឯខាងទុច្ចរិតអញខ្ពើមណាស់ អញមិនហ៊ានជំពាក់ទេ ។ បុរសបណ្ឌិត ដំណាលរឿងរ៉ាវរបស់ខ្លួនសព្វគ្រប់តាំងពីខ្វាក់ភ្នែករហូតដល់ភ្លឺភ្នែក ហើយបានព្រះរាជធីតាជាប្រពន្ធឲ្យបុរសពាលស្តាប់ ។

បុរសពាលស្តាប់រឿងនោះចប់ ក៏នឹកថា អញនឹងចូលទៅរកព្រៃរកទឹកហូរ, រកដើមជ្រៃនោះឲ្យឃើញ ហើយធ្វើត្រាប់សំឡាញ់អញនេះ ក្រែងជួនជាមានជោគវាសនាដូចគេ គិតស្រេច ក៏គេចចូលទៅរកទឹកទន្លង នោះឃើញសព្វគ្រប់ដូចបំណងមែន ឡើងដេកលើដើមជ្រៃ អព្រួចថា អញមុខជាបានសម្រេចបំណងមិនខាន ។

សេចក្តីអំណររបស់បុរសពាលផុយស្រឡះ ដល់យប់ស្ងាត់ពួកបិសាចមកជួបជុំគ្នានៅក្រោមដើមជ្រៃនោះ ជួនជាអកុសលមកដល់ ស្រាប់តែបិសាចម្នាក់មើលទៅឃើញបុរសនៅលើមែកជ្រៃ នឹកខឹងស្អប់ចាប់ទាញកន្ត្រាក់ជើងបុរសធ្លាក់ចុះមកដី ហើយសម្លាប់ចោលនៅគ្រានោះទៅ ។

(រឿងនេះ សូមអស់លោកពិចារណាមើលចុះ ការរស់នៅដោយអំពើសុចរិតនិងទុច្ចរិត តើអំពើណាប្រសើរជាងណា? ដូចមានទិដ្ឋានខាងដើមនេះស្រាប់) ។

# រឿងស្រីគ្រប់លក្ខណ៍

ប្រែ-រចនា រៀបរៀង លោក កេង-ស្រ៊ីវ ពិចិត្រ

## ជំពូក ១

អ្នកបង! ក្រែងស្អែក ត្រូវនាំចៅធនឲ្យទៅនៅរៀនអក្សរឬ?

អើ.. មែនហើយ អូន! បងចង់ភ្លេចទៅតើ ។ ចុះក្រែងអូនឯង នាំចៅសិរីវឌ្ឍន៍ទៅដែរឬ?

ព្រោះតែរឿងហ្នឹងហើយ បានជាខ្ញុំភ្លៀតមកសួរអ្នកបង ដើម្បីនឹងបានទៅជាមួយគ្នា ។

គឺថា នាងសារីដែលមកសួរនាងមន្តលី អំពីរឿងនាំកូនទៅឲ្យរៀនអក្សរ ។ នាងទីមួយជាម្ដាយចៅសិរីវឌ្ឍន៍ នាងបន្ទាប់ជាម្ដាយចៅធន ដែលអាស្រ័យនៅក្នុងភូមិនាលន្ទា ក្នុងដែនមគធៈ នាមជម្ពូប្រទេស (ប្រទេសឥណ្ឌាសព្វថ្ងៃ) ។

ឯស្រីទាំងពីរនាក់នេះសុទ្ធតែមេម៉ាយ ប្ដីស្លាប់ចោលតាំងពីកូននៅតូចៗដូចគ្នា ។ តាមទំនៀមនៅប្រទេសឥណ្ឌា បុរសនឹងស្ត្រីត្រូវមានប្រពន្ធតែម្ដង មានប្ដីតែម្ដង ។ បើប្ដីស្លាប់ឬប្រពន្ធស្លាប់ អ្នកទទួលរងគ្រោះនេះ ត្រូវតែទទួលអំពើអភ័ព្វនេះរហូតអស់មួយជីវិតរៀងខ្លួន ។

ដូច្នេះនាងមេម៉ាយទាំងពីរ ខាងក្រោយមរណភាពនៃប្ដីភាគ្នា រមែងខំរកទទួលទានដោយសេចក្ដីក្លាហាន ដើម្បីចិញ្ចឹមកូន ។ ឥឡូវកុមារ

តាំងពីចំរើនវ័យធំល្មមហើយ គឺថាទៅជនបានអាយុដប់ឆ្នាំ ទៅសិរីវឌ្ឍន៍ អាយុប្រាំបួនឆ្នាំ ៗ

ព្រឹកស្អែក គេឃើញនាងមន្តលី ទីទីនាងសារ៉ែស្បៀកពាក់ដណ្ដប់ សំពត់ព័ទ្ធជុំវិញខ្លួនយ៉ាងស្អាតបាត នាំគ្នាបណ្ដើរកូនមួយម្នាក់យកទៅឲ្យ ទៅរៀនអក្សរក្នុងសំណាក់លោកអាចារ្យម្នាក់ ដែលនៅក្នុងភូមិដទៃឆ្ងាយ ដាច់ពីភូមិខ្លួនបន្តិច ៗ អំពីការសិក្សាក្នុងសម័យនោះ សិស្សណាដែលផ្ទះសំបែងនៅឆ្ងាយ ត្រូវតែសុំបំណាក់អាស្រ័យនៅជាមួយនឹងគ្រូ គឺរៀនផង បំរើគ្រូអាចារ្យផង ហើយមួយឆ្នាំដំបូង ក្នុងម្នាក់ ត្រូវចំណាយបូជាគ្រូ ៦០ កហាបណៈ ក្នុងឆ្នាំទី ២-ទី ៣ ឡើងទៅ ឆ្នាទគ្រូក៏ចេះតែឡើងជាលំដាប់ តាមចិត្តសទ្ធា ប៉ុន្តែមិនមែនជាការបង្ខំទេ ៗ

លុះនាំកូនទៅដល់ផ្ទះអាចារ្យកាលណា នាងមេម៉ាយឡើងទៅបត់ជើង ហើយលើកដៃសំពះផ្ចិតបង្គួរ ជាសេចក្ដីគួរសមតាមទំនៀមទម្លាប់ស្រុកថា:

សូមប្រណិប័តន៍ ព្រះតេជ-គុណ ! សុខសប្បាយជាទេឬ ?

លោកអាចារ្យលើកដៃសំពះតបមកវិញ ហើយលោកថា:

បាទល្អហើយ! លើកដៃថ្វាយព្រះ !

រួចលោកសួរបន្តទៅទៀតថា:

ចុះនាងទាំងពីរនាក់ដែលមកនេះ តើមានការអ្វី ? ឬមួយយកកូន មកឲ្យនៅរៀន ?

ហ៎ ! មែនហើយ ! ព្រះតេជព្រះគុណ ! កូនយើងខ្ញុំសុទ្ធតែកំព្រាឪពុក ស្លាប់ចោលតាំងពីនៅបៅទឹកដោះ យើងខ្ញុំសូមព្រះតេជព្រះគុណមេត្តាបង្ហាត់ បង្រៀនឲ្យផង ហើយសូមឲ្យនៅសំណាក់ជាមួយ ព្រោះផ្ទះនៅឆ្ងាយ ៗ

-បាទ ! មិនពាស់អ្វីទេ នាង ! ប៉ុន្តែរឿងម្ហូបអាហារអត់ខាតបន្តិច ព្រោះខ្ញុំចាស់ហើយៗ ស្រែចំការក៏មិនបានធ្វើឲ្យមាំទាំដូចគេដទៃ ៗ

នាងមេម៉ាយទាំងពីរ ក្រោយដែលបាននិយាយពីនេះពីនោះ អស់រយៈពេលប្រហែលកន្លះម៉ោង ក៏សូមលាលោកអាចារ្យវិលត្រឡប់ទៅទីលំនៅអាត្មាវិញ ៗ មុននឹងចុះជយចេញ នាងនិយាយបន្ថែមចំពោះលោកអាចារ្យ ជាសេចក្ដីបណ្ដាំ នឹងសេចក្ដីបម្រុងចិត្តរបស់ខ្លួនជាក់ច្បាស់ថា :

សូមព្រះតេជ-គុណៈមេត្តាពង្រីកឲ្យពានបន្តិច សូមកុំបារម្ភ ខ្លាចក្រែងយើងខ្ញុំខឹងឲ្យសោះ បើត្រូវវាយខ្លះ ក៏បេះតែវាយទៅ សូមធ្វើយ៉ាងដូចម្ដេចឲ្យតែបានចេះដឹង ចំណែកសាច់ឈាម ជូនទាំងអស់ សូមមេត្តាទុកតែស្បែកនឹងឆ្អឹងឲ្យ ៗ

លោកអាចារ្យឆ្លើយតបទាំងញឹម ៗ ថា:

-នាងកុំព្រួយអី ! ខ្ញុំគ្រាន់តែឃើញទឹកមុខ នឹងអាការប៉ុណ្ណោះ

កំអាចយល់បាន ៖ ក្មេងទាំងពីរនេះ មិនបាច់ចាំប្រដៅច្រើនទេ ។

រួចនាងមន្ថិល នឹងនាងសារ៉ាក៏យកមកនិយាយផ្តាំ ចំពោះកូនទាំងពីរ ដោយទឹកមុខក្រៀមក្រំថា ឲ្យខំយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ឲ្យចេះស្រឡាញ់គ្នា កុំខាសគ្នា ហើយឲ្យគោរពប្រណិប័តន៍គ្រូបាធ្យាយ កុំបីធ្វេសប្រហែស ។

ចាប់តាំងពីពេលនោះមក ហៅធននឹងហៅសិរីវឌ្ឍន៍ពុំដែលធ្វើឲ្យពាក្យទូន្មាននៃម្តាយរបស់ខ្លួនស្ថិតនៅឥតលទ្ធផលល្អឡើយ ។ អ្នកខំសិក្សា ទាំងប្រណិប័តន៍លោកអាចារ្យសព្វពេលវេលា មិនដែលធ្វើឲ្យខាសចិត្តម្តងសោះ ។

វិស្សមកាលម្តង ៗ អ្នកវិលទៅលេងផ្ទះ ដើម្បីសួរសុខទុក្ខម្តាយ ព្រមទាំងជួយធ្វើការងារផ្សេង ៗ មានបោសផ្ទះ ដាំបាយ ដឹកគោយកទៅឲ្យស៊ីស្មៅជាដើម ។

កិច្ចសិក្សានៃមាណពទាំងពីរ មានសេចក្តីចំរើនជានិច្ច ។ អ្នកមិនដែលទទួលសេចក្តីបន្ទោសពីលោកអាចារ្យម្តងឡើយ សេចក្តីសរសើរនៃលោកអាចារ្យ ធ្វើឲ្យហៅធន នឹងហៅសិរីវឌ្ឍន៍រឹតតែមានសេចក្តីក្លាហានដ៏លើសលុបក្នុងការរៀនសូត្រ ។

ក្នុងរយៈកាលតែពីរឆ្នាំ ហៅធននឹងហៅសិរីវឌ្ឍន៍ចេះអក្សរសាស្ត្របាលីម៉ត់ចត់ ។ ពីពេលនេះទៅ អ្នកសុំឲ្យលោកអាចារ្យបង្ហាត់

បង្រៀនវិជ្ជាដទៃផ្សេងៗ មានក្បួនខ្នាតនឹងគម្ពីរសាស្ត្រជាដើម ។ ចៅទាំងពីរតែងបានទទួលសេចក្ដីសរសើរ នឹងសេចក្ដីកប់អានពីសំណាក់លោកអាចារ្យច្រើនជាងសិស្សដទៃ ។

មួយឆ្នាំៗ ទោះបីនឿយហត់លំបាកក្នុងការរកទទួលទានដូចម្ដេច ក៏នាងមេម៉ាយឥតថ្ងូរឡើយ ។ នាងរមែងផ្ដល់រង្វាន់សម្រាប់អាចារ្យផង គ្រឿងសំលៀកបំពាក់ និងប្រដាប់ប្រដាខាងការរៀនសូត្រសម្រាប់កូនរបស់ខ្លួនផង ព្រោះនាងយល់ច្បាស់ថា ចំណេះវិជ្ជាជាអលង្ការនៃមនុស្ស, ក្នុងជីវភាព គេទុកវិជ្ជាជាអាវុធ សម្រាប់កាប់ឆ្កានូវគ្រឿងឧបសគ្គទាំង-ឡាយ ។

ចៅធននិងចៅសិរីវឌ្ឍន៍ ពេលព្រឹកមួយ បាននាំគ្នាចូលទៅធ្វើវត្តប្រណិប័តន៍ចំពោះលោកអាចារ្យ គឺការគក់ប្រហាច់ ជាកិច្ចវត្តដែលខ្លួននិងសិស្សដទៃធ្លាប់ប្រព្រឹត្តជាធម្មតាមក ។ ក្រោយពីការជំណាលរឿងអ្វីផ្សេងៗ លោកអាចារ្យសួរសិស្សទាំងពីរថា " ចៅឯងបានរៀនអក្សរសាស្ត្រ និងវិជ្ជាដទៃចេះល្មមប្រើការបានហើយ តើឥឡូវនៅត្រូវការចង់រៀនវិជ្ជាអ្វីថែមទៀត ចូរប្រាប់យើងមកមើល ? " ។

ចៅធនដោយបានគិតទុកមុន ទើបឆ្លើយជំរាបទៅលោកអាចារ្យវិញថា " ខ្ញុំបាទចង់រៀនវិជ្ជាមើលដីភូមិ ពានព្រោស " ។

ចំណែកចៅសិរីវឌ្ឍន៍ លុះជញ្ជឹងមួយស្របក់ទើបជំរាបចំពោះលោក

គាថាថា "ខ្ញុំបាចចង់រៀនវិជ្ជាមើលស្រីគ្រប់លក្ខណ៍ ចានប្រោស" ។

ចៅធន កាលបើបានឮសំឡេងញាញ់ដាក់បលោកគ្រូថា ចង់រៀនវិជ្ជាមើលស្រីគ្រប់លក្ខណ៍ដូច្នោះក៏និយាយយាត់ថា: "ក្មួនឯងកុំរៀនវិជ្ជានេះ ព្រោះស្រីគ្រប់ល័ក្ខណ៍មិនសូវមានទេក្នុងលោក ហើយបើស្រីគ្រប់ល័ក្ខណ៍មានចំនួនតិចយ៉ាងនេះ តើធ្វើដូចម្ដេច យើងនឹងរកឃើញជួបប្រទះ? ម្ល៉ោះហើយ ការសង្ឃឹមរបស់យើង នឹងបញ្ចេញប្រយោជន៍ឲ្យឃើញជាក់ពិតប្រាកដដោយកម្រ ហើយដួនកាល ទៅជាអសារបង់កំលាំងមាន" ។

បានឮពាក្យដូនយោបល់ដ៏ពីរោះស្មោះត្រង់ របស់សម្លាញ់ហើយ សិរីវឌ្ឍន៍ធ្លើយតបទៅវិញថា "ក្មួនឯងថាហ្នឹងពេញហៅត្រូវហើយ ព្រោះមនុស្សគួរតែនិយមត្រង់កន្លែងងាយ ៗ ដើម្បីប្រកបការចិញ្ចឹមជីវិត ប៉ុន្តែ ចូរក្មួនរៀនវិជ្ជាមើលដីក្ខមិចុះ បំណែកអញបានជាប់ចិត្តទៅខាងណោះហើយ ។ បុកណាពាក្យពោលថា: "ប្ដូសយោយវិត្តចិត្តដោយខ្លួន" ។

ចំពោះកិច្ចសន្ទនានេះ លោកគាថាឥតមានវាចាថាអ្វីសោះ លោកសម្រាន្តធ្វើព្រងើយចាំស្ដាប់សិស្សប្ដូរយោបល់គ្នា ហើយលោកពេញចិត្តក្រៃពេក ដោយនឹកថាអំណើះទៅមុខសិស្សទាំងពីរនេះ នឹងបានទៅជាមនុស្សមានមុខមាត់គ្រាន់បើ ដៀតវ័យនៅក្មេងសោះ វាចេះនិយាយវែកញែកពន្យល់ហេតុផលគួរឲ្យស្ដាប់បាន ។

ផាឥវសាន លោកអាចារ្យប្រាប់សិស្សថា «ឥឡូវយប់យូរហើយ ចូរទៅនាំគ្នាទៅកេដេកពួនចុះ ឯរឿងរៀនវិជ្ជានោះមែនហើយ ក៏ស្រេចលើចំណង់រៀនខ្លួនទេ ដូច្នេះយើងចាប់រៀនពីព្រឹកស្អែកទៅ ។

ដោយមានសេចក្ដីគោរពចំពោះគ្រូបាធ្យាយ មាណពទាំងពីរមិនហ៊ានឆ្លើយជំទាស់ប្រសាសន៍តបវិញថាដូចម្ដេចឡើយ ។ អ្នកក្រោករៀងលុតជង្គង់សំពះលា ហើយថយទៅកន្លែងសម្ងួនខ្លួនដោយស្ងៀមស្ងាត់ ។

ទៅផុនទីងទៅសិរីវឌ្ឍន៍ ខំសិក្សាវិជ្ជាតាមផ្នែករបស់ខ្លួនទៀតៗ ប៉ុន្តែមិត្តភាពរវាងទៅទាំងពីរ ឥតមានការប្រេះឆាឡើយ ។

ថ្ងៃខែឆ្នាំចេះតែប្រព្រឹត្តកន្លងទៅ ហើយពាំនាំយកទាំងអាយុសង្ខារនៃមនុស្សសត្វទៅជាមួយផង ។ រដូវរំហើយវិលទៅជួបទីងរដូវប្រាំងៗវិលទៅជួបទីងរដូវស្សា ហើយវិលវល់យ៉ាងដូច្នេះ ឥតដែលអាក់អួរវេលាដូចជាក្រឡិចចាក់ស្វ័យប្រវត្តិ ។ ចក្រសង្សារវិលឥតឈប់ វិលឥតគ្រឡប់ វិលបង្វិល វិលគ្មានអាណិតមេត្តា វិលចះបក្ខា ចំពោះការសំពះអង្វរការខ្សឹកខ្សួល ការយំសោកសង្រេងសង្រែបោកខ្លួនប្រាណនៃមនុស្សទីងសត្វ ដែលកំពង់តែញាំញីដោយចិត្តក្នុងការត្រេកដញ្ចក់នុងជាសុខសេចក្ដីស្នេហាក្នុងវត្ថុកាមទីងកិលេសកាម ។

ឥឡូវទៅទាំងពីរដល់អាយុម្ភៃដប់ប្រាំមួយឆ្នាំ ម្ភៃដប់ប្រាំពីរឆ្នាំហើយ ។ ចំណែកលោកអាចារ្យ បើកាលណាចង់អានក្បួនថ្មសាស្ត្រអ្វី

គោនតែពាក់វ៉ែនតា ៗ បើមានញាតិជិតខាងយកអ្វីមកជូន លោកដោះវ៉ែនតាចេញហើយ យកដៃប៉ាំងភ្នែកពីខាងលើ ដើម្បីពិនិត្យគាគន្ទុក-ជននោះ ៗ ចួនកាលគេសួរលោកថា :

ព្រះតេជព្រះគុណ ព្រះជន្មប៉ុន្មានហើយ ?

លោកមានវាចាប្រាប់តាំងមុខញាក់ច្រើកៗថា:

ចិតប៉ាយហើយ អ្នក ?

ថ្ងៃមួយ ចៅបែនអាយុដប់ពីរឆ្នាំ ដែលទើបមកនៅរៀនអក្សរ មកជំពបលោកតាអាចារ្យថា:

— ពានប្រោស! អាញ៉ូវដេកស្លាប់នៅក្បែរបន្ទប់ទឹក ៗ

លោកតាអាចារ្យមានប្រសាសន៍ថា:

— អើ! វាចាស់ហើយ . . ៗ

អាញ៉ូវនេះ ជាឆ្កែ ដែលលោកតាអាចារ្យចិញ្ចឹមមក រស់រយៈពេលប្រាំពីរឆ្នាំហើយ ៗ

ចៅប៊ុនធឿនចៅស៊ន ដែលមកពីសែងទឹកស្រះនៅមុខសាលារៀន បានចូលមកជំពបលោកតាអាចារ្យថា :

—ជហ្វា សាលារៀនបាក់ធ្លាក់មកអម្បាញ់មិញ នៅពេលយើងខ្ញុំកំពុងសែងទឹកយកមកដាក់ពាង ៗ

លោកអាចារ្យប្រាប់ថា :

ទើប សាលារៀននេះ ចាស់ទ្រាំទ្រាណាស់ដែរ កសាងមកជាង សាមសិបឆ្នាំហើយ បើទៅដើរក្បែរនោះ ចូរប្រុងប្រយ័ត្នផង ៗ

រីឯចៅធនទឹងចៅសិរីវឌ្ឍន៍ លុះបានរៀនវិជ្ជាចប់សព្វគ្រប់តាមបំណងរៀងខ្លួនហើយ ក៏សូមលាលោកតាអាចារ្យវិលត្រឡប់ទៅផ្ទះអាត្មាទៃ យកទាំងមិត្តភាពដ៏បរិសុទ្ធទៅជាមួយផង ៗ

លុះចៅធនបានអាយុម្ភៃប្រាំឆ្នាំ នាងមន្ទលីជាម្តាយបានទៅដណ្តឹងនាងទារិកាម្នាក់នៃគ្រួសារមួយដ៏សមគួរ យកមកឱ្យធ្វើជាភរិយា ៗ ដោយពឹងផ្អែកទៅលើវិជ្ជាមើលដីភូមិដែលខ្លួនបានរៀនមក ខាងក្រោយអាពាហ៍ពិពាហ៍ មិនយូរប៉ុន្មាន ចៅធនចាប់ផ្ដើមដើរស្វែងរកមើលដីភូមិដើម្បីធ្វើជាទីលំនៅ ហើយនឹងប្រកបការរកទទួលទានតទៅ ៗ ប៉ុន្តែ ដីល្អដ៏ចម្រើនដ៏សុខសប្បាយ ក៏មិនងាយរកបានដោយស្រួលឡើយ គេដើរស្វែងពីភូមិ ១ ទៅភូមិ ១ ពីស្រុក ១ ទៅស្រុក ១ ឆ្លងកាត់ខែត្រនានា ៗ ការដើរស្វែងរកទីស្ថាននេះ ប្រព្រឹត្តទៅអស់រយៈពេលជាយូរថ្ងៃ ហើយឆ្ងាយពីទីលំនៅដើមរបស់ខ្លួនផង ៗ

ជាអវសាន អ្នកប្រទះដីមួយកន្លែង នៅមាត់ស្ទឹងមួយមានសភាពត្រឹមត្រូវតាមក្បួនដែលអ្នកបានរៀនមក ៗ ឈ្មោះធនវិលត្រឡប់មកផ្ទះមាតាវិញ សូមលាលោក ហើយនាំប្រពន្ធទៅនៅប្រកបការចិញ្ចឹមជីវិតត្រង់ដីភូមិដែលខ្លួនបានកំណត់ទុកហើយនោះ ៗ

ដោយអំណាចដ៏ល្អ គូស្វាមីភរិយានេះ រកស៊ីចម្រើនជានិច្ចដូចគេឡើងកាំជណ្ដើរ គឺថាបែរទៅស្រូវមិនដែលខូចក្នុងរដូវណាមួយ បែរមកចំការក៏ជូនផលៗបរិបូណ៌ទៀតៈ ចេកដំឡូងត្រាវអំពៅ ។ល។ ឥតចេះខ្វះ ។

ឯការធ្វើឲ្យទៅជាអ្នកមានទ្រព្យៈនោះ ធំបំផុត នៅត្រង់មានសេចក្ដីសុខ ។ គ្រួសារឈ្មោះធនមិនសូវដែលមានជម្ងឺចូលមកលុកលុយឡើយ ។ បើគ្រួសារណាបានជួបប្រទះនឹងជម្ងឺញឹកញយហើយ ទោះបីទ្រព្យហូរចូលដូចទឹកក៏ដោយ គ្រួសារនោះនឹងអាចធ្វើឲ្យទៅជាអ្នកមានទ្រព្យស្ដុកស្ដម្ភមិនបានឡើយ ។ បុរាណពោលទុកថា «សូវឲ្យពិការលក់ កុំឲ្យតែខ្លោចលក់» ។

ក្នុងរយៈកាលតែបីឆ្នាំប៉ុណ្ណោះ ឈ្មោះធនរកប្រាក់សន្សំទុកបានយ៉ាងច្រើន ដាំដីបានបរិបូណ៌ ទាំងខាងដីភូមិ ទាំងខាងដីស្រែ ហើយកូនឈ្នួលស្រីប្រុសក៏មានប្រើឥតខ្វះ ព្រមទាំងមានចិត្តស្មោះត្រង់ចំពោះនាយទៅហ្វាយផង ។

នៅជំណាច់ឆ្នាំទីបួន ប្រពន្ធឈ្មោះធនសម្រាលបានកូនស្រីមួយមានរូបសម្បត្តិយ៉ាងសមរម្យ ។ គេដាក់នាមថា "សោភណា" ។

តាំងពីពេលដែលសោភណាប្រសូតមក លោកធនរកទទួលបានបានចម្រើនលើសមុនជាកិយ្យោភាព ឥតជាក់បាន ។ ក្រែងតែលោកមិនធ្វើ ។ គួរឲ្យអស្ចារ្យណាស់នៅស្រែជិតគ្នា ស្រែគេត្រូវយប្រផ្នូនអស់

ស្រាលោកធនបេះតែបានផល ។ អ្នកស្រុកនិយមហៅលោកធនជាសេដ្ឋីមួយ ។

ឥឡូវសោភណាបានអាយុប្រាំបីឆ្នាំហើយ ។

កត្រើមួយ ក្រោយពេលបាយ ធនសេដ្ឋីនិងភរិយា អង្គុយជជែកគ្នាលេងនៅល្វែងបន្ទប់ពីរៀងផ្សេង ១ មានការធ្វើស្រែទីងដាំដំណាំជាដើម នៅទីបំផុត ធនសេដ្ឋីបានលើកយកបញ្ហាធីតាសោភណាមកនិយាយ ។

ពេលនោះ ក្រោយការប្រឡែងលេងជាមួយកូនឈ្មួលស្រី ១ សេដ្ឋីធីតាក៏សូមលាមាតាបិតាចូលទទួលទានដំណេកមុន ។

ដោយកំបាំងពីមុខកូន លោកសេដ្ឋីមានប្រសាសន៍ជាមួយប្រពន្ធថា:

នែអូន ! មើលទៅកូនយើងធំគួរសមហើយ បងចង់ឲ្យវារៀនអក្សរ តើអូនឯងយល់ឃើញដូចម្តេច ?

ប្រពន្ធឆ្លើយភ្លាមថា :

ត្រូវមែនហើយ ប៉ាវា ! ខ្ញុំសព្វថ្ងៃនឹងទីងខ្លួនឯងពេក ព្រោះមិនចេះអក្សរ កាលណាត្រូវការអានសៀវភៅអ្វី ១ មើលមិនបាន ចង់ផ្ញើលិខិតទៅណាមកណា សរសេរមិនកើត ចង់គិតគូរគុណចំណួនបូកដកដូចជាលក់អំពៅ លក់ឪឡឹកជាអាទិ៍ រង់ចាំពាល់តែប៉ាវាមក ទើបគិតរកខុសត្រូវឃើញ អើ ! គិតបានខ្លះដែរតាមរបៀបក្បាច់ស្រី ប៉ុន្តែវាបានតែការភយរងដូចជាអំពៅប៉ុន្មានដប់ដើម ឬឪឡឹកដប់ផ្លែប៉ុណ្ណោះ តែហួសពីចំនួននេះ

ទៅ ។ ឧបមាដូចជាលក់អំពៅទាំងពីចំការ លក់ស្រូវទាំងពីជង្រុក ។ គេគិតគូរមិនកើត ព្រោះឯងមិនចេះខ្ពុន្ត រូបការធំបំផុត នៅត្រង់កាលណាឯងចាស់ទៅ ហើយត្រូវការរៀនធម៌អាថ៌ តើទីពឹងអ្នកណា ? មិនអីទេ ក៏ការរកចិញ្ចឹមជីវិត មានប៉ាក់ជាជំហរហើយ ចុះទៅបរលោក ប៉ាក់ជួយខ្ញុំផងបានឬទេ ?

ពេលដែលប្រពន្ធកំពុងនិយាយ ធនសេដ្ឋីបឺតបារីស្លឹកសង្កែ ហើយបង្ហុយផ្សែងហុយ ៗ មានអាការធុញទ្រាន់នឹងប្រពន្ធនិយាយវែងពេក បែកជាអូរហូរជាស្ទឹង ៗ លុះប្រពន្ធនិយាយចប់ លោកសួរទាំងញញឹម ៗ ថា:

ម៉េចចប់ហើយ ! ចង់កំពុងតែពីរោះ ។

ខ្ញុំនិយាយវែងបន្តិចមែន ប៉ាក់ ប៉ុន្តែតើសំដីខ្ញុំមានត្រូវខ្លះដែរឬទេ ?

ធនសេដ្ឋីនិយាយបញ្ជោរប្រពន្ធថា :

ប្រពន្ធសេដ្ឋីហើយ កាលណានិយាយខុស ប៉ុន្តែអូនឯងកុំអាលទឹករៀងរៀនធម៌អី យើងនៅមានកម្លាំងពលំ ហើយអាចធ្វើការអ្វីសព្វគ្រប់បាន មិនទាន់ចាស់ធ្វើអ្វីលែងកើតនោះទេ ។

ឮប្ដីនិយាយចំអន់ដូច្នោះ ប្រពន្ធលូកដៃក្តិចប្តី ហើយនិយាយទាំងសើចថា :

– ប៉ាក់ ! កុំនិយាយផ្ដេសផ្ដាសចឹង !

– បើដូច្នេះ អូនឯងពេញចិត្តណាស់ក្នុងការឲ្យកូនយើងទៅរៀនមែនឬទេ !

– ចុះចាំចញ្ញាក់ធ្វើអ្វីទៀត ៗ ប៉ុន្តែ ប្ញាំវា! ខ្ញុំធ្លាប់ឮចាស់ៗនិយាយថា: “ក្មេងទៅរៀនអក្សរហើយគាប់មានស្មារតីចាំបាន លុះណាតែវាលើកដៃម្ខាងគងក្បាលវា រួចស្ទាបស៊ីកត្រចៀកដល់” , មិនដឹងជាលោកណាស្ទាបស៊ីកត្រចៀកដល់ឬពុំដល់ ខ្ញុំបង្ខំឲ្យវាស្ទាបល្បងមើល ប៉ុន្តែ ចាស់ពេលនេះវាទៅកើតហើយ ៗ

– ពាក្យចាស់ថានោះ មិនសូវជាខុសប៉ុន្មានទេ ព្រោះលោកមានការពិសោធន៍ បងឥតមានការប្រឆាំងទេ ប៉ុន្តែតាមយោបល់បង ទោះបីមីនាងលូកដៃស្ទាបស៊ីកត្រចៀកដល់ក្តី ឬមិនដល់ក្តី យើងត្រូវតែឲ្យវាទៅរៀនចុះ ព្រោះអាយុវាគ្រប់ប្រាំបីឆ្នាំហើយ ៗ មួយយ៉ាងទៀត ការដឹងក្តីរបស់វាហាក់ដូចជាសព្វគ្រប់គ្រាន់បើដែរ ចំពោះមតិបងនេះ តើអូនយល់ឃើញដូចម្តេច ?

– ខ្ញុំជាដើរក្រោយ ដោយដើរមុខទេ បើប្តីវាឲ្យទៅរៀន ហើយវាព្រមទៅ នោះជាការគាប់ប្រសើរណាស់ទោះ យ៉ាងម្តេចម្តា ក៏មួយថ្ងៃបាន អក្សរមួយតួជាមិនខាន ជាជាងនៅផ្ទះរត់តែលេងឥតប្រយោជន៍ ៗ

ព្រឹកស្អែក គេឃើញជនសេដ្ឋីនាំកុមារីជាបុត្រីយកទៅឲ្យសិក្សាក្នុងសំណាក់លោកអាចារ្យម្នាក់ដែលនៅក្នុងភូមិជាមួយ ៗ

សោភណាជាកុមារីមានចិត្តស្លូតបូត មានបរិយាសមរម្យ នឹងមានសេចក្ដីព្យាយាមល្អ ៗ នៅក្នុងថ្នាក់រៀន នាងមិនដែលធ្វើឲ្យលោកអាចារ្យអាក់អន់ស្រពន់ចិត្ត ដោយសារតែអំពើឆ្គាំឆ្គងរបស់នាងឡើយ ។ នាងស្ដាប់គ្រូនិយាយពន្យល់ដោយផ្ទៀងផ្ទាត់ នឹងដោយសេចក្ដីគោរពយ៉ាងពន់ពេក ៗ សិស្សផងគ្នា មិនដែលទទួលអំពើអសប្បុរសពីនាងសោភណាម្ដងសោះ ។

មិនតែប៉ុណ្ណោះ នាងមានចិត្តធូរទូលាយថែមទៀត ។ នៅទីធ្លា ពេលចេញលេង នាងតែងតែចែករំលែកនំចំណីឲ្យដល់សិស្សទាំងឡាយទទួលទានផងជានិច្ច គឺថានាងមិនអាចតាំងចិត្តជាមនុស្សថ្នុបានឡើយ នៅឱកាសដែលនាងទទួលទានអ្វី ក្នុងចំណោមមិត្តភក្តិដែលនៅលេងជាមួយគ្នា ។ បើឃើញសិស្សតូច ៗ ឈ្លោះគ្នា នាងចេះឃាត់ហើយចេះនិយាយលួងលោមផ្សះផ្សា សម្រួបសម្រួមឲ្យបានកាត់ទឹង ព្រមទាំងបានជាគ្នាឡើងវិញ ។

ដូច្នេះ សិស្សដទៃតែងស្រឡាញ់រាប់អានសោភណាក្រៃពេក នាំគ្នាគោរព ហើយទុកនាងជាគំរូខាងចិត្តសប្បុរសនឹងខាងបរិយាបរិសុទ្ធ ។ ឈ្មោះសោភណា ស្ថិតនៅរស់រវើកក្នុងគ្រួសារនៃសិស្សទាំងឡាយ ដែលសិក្សាក្នុងថ្នាក់រៀនជាមួយ ។

សោភណាគោរពមាតាបិតាណាស់ ។ ពេលរៀបចេញទៅសាលារៀនក្ដី ពេលត្រឡប់មកដល់គេហដ្ឋានវិញក្ដី នាងតែងសំពះលានឹងសំពះជំរាបសួរចំពោះអាពុកម្ដាយ ឥតដែលមានអាក់ខានមួយដងឡើយ ។

ចំណែកមេរៀនទាំងករណីយកិច្ចដែលគ្រូប្រគល់ឲ្យធ្វើ នាងខំបំពេញយ៉ាងម៉ឺងម៉ាត់ដោយឥតទុកឲ្យនៅសេសសល់ឡើយ ។ ម្ល៉ោះហើយនាងបានពិន្ទុច្រើនផង បានទទួលការសរសើរ និងការពេញអានពីសំណាក់លោកអាចារ្យផង ។

ដូច្នេះ ការសិក្សានៃធីតាសោភណា ក្នុងរយៈពេលតែពីរឆ្នាំបានចប់ខាងអក្សរសាស្ត្រ ។ នាងបន្តកិច្ចសិក្សាចំនួនពីរឆ្នាំទៀត ដើម្បីឲ្យវិជ្ជាផ្សេងដទៃមានវេជ្ជសាស្ត្រជាដើម ។

នៅពេលដែលធនសេដ្ឋីទៅជួបលោកអាចារ្យ នូវដំណើរបញ្ចប់កិច្ចសិក្សានៃធីតាសោភណា ព្រោះការចេះត្រឹមប៉ុណ្ណោះល្មមសមគួរដល់ឥត្ថីភេទហើយ លោកគ្រូបានពោលដំរាបលោកសេដ្ឋីថា: "កូនស្រីលោកទៅអនាគត នឹងបានជាស្ត្រីមេផ្ទះដ៏យ៉ាងចំណាន" ។ សំដីនេះធ្វើឲ្យសេដ្ឋីជាឪពុកពេញចិត្តយ៉ាងខ្លាំងចំពោះវាសនារបស់ខ្លួន ព្រមទាំងរឹងរឹតតែស្នេហាកូនស្រីទ្វេឡើងទៀត ។

កាលវេលាវិលប្រព្រឹត្តទៅជាធម្មតា ឥតដែលអាក់មួយវិនាទី ។ ការប្រកបអាជីវកម្មនិងសេចក្ដីសុខចម្រើននៅគេហស្ថាននៃធនសេដ្ឋី ឥតមានការប្លែកឡើយ ។

ល្ងាចមួយ ធនសេដ្ឋីអង្គុយជំណាលលេងពីនេះពីនោះជាមួយមនុស្សរបស់លោក ដើម្បីសំដែងសមភាពនិងសាមគ្គីធម៌ឲ្យកើតមានរវាងចៅ-

ហ្វាយនាយនិងកូនឈ្នួល ៗ ជាទីបំផុត លោកពោលទឹកភ្នែកដល់ឈ្មោះសិរីវឌ្ឍន៍ជាសំឡាញ់របស់លោកថា មិនដឹងជាស្លាប់ឬរស់ ព្រោះតាំងពីពេលឈប់រៀនហើយបែកគ្នាទៅផ្ទះរៀងខ្លួន មកដល់ឥឡូវនេះលោកមិនដែលបានទទួលដំណឹងអ្វីមួយអំពីមិត្រលោកម្តងសោះ ៗ

ខណៈនោះ សោភណាកំពុងនៅអង្គុយដេរប៉ះសំលៀកបំពាក់នៃកូនឈ្នួលក្បែរជើងភ្លើងដីគងចង្កៀងប្រទីបមួយ ៗ លុះបានឮបិតានាងនិយាយថាមានសំឡាញ់ម្នាក់ តែមិនដឹងឥឡូវនេះនៅទីណា មានសុខទុក្ខលំបាក ស្លាប់ឬរស់យ៉ាងណា នាងនិយាយដកបណ្តាំថា: បើគាត់ជាមិត្ររបស់ប៉ា ដូចម្តេចក៏ប៉ាមិនធ្វើសំបុត្រផ្ញើទៅសួរដំណឹងអំពីគាត់ផង? អាណិតគាត់ណាប៉ា!

ធនសេដ្ឋីឆ្លើយតបទាំងមានទឹកមុខស្លុតថា: ម៉ូបអើយ! ប៉ាមិនដឹងផ្ញើទៅកន្លែងណាទេ បើបាត់ដំណឹងសូន្យឈឹងដូចគេដកកប់យ៉ាងនេះ ៗ កាលពីប៉ុន្មានឆ្នាំមុន ប៉ាឮគេថាលោកម៉ឺនសារីទទួលអនិច្ចកម្មហើយ ក្រោយពេលដែលសិរីវឌ្ឍន៍លាចាកចេញពីផ្ទះ ដើម្បីដើរស្វែងរកស្រីគ្រប់លក្ខណ៍ ៗ ហើយប៉ាក៏ចេញចាកស្រុកកំណើតមកនៅទីនេះជាយូរអង្វែងឆ្នាំណាស់ផង ៗ

លុះឮបណ្តាំនិយាយថា «ស្រីគ្រប់លក្ខណ៍» សោភណានឹកឆ្ងល់មិនដឹងជា"ស្រីគ្រប់លក្ខណ៍"នោះមានសភាពបែបណា ឬមួយជាស្រីទេព-

អប្សរ ឬមួយជាស្រីប្រកបដោយរូបសម្បត្តិនិងចរិយាសម្បត្តិ ៗ ហើយសួរសព្ទនៃពាក្យនេះទៀត ក៏ពីរោះសមរម្យគួរតែបងបានយកមកដាក់ទុកក្នុងដួងហឫទ័យ ៗ នាងនឹកម្តងដូចជាចង់សួរចំពោះលោកអាពុកនូវ "ស្រីគ្រប់លក្ខណ៍" នោះ ដូចម្តេច ? នឹកម្តង ខ្លាចក្រែងជាការណ៍មិនគួរសមក្នុងរឿងសួរនេះ ព្រោះខ្លួនជាស្រី ហើយក៏ស៊ូទ្រាំនៅស្ងៀម ប៉ុន្តែនាងនឹកមិនភ្លេចនូវពាក្យ «ស្រីគ្រប់លក្ខណ៍" សោះ ៗ

ដល់ព្រឹកស្អែក នាងលបសួរម្តាយនាង ក្នុងទីស្ងាត់ថា:

ម៉ែ ! ពីយប់មិញ ប៉ាមានប្រសាសន៍ថា «ស្រីគ្រប់លក្ខណ៍» តើ «ស្រីគ្រប់លក្ខណ៍" ដូចម្តេច ?

រូបម៉ែក្តី រូបខ្ញុំក្តី ជាស្រីដែរ តើជាស្រីអ្វីទៅវិញ ?

ម្តាយៈសើចញឹមៗ ហើយឆ្លើយប្រាប់ពាំងស្ងានថា:

— ម្តាយក៏ដូចកូនឯងដែរ មិនដឹងជា «ស្រីគ្រប់លក្ខណ៍" ដូចម្តេចទេ ប៉ុន្តែ ម្តាយបានឮចាស់ៗដំណាលថា: "ស្រីគ្រប់លក្ខណ៍" នោះ គឺស្រីប្រសើរណាស់ រកស្រីណានឹងប្រៀបផ្ទឹមពុំបានទេ គ្មានស្ត្រីណានឹងធ្វើតាមបានទេ គឺជាស្ត្រីអស្ចារ្យ កូន ! ម្តាយធ្លាប់ឮចាស់ៗតែងដេរស្តីឲ្យកូនស្រីដែលមានការប្រញាប់ហើយនៅតែដើរៗ មិនព្រមរត់ឲ្យទាន់ចិត្តថា: "ហងឯងមិនមែនស្រីគ្រប់លក្ខណ៍ទេ រត់ឲ្យលឿនមក" បើតាមពាក្យនេះម៉ែយល់ថា: "ស្រីគ្រប់លក្ខណ៍" ប្រហែលមិនចេះរត់ទេ ៗ ម្យ៉ាងទៀត

ម្ដាយដ្ឋាប់ព្រះខ្លាចយាយកូនឯងដំណាលប្រាប់ថា: " ប្រពន្ធដើមរបស់មាឃើងជាស្រីកះញីផុះ ប្រពន្ធនាយសំពៅដែលដូរទៅឲ្យមាឃើង ជាស្រីគ្រប់លក្ខណ៍ ព្រោះក្រោយមក នាយសំពៅទៅជាអ្នកក្រ ហើយមាឃើងទៅជាអ្នកមានយសសក្តិធំ", ហើយលោកយាយពោលបញ្ជាក់ថា: "នាយសំពៅទៅជាក្រព្រោះយកស្រីកណ្តាច់លក្ខណ៍ជាប្រពន្ធ មាឃើងទៅជាអ្នកមានយសសក្តិ ព្រោះបានប្រពន្ធស្រីគ្រប់លក្ខណ៍" ។

ដោយចង់ដឹងលក្ខណសម្បត្តិនៃប្រពន្ធមាឃើង និងប្រពន្ធនាយសំពៅ ទើបសោភណាដណ្តឹងសួរម្តាយទៀតថា:

ខ្ញុំចង់ដឹងណាស់ ម៉ែ ! សូមម៉ែដំណាលរឿងមាឃើងត្រង់ប្តូរប្រពន្ធគ្នាឲ្យខ្ញុំស្តាប់បន្តិចមើល !

–ម៉ែដូចជាចង់ភ្លេចអស់ហើយ នៅចាំដែរ តែដោយស្រពិចស្រពិល ព្រោះយាយកូនឯងបានដំណាលឲ្យស្តាប់តាំងពីម៉ែនៅជំទង់ម្ល៉េះ ចាំម៉ែនឹកបន្តិចសិន ។

រួចម្តាយសោភណាយកដៃស្ទាបថ្ពាសនឹកដញ្ញឹងមួយស្របក់ ទើបដាក់ដៃចុះហើយនិយាយថា:

"មាឃើងជាអ្នកទីទាល់ក្រ តែមានប្រពន្ធល្អ ។ ថ្ងៃមួយប្តីនិងប្រពន្ធនាំគ្នាទៅដញ្ជាក់ត្រីនៅមាត់ទន្លេ ។

(មានត)

## រឿងសាមកុក

## កណ្ឌទី ៣៧

ឧកញ៉ាវិបុលរាជសេនា ង៉ូ-កឹង ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នករាំងវើផ្លាស បើបានអាន<br>នឹងបេះឧបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ ។ |

អន្តរាយមុខជាទឹងមានដល់ខ្លួនលោកមិនខាន ។ ទៀតសួរថា ផ្លូវដែលនៅខាងមុខឈ្មោះដំបន់អ្វី? ។ តាហាននាំផ្លូវឆ្លើយថា ទៅខាងមុខនោះខឹងចូលដែនស្រុកកុងយ៉ុង មានភ្នំធំ១ឈ្មោះភ្នំកេងសាន់ ។ ទៀតពីជីងជួរញ៉ា: គឺនាំគ្រប់គ្រួស្រួតរូតដើរទៅដល់ភ្នំកេងសាន់ ហើយឲ្យគ្រប់គ្រួតាំងជំរំឈប់នៅប្របជើងភ្នំ ។ ព្រោះនោះជាផ្លូវរអាណាស់ អាណាប្រ.ជានុរាស្ត្រទាំងពួងនោះ ទៅជាឈឺថ្កាត់គ្រុនរងារមានសេចក្ដីលំបាកវេទនាជាច្រើន ខ្លះស្រែកថ្ងូញយំរងំសាំនក្នុងព្រៃ ប្រឡំទាំងសំឡេងស្រីទីងប្រុសចាស់ទីងក្មេង គួរឲ្យកើតសេចក្ដីសង្វេគពេកណាស់ ។

លុះពេលប្រហែលយាម ៣ យប់ ឡៅពីក៏ឮសំឡេងស្រែកហៅកញ្ជ្រៀវមកពីទិសឯជើង ដូចជារលើងរលំឈើព្រៃ, ឡៅពីភ័យតក់ស្លុតចិត្ត ទើបឡើងសេះនាំទាហាន ២ ពាន់លើកចេញទៅ ទទួលប្រទះនឹងកងទ័ពចូចូលើកតាមមក, ឡៅពីក៏បរសេះនាំទាហានចូលតប្រាំងជាពន្លឹក ទាហានចូចូក៏ឡោមព័ទ្ធឡៅពីបាន ។ លុះទៀវហ៊ុយក្រឡេកឃើញឡៅពីនៅកណ្ដាលចំណោមទ័ពចូចូដូច្នោះ ក៏ស្ទុះពុះពារទំលាយទ័ពចូលទៅជួយឡៅពីៗ បានទំនងស្រួល ក៏ចូលប្រយុទ្ធច្រែកចេញទៅតាមទៀវហ៊ុយទិសឯកើតប្រទះគ្នានឹងហ៊ុនផេងលើកទាហានមកចាំស្កាត់ពីមុខ ។ ឡៅពីក៏បរសេះសំរុកចេញទៅមុខ ៗ ទាហានស្រែកដេរហ៊ុនផេងថា អាចោរទុយិសលក់ឈ្មោះម្ចាស់ នៅចេញមុខឥតខ្មាសមកចូលនឹងចូចូជាសត្រូវផែនដីទៀត ។ ហ៊ុនផេងឮដូច្នោះ មានសេចក្ដីអៀនខ្មាសមិនបង្អង់ឡៅពីឃើញមុខបាន ក៏លើកទាហានបែរតេះទៅ ។

ទាហានចូចូបានចំណាប់ ក៏លើកដេញឡៅពីប្រដាប់ចូលមក ។ ឡៅពីនឹងទៀវហ៊ុយ ២ នាក់បងប្អូនក៏ជួយគ្នាពារទំលាយមកក្រោយ ពាំងទ័ពខុកពាល់តែភ្លឺស្រាង ៗ លុះទាហានចូចូគ្រាកចេញទៅឆ្ងាយហើយ ក៏ឈប់សំរាកទាហាននៅទីនេះ ។ លុះឃើញទាហានដែលសល់ រត់តាមមកផងប្រហែល ១០០ នាក់គ្រប់គ្រួចាំងហួងហ្វាយរបស់ខ្លួន នឹងអាណាប្រជា-នុរាស្ត្រទាំងពួងខ្ចាត់ខ្ចាយព្រាត់គ្នាទៅ, ឡៅពីក៏យំសោកសៅថា មនុស្ស

ទាំងអស់នេះមកថ្វស់ផ្តាយស្លាប់ព្រោះតែយើងម្នាក់ ទាំងបុត្រភរិយារបស់យើងក៏មិនដឹងជានៅទីឯណា ជាស្លាប់ឬរស់មិនបានឃើញនឹងភ្នែកសោះឡើយ, កាលឡេវពីកឈប់អង្គុយឃុំនៅទីនេះទទួលឃើញបីហង ត្រូវអាវុធរបួសជាច្រើនកន្លែង ប្រឡាក់ទៅដោយឈាមពេញអស់ទាំងខ្លួន តែចូលមកស្រែកប្រាប់ថា ឥឡូវជូឡុងប្រែចិត្តចូលទៅខាងទ័ពចូចូហើយ, ឡេវពីឮដូច្នោះ ក៏ស្រែកគំហកឲ្យបីហងថា ឯងនេះជាមនុស្សឥតពីគ្រោះពិចារណាអ្វីសោះ ឯជូឡុងនោះ ជាមនុស្សមានសុចរិតស្រឡាញ់យើងពិតត្រង់ណាស់ ដែលថាប្រែចិត្តចូលទៅខាងចូចូនោះ កុំសង្ស័យឡើយ ។

ទៀវហ៊ុយឆ្លើយថា ពីដើមគេឃើញយើងជាទីពំនាក់បាន ឥឡូវយើងបងប្អូនដុនដាបទៅហើយ ប្រហែលគេប្រែចិត្តចេញទៅមែនទេដឹង ។ ឡេវពីថាឯចិត្តជូឡុងនោះទៀងត្រង់ពិតប្រាកដណាស់ ប្អូនចូរគិតមើលចុះ កាលគួនអ៊ូទៅនៅនឹងចូចូ ចេញមកសម្លាប់ង៉ាន់លៀង ប៊ុនធិវស្លាប់, ប្អូនក៏សង្ស័យថា គួនអ៊ូប្រែចិត្តចេញទៅនៅនឹងចូចូ គិតសម្លាប់គ្នាគ្រានោះដល់គ្រានេះទៀត ទោះបើជូឡុងទៅនៅខាងចូចូមែនក្តី ទោះបើការជាក៏ដោយសារមានហេតុទើបទៅ ឯជូឡុងបងស្គាល់បានថា មិនមែនពោលបងជាប្រាកដ ៗ ទៀវហ៊ុយមិនជឿនឹកខឹងណាស់ ក៏លើកទាហានសេះ ២០ ស្រូតរិលត្រឡប់ចូលទៅជួបនឹងជូឡុង លុះទៅដល់ដើមស្ពានទៀងផាន់កៀវ ក្រឡេកឃើញព្រៃ១ នៅខាងទិសឯកើត ក៏នាំ

ទាហានចូលទៅ ហើយគាត់យកមែកឈើមកចងគ្របកន្ទុយសេះ ហើយបង្គាប់ទាហានឲ្យបរសេះវិលវក់ចុះឡើង ក្នុងវេលាដែលកងទ័ពចូចូលើកមកដល់ ដើម្បីរៀបចូលហ៊ុមដង្រៃលោមឡើង កងទ័ពចូចូមិនដឹងក៏សំគាល់ថាបង្កប់ពលនៅក្នុងព្រៃជាច្រើន, ទៀវហ៊ុំបង្គាប់ទាហានដូច្នោះហើយ ក៏បរសេះទៅឈរកាន់ខ្លួនស្ងាត់នៅលើស្ពាន ។

ឯជូឡុងចូលច្បាំងជាច្រឡំបល់ នៅក្នុងជ្រោះកណ្ដាលកងទ័ពចូចូ នោះវាយត្រឡប់ចេញមកហើយ ក៏ចូលទុះទារទៅវិញទៀត ស្វះស្វែងរកឡៅពីទីងគ្រប់គ្រួតាំងពួងមិនឃើញសោះ ក៏វាយត្រឡប់ចេញមកវិញ វិលដល់នៅក្នុងទ័ពចូចូ តាំងពីយាម ១ រហូតដល់ភ្លឺស្រាង ជូឡុងក៏គិតថានឹងស្វះស្វែងរកឡៅពីក៏មិនប្រទះសោះ ទាំងគ្រប់គ្រួក៏បាត់អស់ទៅ ទីងជាប្រការម្ដេចក៏មិនដឹង ក្រោយមុខ ឡៅពីក៏បានផ្ញើផ្ទុះនេះ ឲ្យយើងនៅរក្សាបុត្រករិយា ឥឡូវមកឲ្យវិនាសបាត់ទៅក្នុងជ្រោះកណ្ដាលចំណោមទ័ពដូច្នោះ ឃើញជាមិនគួរសោះឡើយ, ជូឡុងគិតហើយក៏ទុកតូចចិត្តណាស់ ត្រឡប់តាំងមានៈចិត្តគិតឡើងថា ត្រូវតែសំរុកវាយទំលាយកងទ័ព ចូលទៅរកម្ដងទៀតឲ្យឃើញគ្រប់គ្រួទាំងនោះ ទោះបីស្លាប់នៅក្នុងកណ្ដាលណោ-សង្គ្រាមក៏តាមការចុះ បើមិនឃើញគ្រប់គ្រួឡៅពីនោះទេ ក៏មិនដឹងនឹងបើយកមុខទៅទុកឯណា, ជូឡុងគិតដូច្នោះហើយ ក៏បរសេះពុះពារទំលាយចូលទៅក្នុងជ្រោះកណ្ដាលទ័ពចូចូ ជាមួយនឹងទាហានសេះប្រហែលសែ

៣១ ឃើញពួកអ្នកស្រុកត្រូវការរុំតរបួសពិការជាច្រើន ក្រៃសម្រេងចូញ យំរងំអឺងកង, ដូច្នេះក៏ញាក់សេះវិលទៅរកគ្រប់គ្រឿងទៀត ប្រទះនឹងកាន់ យ៉ុង ត្រូវការរុំតរបួសជាទម្ងន់ ដេកពួននៅក្នុងគុម្ពព្រៃ, ដូច្នេះក៏សួរទៅថា អ្នកបានប្រទះឃើញនាងកាំហ៊ូយ៉ិន នាងបីហ៊ូយ៉ិនទាំង ២ នាក់នៃឬទេ? កាន់យ៉ុងឆ្លើយថា ឥឡូវអ្នកទាំងពីរឃើញកងទ័ពចូងរលីកមកជិតនឹងធ្លាក់ កំណោតចុះពីលើរទេះ ពកូនរត់បន្ទំចូលទៅក្នុងពួកអ្នកស្រុក ខ្ញុំក៏បំផាយ សេះតាមទៅរកជិតដើងក្នុំ តាហានចូងម្នាក់ យកទួនចាក់ត្រូវខ្ញុំធ្លាក់ពី លើសេះ ហើយដណ្តើមយកសេះទៅបាន ខ្ញុំក៏ឈឺលំបាកដើរទៅមិនរួច ក៏លូនមកពួននៅទីនេះ ។ ដូច្នេះឲ្យតាហានម្នាក់ចុះពីលើសេះឲ្យពយក កាន់យ៉ុងឡើងជិះសេះ ហើយប្រាប់ថា អ្នកស្រុតរូតទៅមុនចុះ បើបានជួប ប្រទះនឹងទៀតផងទៅហ្វាយយើងឲ្យដឹកបថា ឥឡូវនាងកាំហ៊ូយ៉ិនខ្លាក់ ក្មាត់ទៅបាត់រកមិនទាន់ឃើញទេ យើងនៅស្វះស្វែងរកឲ្យឃើញទើប ទៅជាក្រោយ បើសិនណាយើងរកនាងកាំហ៊ូយ៉ិនមិនឃើញទេ ទោះបី នឹងស្លាប់ ក៏យើងមិនស្តាយជីវិតឡើយ, ដូច្នេះក្តាំហើយ ក៏បំផាយសេះវិល ទៅក្រោយវិញ ។

ខណៈពេលនោះឮសំឡេងតាហានម្នាក់ស្រែកសួរថា ជូច្នេះបរសេះ ទៅឯណា? ដូច្នេះឮច្បាស់ក៏ទាញសេះឈប់ ហើយងាកចូលទៅសួរថា អ្នកឯងឈ្មោះអ្វី? ។ តាហាននោះប្រាប់ថា ខ្ញុំបាទជាអ្នកបររទេះឲ្យ

នាងកាំហ៊ូយ៉ិនជិះ ឥឡូវនាងនោះត្រូវព្រួញរបួសទៅមិនរួច ។ ជូឡុងសួរថា នាងនៅឯណាឥឡូវនេះ ? ។ ទាហានឆ្លើយថា នាងរត់ប្រឡំបល់ចូលទៅក្នុងគ្រួសារអ្នកស្រុកៈទៅទិសខាងឯត្បូង ។ ជូឡុងឮហើយ ក៏រត់បោលទាហានទាំងអស់ ទំបរសេះស្រូតទៅតែម្នាក់ឯង ប្រទះនឹងពួកអ្នកស្រុកដែលរត់ទៅពួននៅកន្លែង ១ ក៏សួរថា ឃើញនាងកាំហ៊ូយ៉ិននៅពួនក្នុងទីនេះដែរឬ ? ។

នាងកាំហ៊ូយ៉ិនឆ្លើយថា ខ្ញុំនៅឯណេះ នាងក៏ធូរស្រាលក្នុងចិត្ត ព្រោះជឿតឃើញជូឡុងទៅដល់ ហើយថា អ្នកចូរជួយយកអាយុជីវិតខ្ញុំផង ថាហើយ ក៏យំសោកាពិលាប ។ ជូឡុងលោតចុះពីលើសេះខ្ញី ឃាតចូលទៅគំនាប់ហើយថា ដែលខ្ញុំបាទមិនបានរំពឹងអ្នកៗ ក៏បានសេចក្ដីលំបាកដូច្នេះ ទោសខ្ញុំបាទធុំសធ្ងន់ណាស់ ឥឡូវនាងបីហ៊ូយ៉ិននឹងអាគៅជាបុត្រនោះនៅឯណា ? ។ នាងកាំហ៊ូយ៉ិនប្រាប់ថា កាលទើបចុះពីលើរទេះ រត់ចូលទៅប្រឡំនឹងគ្រួសារអ្នកស្រុកដែលមកជាមួយគ្នា លុះទាហានចូចូដេញរាយចូលមកពីក្រោយ ទាំងអស់គ្នាក៏បែកខ្ចាត់ភ្ជាត់អស់ទៅមិនដឹងជាទៅនៅខាងណាទេ ។

កាលកំពុងតែនិយាយគ្នា ទទួលៈឃើញកងទ័ពចូចូលើកមក ១ កង ដេញគ្រប់គ្រួសារចូលមក , ជូឡុងឮសំឡេងទ្រហោយំអឺងកង ក៏ភ័យស្លុតស្មារតីលោតឡើងសេះខ្ញីឃាត ក្រឡេកទៅឃើញអ៊ីគោលើក

ទាហាន ១ គង់ ប្រហែលខាន់ប្ដាយ ចាប់បានប៉ីតុកចងដៃដឹកមកខាងក្រោយសេះ, ដូឡុងក៏បំផាយសេះចូលទៅស្រែកគំហកដោយសំឡេងយ៉ាំងខ្លាំង ទីងចូលច្បាំងតនឹងអ៊ុតោ ។ បរសេះចូលតស៊ូនឹងដូឡុងមិនទាន់បាន១ក្បួន ដូឡុងក៏យកទួនចាក់ត្រូវអ៊ុតោធ្លាក់ពីលើសេះស្លាប់ ហើយក៏ស្រាយចំណងប៉ីតុកចេញ ដណ្ដើមសេះបានពីទាហាន ២ ហើយឲ្យប៉ីតុក ១ នាងកាំហ៊ូយិន ១ ឡើងជិះសេះចេញទៅដល់ចុងស្ពាន ។

ទៀវហ៊ុយគ្រាន់ឡេកឃើញដូឡុង ក៏ស្រែកថា ហេតុម្ដេចបានជាដូឡុងប្រែចិត្តទៅចូលខាងចូចូ ? ។ ដូឡុងស្រែកតបថា អ្នកកុំស្ដីដូច្នោះ ដែលខ្ញុំបាត់យូរទាំងម៉្លេះ ព្រោះខ្ញាត់ក្នាត់បាត់នាងកាំហ៊ូយិន នាងប៉ីហ៊ូយិនទាំង ២ មិនដឹងទៅឯណា ខ្ញុំខំស្វះស្វែងតាមរកបានជាយឺតយូរមកជាក្រោយ ដែលថាខ្ញុំនឹងប្រែចិត្តចេញទៅស្រឡាញ់ចូចូ នោះមិនមែនទេ ។ ទៀវហ៊ុយស្ដាប់ហើយថា នេះហាក់តែកានយ៉ុងមកប្រាប់ការធ្ងន់ស្រាលដល់ខ្ញុំជាមុន បើកុំតែដូច្នោះ ខ្លួនអ្នកនឹងខ្ញុំក៏កាន់ប្រទុស្ដគ្នាទៅ ។ ដូឡុងសួរថា ឥឡូវចៅហ្វាយយើងនៅឯណា ? ។ ទៀវហ៊ុយឆ្លើយថា បងយើងនៅឯក្រោយផ្លូវមិនឆ្ងាយប៉ុន្មានទេ ។ ដូឡុងនិយាយនឹងប៉ីតុកថា អ្នកចូរនាំនាងកាំហ៊ូយិនទៅឲ្យចៅហ្វាយយើងមុនចុះ ខ្ញុំនឹងត្រឡប់វិលទៅស្វែងរកនាងប៉ីហ៊ូយិន និងអាតៅឲ្យឃើញសិនសឹមទៅជាក្រោយ ។ ដូឡុងនិយាយហើយបរសេះត្រឡប់ទៅជួបនឹងហែហ៊ូអ៊ុនកំពុងលើកទាហាន

ប្រហែល ៤០ នាក់ បរសេះកាន់ខ្លួនសៀតក្របីឈរស្ទាក់ផ្លូវជូឡុង ក៏បរសេះចូលតយុទ្ធនឹងហែហ៊ាអ៊ុនបានទាំងគ្មាន ក៏យកគ្រួនចាក់ត្រូវហែហ៊ាអ៊ុនធ្លាក់ពីលើសេះស្លាប់ ។ ពាហានទាំងអស់ក៏បែកខ្ចាត់ខ្ចាយរត់ទៅ ។ ហែហ៊ាអ៊ុននេះជាមនុស្សជំនិតទុកចិត្តរបស់ចូចូ មានកំឡាំងច្រើន ។ ចូចូស្រឡាញ់ឲ្យកាន់ក្របីឈ្មោះតីថនកៀម បើនឹងកាប់ដែកក៏ដូចកាប់បណ្តូលចេក ។

ជូឡុងបានក្របីហើយហូតចេញមកមើល ឃើញអក្សរចារឹកជាប់នឹងដង ក៏ដឹងថាក្របីឯករបស់ចូចូ, ជូឡុងក៏សៀតស្ពាយហើយបំបោលសេះពុះពារចំលាយចូលទៅរកនាងបីហ៊ួយអ៊ិនកូនកង់ទៀតម្នាក់ឯង មិនបានគោតញញើតនឹងសេចក្តីស្លាប់សោះ ប្រទះគ្រប់គ្រួអ្នកស្រុកទាំង២ដំបន់ ក៏សួររកនាងបីហ៊ួយអ៊ិនជាដរាប ។ មានមនុស្សម្នាក់ចង្អុលប្រាប់ថា នាងបីហ៊ួយអ៊ិនត្រូវខ្លួនត្រង់ភ្លៅដើរមិនរួច ពកូនអង្គុយគួនទៅត្រង់ជញ្ជាំងផ្ទះត្រង់ណោះ, ជូឡុងដឹងច្បាស់ដូច្នោះ ក៏បរសេះស្រូតទៅដល់ផ្ទះ ១ ភ្លើងឆេះនៅតែជញ្ជាំង ក៏ចូលទៅគន់គេមើល ឃើញនាងបីហ៊ួយអ៊ិនពអាតៅអង្គុយយំនៅក្បែរមាត់អណ្តូង ជូឡុងលោតចុះពីលើសេះរត់ចូលទៅគំនាប់ហើយក៏យំ ។

នាងបីហ៊ួយអ៊ិនឃើញជូឡុងទៅដល់ មានអំណរក្នុងចិត្តណាស់ថា អ្នកមកជួបនឹងខ្ញុំគ្រានេះ ក៏ដូចអ្នកមកយកជីវិតកូនទៅទុកឲ្យរស់ សូមឲ្យអ្នកមានសេចក្តីករុណានាំយកអាតៅទៅចុះ ដើម្បីឲ្យបិតាបានឃើញមុខ ឯខ្លួនខ្ញុំមុខជាស្លាប់ហើយ តាមតែវេរកម្មរបស់ខ្ញុំប្រាប់ ។ ជូឡុង

គបថា ដែលអ្នកបានដល់នូវសេចក្ដីទុក្ខលំបាកទាំងម្ល៉េះ ក៏ព្រោះខ្លួនខ្ញុំបានត្រូវក្រអ្នកមិនឈ្នះ ទោសទាំងអស់ក៏ធ្លាក់លើខ្លួនខ្ញុំបានជាទម្ងន់ ឥឡូវខ្ញុំបានបានខំស្វះស្វែងមករកអ្នកឃើញហើយ សូមអញ្ជើញអ្នកឡើងជិះសេះចុះ ខ្ញុំបាននឹងដើរដេងកំផាការពារមុខនាំអ្នកចេញទៅ ៗ នាងបិហ្វូ-យិនឆ្លើយថា អ្នកកុំព្រួយជាទុក្ខនឹងខ្ញុំឡើយ ដ្បិតខ្លួនខ្ញុំឈឺធ្ងន់ណាស់ហើយមុខជាមិនរស់ទេ ខ្ញុំនេះបើនឹងរស់រួចជីវិតក៏ពីព្រោះតែអ្នក ដែលអ្នកនឹងចុះពីលើសេះដើរដេងទៅ បីដូចជាជីវិតកូនខ្ញុំគ្មាននៅសោះឡើយ អ្នកចូលខំស្រូតយកតែកូនខ្ញុំទៅមុនចុះ កុំបីរវល់កំណាន់ចិត្តគិតដល់ខ្ញុំឡើយ ៗ ជូឡុងឆ្លើយតបថា អ្នកកុំដដែកដោះស្រាយឲ្យខ្ញុំបានរង់ចាំយូរឡើយ អញ្ជើញឡើងសេះឲ្យឆាប់ៗចុះ សំឡេងទាហានចូចូហោកញ្ច្រៀវខ្លាំងៗពួកចូលមកកាន់តែជិតណាស់ហើយ ៗ នាងបិហ្វូយិនថា បើអ្នកអាណិតហើយ ក៏ចូរស្រូតស្រូតយកកូនខ្ញុំរត់ទៅឲ្យរួចចុះ ខ្លួនខ្ញុំនេះនឹងទៅផងមិនបានទេ នឹងមកអំពល់រវល់អំពីនឹងខ្ញុំនេះ នឹងនាំគ្នាស្លាប់ទាំងអស់ទៅវ្ហ ហើយក៏យកកូននោះហុចទៅឲ្យជូឡុងៗ មិនព្រមទទួល នៅតែទទូចអញ្ជើញនាងបិហ្វូយិនឲ្យឡើងជិះសេះដ.ប់ ២-៣ គ្រា នាងបិហ្វូ-យិនក៏មិនព្រមឡើងជិះសេះសោះ ចេះតែអង្វរកះជាយូរណាស់ ៗ សំ-ឡេងទាហានចូចូក៏រឹតតែហោកញ្ច្រៀវខ្លាំង ៗ ជិតចូលមក ៗ ជូឡុងក៏និយាយថា អ្នកនៅតែអង់ឆ្លើយឲ្យយូរម្ល៉េះ បើកងទ័ពចូចូលើកចូលមកហើយ

នឹងមិននាំគ្នាស្លាប់បង់ការវេរវេទៅឬ ? ។ នាងបីហ៊ួយមិនព្រមដូច្នោះ ក៏យកអាតៅជាបុត្រនោះ បោះបោលទៅលើផែនដី ចំពោះមុខជូឡុងហើយក៏លោតចុះទៅក្នុងអណ្តូងទឹកស្លាប់ ១ រំពេច ។

ជូឡុងឃើញដូច្នោះ យំសោកបោកខ្លួនប្រាណ ដោយមានចិត្តអាណិតនាងបីហ៊ួយណាស់ ហើយក៏កកាយដីក្បែរមាត់អណ្តូងនោះអស់ទៅប្រាថ្នានឹងមិនឲ្យទាហានចូចូឃើញសាកសព ហើយយកសំពត់រុំខ្លួនអាតៅធ្វើជាថែបអង្រឹងចងភ្ជាប់កពីខាងមុខ ដោះខ្សែក្រោះបញ្ចូលទៅក្នុងដើមទ្រូង យកអាតៅលាក់ក្នុងក្រោះនោះទៅវិញ ឡើងសេះបរចេញមក ទទួលជួបនឹងហាន់បេងជាទាហានរងចូចូ លើកពលទាហានដេរទង់ស្ទាក់ពីមុខជូឡុង ។ ក៏បរសេះចូលច្បាំងនឹងហាន់បេងបាន ៣ ក្បួន ។ ហាន់បេងចាញ់ដៃជូឡុង ។ ចាក់ត្រូវនឹងលំពែងធ្លាក់ពីលើសេះស្លាប់ ក៏កាប់ចំលាយចេញទៅមុខជួបនឹងកងទ័ពទៀវទាប់ស្ទាក់ពីមុខទៀត ក៏បរសេះចូលប្រយុទ្ធគ្នានឹងទៀវទាប់បាន ១៥ ក្បួន ជូឡុងក៏ទាញសេះវ៉ះរត់ចេញ ។ ទៀវទាប់ ឃើញបានចំណាប់ក៏បរសេះដេញតាមទៅ ។ ជូ-ឡុងបរសេះរត់ទៅដោយលឿនរហ័សណាស់ ប្រទះនឹងថ្លុកចង្ហុក ១ អន្ទើសេះរត់ជៀសមិនទាន់ ក៏ធ្លាក់ចុះទៅក្នុងចង្ហុកនោះ ទាំងសេះទាំងមនុស្សក៏ដួលប្រមូលលើគ្នា ។ ទៀវទាប់ក៏ដេញតាមទៅទាន់ លោកទៅប្រុងចាក់នឹងលំពែង ។ ខណៈនោះជាបុណ្យបារមីរបស់អាតៅ ដែលនឹងបានធ្វើ

ជាក្សត្រសោយរាជសម្បត្តិមិនគួរនឹងស្លាប់ដោយគ្រឿងសស្ត្រាវុធ  ក៏ឲ្យបណ្តាលជាពន្លឺភ្លើង ឆេះចេញអណ្តាតឡើង  ត្រង់កន្លែងជូឡុងធ្លាក់នោះ ទៀវខាប់ភ័យភ្ញាក់ដូចគេក្រទាក់សេះនោះទុចថយមកក្រោយ ។ ជូឡុងក៏ក្រទិចឲ្យសេះស្ទុះឡើងរួចក៏ហោះចេញបានពីក្នុងជង្ហុករណ្តៅរត់ទៅបាន ។ ទៀវខាប់ឃើញច្បាស់ដូច្នោះ  ក៏មិនអាចនឹងដេញតាម ។ ឯម៉ាកៀន; នឹង ទៀវគី ២ នាក់  លើកទាហានរត់តាមពីក្រោយពីមុខហើយស្រែកថា ជូឡុងគ្រានេះនឹងរត់ពីដៃយើងមិនរួចទេ ។ ឯទៀវហៀ  នឹងទៀវឡាំ ២ នាក់ក៏លើកទាហានចេញទៅស្ទាក់ពីមុខ ។ ជូឡុងបរសេះចូលប្រយុទ្ធគ្នា នឹងពួកទាហានទាំង ៤ ក្រុមនេះជាពន្លឹក ។ ពួកកូនទាហានទាំងអម្បាលនោះ  ក៏ចោមរោមព័ទ្ធជូឡុងជាច្រួលច្របល់ ។ ជូឡុងក៏ហូតក្រប៊ីដេញកាប់ចាក់ស្លាប់ទាហានទាំងនោះច្រើនណាស់ ។

ចូចូឡើងទៅលើភ្នំកេងសាន  ក្រឡេកមើលមកក្រោយឃើញជូ-ឡុងចូលប្រយុទ្ធកកកុញកងទ័ពជាច្រួលច្របល់ដោយទាហានទាំងពួង  ឃើញថ្វីដៃដែលកាប់ចាក់មិនមានកញ្ញើញញើតទៅខាងណា  ទើបសួរថា  ទាហានទៀតម្នាក់ឈ្មោះអ្វីក៏មានថ្វីដៃខ្លាំងពូកែម៉្លេះ ? ។ ទាហានឮចូចូសួរ  ក៏បរសេះចុះនៅពីលើភ្នំ  ចូលទៅស្ទាក់ពីមុខជូឡុង  ហើយស្រែកសួរថា អ្នកឯងឈ្មោះអ្វី ? ។  ជូឡុងក៏ស្រែកតបមកវិញថា  យើងឈ្មោះទៀវ ជូឡុង ។ ទាហានក៏ត្រឡប់សេះឡើងទៅជំរាបចូចូ ។ ក៏សរសើរថា

ទាហាននេះមានអំណាចបីដូចខ្លា ហើយក៏បង្គាប់ឲ្យស្រែកប្រកាសថា កុំឲ្យនរណាយកធ្នូបាញ់ជូឡុងឡើយ ត្រូវជួយគ្នាព័ទ្ធចាប់យកខ្លួនទាំងរស់ឲ្យបាន ៗ ឯជូឡុង ក៏បរសេះបំពានវាក់កាប់សម្លាប់ពួកទាហានចេញពីក្នុងចំណោមបានដោយហេតុថា ចូចូហាមប្រាមទាហានទាំងពួងមិនឲ្យបាញ់ទងធ្នូ គឺថាបុណ្យបារមីរបស់អាតៅ ដែលនឹងបានសោយរាជ្យជាព្រះមហាក្សត្រិយ៍ទៅឯមុខ ទើបបណ្តាលឲ្យជូឡុងសម្លាប់មេកងធំក្នុងកងទ័ពចូចូបាន ២ នាក់, ទាហានឯក ៥០ នាក់ ឈាមក៏ហូរប្រឡាក់ពេញអស់ទាំងគ្រោះនឹងខ្លួនសេះ បីដូចគេស្រោចទឹកលាក់ ៗ

ជូឡុងបរសេះនាំអាតៅស្រូតទៅដល់ជើងភ្នំ ១ ទៀត ប្រទះនឹងចុងជិន, ចុងស៊ុនបងប្អូនទាំង ២ នាក់ ដែលជាទាហានរបស់ហាហ៊ូតុន ញាក់សេះចេញមកស្ទាក់ពីមុខ, ជូឡុងក៏បរសេះចូលប្រយុទ្ធគ្នានឹងចុងជិន, ចុងស៊ិនបាន ៣ គ្រួកាត់ត្រូវចុងជិនធ្លាក់ពីលើសេះស្លាប់, រួចជូឡុងក៏បរសេះស្រូតតទៅ ៗ ចុងស៊ុនក៏បរសេះចេញតាមខ្លួនពីក្រោយ ជាប់គ្នានឹងសេះជូឡុង ឆាកទិញចាក់ដោយលំពែង សេះក៏ស្ទុះដែរហួសមួយថ្នាក់ រៀបនឹងចាក់កំផុតទៅពេលនោះទៅបានទឹមគ្នា ៗ ជូឡុងឆាកសេះត្រឡប់មកតនឹងចុងស៊ុន ទទួលសេះចុងស៊ុនដេញខាងជិតៈនៅឆាកខ្លួនមិនទាន់ ដើមទ្រូងចុងស៊ុននឹងដើមទ្រូងជូឡុងក៏ទៅប៉ះទង្គិចគ្នា ជូឡុងយកលំពែងវាត់លំពែង

(នៅមានត)

## ផ្នែកកំណត់និងប្រវត្តិការណ៍

# អំពីសេចក្ដីថ្លែងការណ៍សារពត៌មាន របស់ព្រះតេជព្រះគុណ ព្រះពោធិវង្ស ហួត - តាត អគ្គាធិការនៃពុទ្ធិកសិក្សា

ចាប់តាំងពីថ្ងៃទី ១៥ មិថុនា រហូតដល់ថ្ងៃទី ១៧ កក្កដា ១៩៥៩ ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត - តាត អគ្គាធិការនៃពុទ្ធិកសិក្សា ព្រមទាំងសហការី គឺលោកយឹម - វ៉ែន ទីប្រឹក្សាបច្ចេកទេស ១, ព្រះវិន័យសំវរ ជាច់ - កឹង អគ្គាធិការរងភូមិភាគខាងជើង ១, ព្រះគ្រូមុនី-សោភ័ណ សេរ-នាង អគ្គាធិការរងភូមិភាគខាងត្បូង ១, លោករស់-ហូ លេខាធិការ ១, បាននិមន្ត អញ្ជើញទៅទស្សនាចរត្រួតត្រាសាលាពុទ្ធិក-បឋមសិក្សាគ្រប់ខេត្តក្នុងព្រះរាជអាណាចក្រ ដើម្បីពន្យល់ណែនាំលោកអធិការប្រចាំខេត្ត អធិការប្រចាំស្រុក លោកចៅអធិការ និងលោកគ្រូបង្រៀនទាំងឡាយ អំពីរបៀបចាត់ការពិនិត្យត្រួតត្រាសាលារៀន និងកិច្ចបង្រៀនតាមវិធីគរុកោសល្យ ឲ្យបានល្អតាសម័យនេះតទៅ ។

ឯការទស្សនាចរនេះ បានធ្វើទៅតាមរថយន្តខ្លះ តាមកាណូតខ្លះ (ដូចជាខេត្តកណ្ដាល) ហើយបានចែកជា ៥ លើកគឺ :

លើកទី១–ខេត្តតាកែវ – កំពត – កំពង់ស្ពឺ ,

លើកទី២ – នៅខេត្តព្រៃវែង – ស្វាយរៀង ,

លើកទី៣ – នៅខេត្តកំពង់ធំ – សៀមរាប – បាត់ដំបង – ពោធិសាត់ – កំពង់ឆ្នាំង ,

លើកទី៤ – នៅខេត្តកំពង់ចាម – ក្រចេះ – ស្ទឹងត្រែង ,

លើកទី៥ – នៅខេត្តកណ្ដាល ។

នៅខេត្តតាកែវ មានការប្រជុំ ២ កន្លែង គឺនៅវត្តអំពិលបី ស្រុកសំរោង១, នៅវត្តសីហាតេជារាម ក្រុងតាកែវ ១ ។

នៅខេត្តកំពត មានប្រជុំពីរកន្លែង គឺនៅវត្តត្រែស្រកាន់ ស្រុកបន្ទាយមាស១, នៅវត្តកំពត ក្រុងកំពត ១ ។

នៅខេត្តកំពង់ស្ពឺ មានកន្លែងប្រជុំ១ គឺនៅវត្តប្រុំ ក្រុងកំពង់ស្ពឺ ។

នៅខេត្តព្រៃវែង មានកន្លែងប្រជុំ ២ គឺនៅសាលារៀនក្រុងព្រៃវែង១ និងវត្តសិរីសោធរ ស្រុកកំពង់ត្របែក ១ ។

–នៅខេត្តស្វាយរៀង មានទីប្រជុំ១ គឺនៅវត្តជម្ពូព្រឹក្សា ។

–នៅខេត្តកំពង់ធំ មានទីប្រជុំ១ គឺនៅវត្តកំពង់ធំ ក្រុងកំពង់ធំ ។

–នៅខេត្តសៀមរាប មានទីប្រជុំ ១ គឺនៅវត្តដំណាក់ ក្រុងសៀមរាប ។

–នៅខេត្តបាត់ដំបង មានទីប្រជុំ២ គឺនៅវត្តឫស្សីក្រោក ស្រុកមង្គលបុរី១, នៅវត្តពោធិវាល ក្រុងបាត់ដំបង ១ ។

-នៅខេត្តពោធិ៍សាត់ មានកន្លែងប្រជុំ១ គឺនៅវត្តបន្ទាយដី ក្រុងពោធិ៍សាត់ ។

-នៅខេត្តកំពង់ឆ្នាំង មានទីប្រជុំ១ គឺនៅវត្តទេពធីតារាម ក្រុងកំពង់ឆ្នាំង ។

-នៅខេត្តកំពង់ចាម មានទីប្រជុំ៣ គឺនៅវត្តសុគន្ធារាម ស្រុកដើមព្រៃ១, នៅវត្តចិនកុក ក្រុងកំពង់ចាម១, នៅវត្តវិហារទន្ទឹម ស្រុកត្បូងឃ្មុំ១ ។

-នៅខេត្តក្រចេះ មានទីប្រជុំ ១ គឺនៅវត្តសិរីសម្បូរវង្ស ក្រុងក្រចេះ ។

-នៅខេត្តស្ទឹងត្រែង មានទីប្រជុំ ១ គឺនៅវត្តកត្តិញ្ញារាម ក្រុងស្ទឹងត្រែង ។

-នៅខេត្តកណ្ដាលមានទីប្រជុំ ៨ កន្លែងគឺ:

១-នៅវត្តជោតមង្គល ស្រុកពញាឮ ២-នៅវត្តស្វង ស្រុកក្ដាំពេញ
៣-នៅវត្តទេពវិសាល ស្រុកស្អាង ៤-នៅវត្តសំប៉ាន ស្រុកកោះធំ
៥-នៅវត្តស្វាកែត ស្រុកកៀនស្វាយ ៦ នៅវត្តថ្គរ ស្រុកល្វាឯម
៧-នៅវត្តចតុមុខារាម ស្រុកមុខកំពូល ៨ នៅវត្តគន្ធីយារាម ស្រុកខ្សាច់កណ្ដាល ។

នៅគ្រប់ទីប្រជុំ ព្រះតេជព្រះគុណ ព្រះពោធិវង្ស មានព្រះពុទ្ធដីកាប្រាស្រ័យទាក់ទង សំដែងសេចក្ដីគោរពចំពោះព្រះសង្ឃទាំងអស់

ដែលនិមន្តមកពីចំងាយ ព្រមទាំងប្រាស្រ័យកក់ទាក់ ចំពោះមន្ត្រីខេត្រ ស្រុក ឃុំ មានលោកចៅហ្វាយខេត្រ-លោកចៅហ្វាយស្រុក- និងលោកមេឃុំជាដើម ដែលបានមកជួយឧបត្ថម្ភកិច្ចទស្សនាចរនេះ ។ រួចទើបព្រះតេជព្រះគុណព្រះពោធិវង្ស ថ្លែងពន្យល់អំពីកិច្ចសិក្សាខាងព្រះពុទ្ធសាសនាយ៉ាងពិស្ដារ ដូចមានសេចក្ដីជាគោលតទៅនេះ ៖

១- ពន្យល់អំពីព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ដែលមានព្រះករុណាជាម្ចាស់ជីវិតលើត្បូងទាំងពីរព្រះអង្គ និងសម្ដេចព្រះឧបយុវរាជ ជាព្រះបិតាឯករាជ្យជាតិ ទ្រង់ជាអគ្គសាសនូបត្ថម្ភ ទ្រង់បានជួយទំនុកបំរុងព្រះពុទ្ធសាសនាគ្រប់បែបគ្រប់យ៉ាង ទ្រង់ព្រះបរមរាជានុញ្ញាតឲ្យរៀបចំជាសាលាពុទ្ធិកបឋមសិក្សា . ពុទ្ធិកមធ្យមសិក្សា-ពុទ្ធិកឧត្ដមសិក្សា ឲ្យមានរបៀបរៀបរយដូចជាការសិក្សាខាងអាណាចក្រ ឬការសិក្សាក្នុងសាកលលោក ដើម្បីញុំាងព្រះពុទ្ធសាសនាឲ្យមានវឌ្ឍនភាពជីកុំស្ទាងរុងរឿង ដូចមានព្រះរាជសុន្ទរកថា សម្ដេចព្រះឧបយុវរាជ ទ្រង់បានថ្លែងក្នុងឱកាសបើកការសិក្សាពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ - និងសម្ពោធគ្រឹះស្ថានព្រះសីហនុ ពីថ្ងៃទី ១០ ខែមិថុនា ១៩៥៩ ។

២- ពន្យល់ពីកិច្ចសិក្សាខាងព្រះពុទ្ធសាសនា សុំឲ្យព្រះសង្ឃយកចិត្តទុកដាក់ទំពេញ ព្រោះជាមូលដ្ឋានសម្រាប់បណ្ដុះបណ្ដាលព្រះសង្ឃឲ្យមានការចេះដឹង បើព្រះសង្ឃចេះដឹងហើយ ទើបអាចញុំាងព្រះពុទ្ធ

សាសនាឲ្យមានវឌ្ឍនភាពក្នុងស្ថានបាន ។

៣– ពន្យល់អំពីព្រះសង្ឃជាបុគ្គលគួរគោរពបូជាអំពីគ្រហស្ថ ក្នុងសម័យបច្ចុប្បន្ននេះ គ្រហស្ថមានវិជ្ជាច្រើន ព្រះសង្ឃគោរពមានវិជ្ជាច្រើនជាងគ្រហស្ថទើបសមរម្យ បើព្រះសង្ឃឯងឥតល្អ មុខជាគ្មានអ្នកណាគោរពទេ ព្រះសង្ឃដែលល្អ មិនគាប់ចិត្តផ្ទាល់ដោយខ្លួនឯងផង មិនធ្ងន់ទៅព្រះសង្ឃឯទៀតផង មិនតែប៉ុណ្ណោះ ធ្វើឲ្យព្រះពុទ្ធសាសនាដែលធ្លាប់តែក្នុងស្ថានឲ្យអាប់ឱនផង ។

៤– ពន្យល់អំពីព្រឹត្តិការណ៍របៀបសិក្សាសម័យបុរាណ និងបច្ចុប្បន្ន ដើម្បីឲ្យព្រះសង្ឃចំរៀន ព្រោះសម័យនេះហើយ ដែលព្រះសង្ឃត្រូវធ្វើដំណើរទៅកាន់ការក្នុងស្ថានឲ្យទាន់ពេលវេលា ។

៥– ពន្យល់ថា ក្នុងសកលលោកនេះ ប្រទេសណាមិនធ្លាប់មានព្រះពុទ្ធសាសនា ក៏ត្រឡប់ជាមានឡើង ប្រទេសណាធ្លាប់មានហើយ គេខំប្រឹងធ្វើឲ្យរុងរឿងតទៅទៀត ។ ប្រទេសកម្ពុជាមានព្រះពុទ្ធសាសនាចំនួនជា ២០០០ ឆ្នាំហើយ គួរព្រះសង្ឃនិងគ្រហស្ថប្រជុំជ្រែងព្រះពុទ្ធសាសនាឲ្យរុងរឿង ដើម្បីផ្សាយទូទៅក្នុងប្រទេសនិងសាកលលោក ព្រោះព្រះពុទ្ធសាសជាសាសនានាំមកនូវសន្តិភាព ។

បន្ទាប់មក ព្រះគ្រូមុនីសាភ័ណ សេខ–មាន អគ្គាធិការនៃ

ឲ្យបានថ្លែងពន្យល់អាចារ្យបង្រៀន តាមកម្មវិធីថ្មី តាមរបៀបវិធីគរុកោសល្យ ។

តពីនោះមកទៀត លោក យ៉ែម-វ៉ែន ទីប្រឹក្សាបច្ចេកទេស បាន ពន្យល់លោកគ្រូមេគណ អនុគណ - ចៅអធិការវត្ត ដែលមានសាលាពុទ្ធិកបឋមសិក្សា និងលោកអាចារ្យបង្រៀនឲ្យជ្រាបពីមុខការបច្ចេកទេស ដែលជានាទីរបស់លោក គឺកិច្ចការជាអធិការប្រចាំខេត្ត - អធិការប្រចាំស្រុក អំពីការជួយឧបត្ថម្ភសាលាពុទ្ធិកបឋមសិក្សា - អំពីត្រួតសាលា - អំពីរៀបចំសាលា - អំពីការសុំបើកសាលាថ្មី - អំពីការសុំអាចារ្យបង្រៀន អំពីអាចារ្យលាឈប់លែងបង្រៀន ។

ទីបំផុត បានចែកសៀវភៅសម្រាប់បង្រៀន - សៀវភៅសរសេរ - និងលិខិតផ្សេងៗ សម្រាប់សាលាពុទ្ធិកបឋមសិក្សា ។

នៅគ្រប់ទីកន្លែងប្រជុំ មានដំណើរការប្រព្រឹត្តទៅដោយស្រួលទាំងអស់ ព្រោះមានលោកចៅហ្វាយខេត្ត - លោកចៅហ្វាយស្រុក - លោកមេឃុំ និងសហការី អញ្ជើញមកជួយឧបត្ថម្ភស្ទើរគ្រប់កន្លែង ។

ក្រសួងធម្មការ សូមឆ្លៀតឱកាសដ៏ប្រពៃនេះ សូមឱនកាយថ្វាយបង្គំចំពោះលោកគ្រូជាមេគណ - លោកគ្រូអនុគណ - លោកចៅអធិការ ព្រមទាំងព្រះសង្ឃគ្រប់ព្រះរាជាណាចក្រ សំដែងនូវការ-

វិភាពដ៏ខ្ពង់ខ្ពស់ សូមព្រះអង្គជួយឧបត្ថម្ភសាលាដែលសង់នៅទីវត្ត ដើម្បីញុំាងសាលាពុទ្ធិកបឋមសិក្សាទាំងនេះ ឲ្យមានវឌ្ឍនភាពបរិបូណ៌ទៅអនាគត ។ បើពុទ្ធិកបឋមសិក្សាចំរើនហើយ ព្រះពុទ្ធសាសនាក៏នឹងចំរើនតាមលំដាប់ ហើយប្រទេសកម្ពុជាក៏នឹងឡើងទៅកាន់សន្តិភាពនឹងវឌ្ឍនភាពសម្បូណ៌ដោយអ្នកប្រាជ្ញបណ្ឌិតខាងព្រះពុទ្ធសាសនា ដែលជាមគ្គុទ្ទេសក៍ដ៏ប្រសើរ សម្រាប់ដឹកនាំជាតិខ្មែរទៅតាមមាគ៌ានយោបាយសន្តិភាពដ៏ឧត្តុង្គឧត្តមនៃសម្តេចព្រះឧបយុវរាជ ជាព្រះបិតាឯករាជ្យជាតិទៅកាន់ត្រើយនាយ គឺមហាសុភមង្គលគ្រប់យ៉ាងសមតាមព្រះរាជបំណងតាមលំដាប់ ។

មួយទៀត ក្រសួងធម្មការ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះឯកឧត្តមព្រះរាជប្រតិភូប្រចាំខេត្ត សហជីវិនទៅហ្វាយខេត្ត ចៅហ្វាយស្រុក ព្រមទាំងសហការីរបស់លោកដែលបានជួយឧបត្ថម្ភកងការទស្សនាចរព្រះតេជព្រះគុណព្រះពោធិវង្ស នេះ ឲ្យមានដំណើរការប្រព្រឹត្តទៅបានដោយល្អប្រពៃ និងសូមពឹងផ្អែកយ៉ាងមុតមាំ លើឯកឧត្តមព្រះរាជប្រតិភូប្រចាំខេត្ត និងសហជីវិនទៅហ្វាយខេត្ត សូមឲ្យជួយឧបត្ថម្ភវត្តអារាមនិងសាលាសាសនសិក្សា ដើម្បីឲ្យបានសេចក្តីចំរើនពេញបរិបូណ៌នឹងដើម្បីឲ្យបានទៅជាប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា ។

## ពត៌មានផ្សេងៗរបស់ក្រសួងធម្មការ

### អំពីការតាំងចៅអធិការ

បានតាំងភិក្ខុ ឡោ-ជិនលន់ ជាចៅអធិការ វត្តកណ្ដាលកោះសុទិន ឃុំកោះសុទិន ស្រុកកោះសុទិន ខេត្តកំពង់ចាម ។

### អំពីការតាំងគ្រូសូត្រ

បានតាំងភិក្ខុ កែន-យឹម ជាគ្រូសូត្រស្ដាំ វត្តពិកិន្ទាពម ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង ។

បានតាំងភិក្ខុ ប៊ុត-ង៉ុយ ជាគ្រូសូត្រឆ្វេង វត្តពិកិន្ទាពម ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង ។

បានតាំងភិក្ខុ ជុំ-នុល ជាគ្រូសូត្រស្ដាំ វត្តកណ្ដាលកោះសុទិន ឃុំកោះសុទិន ស្រុកកោះសុទិន ខេត្តកំពង់ចាម ។

បានតាំងភិក្ខុ អឹម-ខេង ជាគ្រូសូត្រឆ្វេង វត្តកណ្ដាលកោះសុទិន ឃុំកោះសុទិន ស្រុកកោះសុទិន ខេត្តកំពង់ចាម ។

( តមក )

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

អដាដ្យ នពុំ. កិរិយាត្រេចរង្គាត់ ។

អដី–ក្ប្រ ក្រ. ចូលទៅជិត ។

អដ្ដ បុំ. បន្ទាយ, បន្ទាយល្វាំ ។ *អដ្ដាល, អដ្ដាលក* បុំ. បន្ទាយ ។

*-ចារក* បុំ អធិការទីផ្សារ ។

អដ្ដ សំឃដ្ដ ពុំ. កិរិយាប៉ះទង្គិចដ៏ខ្លាំង, សូរទង្គិចគ្នា ។

អដ្ដ ហាស បុំ កិរិយាសើចដ៏ខ្លាំង, សំណើចក្អាកក្អាយ. ( នៃឥសូរ: ) ។ *អដ្ដ*

*-ហាស្យ* នពុំ. កិរិយាសើចដ៏ខ្លាំង ។

អដ្យា ស្ត្រី. កិរិយាដើរត្រេច, កិរិយាដើរសាត់ព្រាត់ ។

អណិមន៑ បុំ. ធម្មជាតល្អិត, បរមាណូ ។

អណីមាណ្ឌវ្យ បុំ. ឈ្មោះឫសី ។

អណុ (-ណ្វី) គុ. ឆ្មារ, ល្អិត, ស្ដើង, ខ្សោយ, សុខុម; ដែលប្រមាណមិនបាន ។ បុំ. គ្រាប់ (millet?) ។ នពុំ. ឈ្មោះវេលា ។ – ត្វ នពុំ. ភាពនៃអណូ ។– មាត្រិក គុ. ដែលមានមាត្រាជាបរមាណូ ។ អណុត្ត បុំ. ប្រស្នាដែលដោះស្រាយបានដោយប្រាជ្ញាសុខុមគម្ភីរភាព ។